ការិយាល័យប្រចាំប្រទេសរបស់អង្គការពលកម្មអន្តរជាតិសម្រាប់ប្រទេសថៃ កម្ពុជា និងសាធារណៈរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ (Co-Bangkok)
ILO/EC គម្រោង "ការតាមដាន និងវាយតម្លៃវឌ្ឍនភាពស្តីពីការងារសមរម្យ" (MAP)

International
Labour
Office

# សិក្ខាសាលាបណ្តុះបណ្តាល និងពិគ្រោះយោបល់ត្រីភាគីស្តីពី "ការវាស់វែងការងារសមរម្យនៅប្រទេសកម្ពុជា"

របាយការណ៍សិក្ខាសាលា

ថ្ងៃទី០៤-០៦ ខែឧសភា ឆ្នាំ២០១១ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ឯកសារនេះត្រូវបានផលិតឡើងក្រោមជំនួយឧបត្ថម្ភពីសហភាពអឺរ៉ុប ។ រាល់ខ្លឹមសារដែលបានបង្ហាញនៅក្នុងឯកសារនេះ មិនបានឆ្លុះបញ្ចាំងអំពីទស្សនៈជាផ្លូវការរបស់សហភាពអឺរ៉ុបឡើយ ។

**ការិយាល័យប្រចាំប្រទេសរបស់អង្គការពលកម្មអន្តរជាតិសម្រាប់ប្រទេសថៃ កម្ពុជា និងសាធារណៈរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ (Co-Bangkok)**

**ILO/EC គម្រោង "ការតាមដាន និងវាយតម្លៃវឌ្ឍនភាពស្តីពីការងារសមរម្យ" (MAP)**

**របាយការណ៍សិក្ខាសាលា**

# សិក្ខាសាលាបណ្តុះបណ្តាល និងពិគ្រោះយោបល់ត្រីភាគីស្តីពី " ការវាស់វែងការងារសមរម្យនៅប្រទេសកម្ពុជា "

## ថ្ងៃទី០៤-០៦ ខែឧសភា ឆ្នាំ២០១១

## រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ឯកសារនេះត្រូវបានរៀបចំដោយការិយាល័យពលកម្មអន្តរជាតិ
ដោយការផ្តល់ឥណទានពីសហភាពអឺរ៉ុប ក្រោមគម្រោង ILO/EC
"ការតាមដាន និងវាយតម្លៃវឌ្ឍភាពស្តីពីការងារសមរម្យ" (MAP)

**ការិយាល័យពលកម្មអន្តរជាតិ**
**បាងកក និង ហ្ស៊ឺណែវ**

**ខែមិថុនា ឆ្នាំ២០១១**

សិទ្ធិចម្លង © អង្គការពលកម្មអន្តរជាតិ ឆ្នាំ២០១១

ការបោះពុម្ពផ្សាយរបស់ការិយាល័យពលកម្មអន្តរជាតិទទួលការរក្សាសិទ្ធិក្រោមពិធីសារ២នៃអនុសញ្ញាសិទ្ធិចម្លងជាសកល។ ទោះជាយ៉ាងដូច្នេះក្តី ការដកស្រង់ខ្លីៗចេញពីការបោះពុម្ពផ្សាយនេះអាចធ្វើការផលិតឡើងវិញបាន ដោយពុំចាំបាច់មានការអនុញ្ញាតក្នុងលក្ខខណ្ឌដែលមានការបញ្ជាក់ពីប្រភពដើម ។ សម្រាប់សិទ្ធិនៃការផលិតឡើងវិញ ឬការបកប្រែ គួរធ្វើពាក្យស្នើសុំទៅផ្នែកបោះពុម្ពផ្សាយនៃការិយាល័យពលកម្មអន្តរជាតិ (ផ្នែកសិទ្ធិ និងការអនុញ្ញាត) ដែលមានអាសយដ្ឋានៈ ការិយាល័យពលកម្មអន្តរជាតិ CH-1211 Geneva 22 Switzerland ។ ការិយាលយពលកម្មអន្តរជាតិសូមស្វាគមន៏ការដាក់ពាក្យស្នើសុំនេះ។

បណ្ណាល័យ ស្ថាប័ន និងអ្នកប្រើប្រាស់ផ្សេងៗទៀតដែលមានចុះបញ្ជីនៅចក្រភអង់គ្លេសជាមួយទីភ្នាក់ងារផ្តល់អាជ្ញាប័ណ្ណសិទ្ធិចម្លង អាសយដ្ឋានៈ 90 Tottenham Court Road, London W1T 4LP [Fax: (+44) (0)20 7631 5500 ; email: cla@cla.co.uk] នៅសហរដ្ឋអាមេរិកជាមួយមជ្ឈមណ្ឌលបញ្ជាក់សិទ្ធិចម្លង អាសយដ្ឋានៈ 222 Rosewood Drive, Danvers, Ma 01923 [Fax: ( +1) (978) 750 4470; email: info@copyright.com] ឬនៅក្នុងប្រទេសផ្សេងទៀត ជាមួយអង្គការដែលទាក់ទងនឹងសិទ្ធិនៃការផលិតឡើងវិញ អាចធ្វើការថតចម្លងបានដោយយោងតាមអាជ្ញាប័ណ្ណដែលចេញឱ្យពួកគេសម្រាប់គោលបំណងនេះ ។

---

ILO ការរាយឈ្មោះទិន្នន័យបោះពុម្ពផ្សាយ

របាយការណ៏សិក្ខាសាលា : សិក្ខាសាលាបណ្តុះបណ្តាល និងពិគ្រោះយោបល់ត្រីភាគីស្តីពី "ការវាស់វែងការងារសមរម្យនៅប្រទេសកម្ពុជា" ថ្ងៃទី៤-៦ ខែឧសភា ឆ្នាំ២០១១ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា/ការិយាល័យប្រចាំប្រទេសរបស់អង្គការពលកម្មអន្តរជាតិសម្រាប់ប្រទេសថៃ កម្ពុជា និងសាធារណៈរដ្ឋប្រជាធិបតេយ្យប្រជាមានិត្យឡាវ (Co-Bangkok) / ILO/EC គម្រោង "ការតាមដាន និងវាយតម្លៃវឌ្ឍនភាពស្តីពីការងារសមរម្យ" (MAP)-បាងកក ILO ២០១១។
1 v.
ISBN: ~~978-92-2-125176-7~~; ~~978-92-2-125177-4~~ (web pdf)

ការិយាល័យអង្គការពលកម្មអន្តរជាតិ, ការិយាល័យតំបន់នៃអង្គការពលកម្មអន្តរជាតិសម្រាប់អាស៊ី និងប៉ាស៊ីហ្វិក
សិក្ខាសាលាបណ្តុះបណ្តាល និងពិគ្រោះយោបល់ត្រីភាគីស្តីពីការវាស់វែងការងារសមរម្យនៅប្រទេសកម្ពុជា (ឆ្នាំ២០១១ ភ្នំពេញ កម្ពុជា)។

ការងារសមរម្យ/ការងារ/ការវាស់វែង/ការប្រមូលទិន្នន័យ/ប្រព័ន្ធព័ត៌មានទីផ្សារការងារ/កម្ពុជា

13.01.1

---

នាមកត្តាដែលបានប្រើនៅក្នុងការបោះពុម្ពផ្សាយរបស់ ILO ដែលស្របតាមការអនុវត្តន៏របស់សហប្រជាជាតិ និងការបង្ហាញដែលមាននៅក្នុងការបោះពុម្ពផ្សាយនេះមិនបញ្ជាក់ពីការបញ្ចេញមតិយោបល់ណាមួយពីការិយាល័យពលកម្មអន្តរជាតិដែលទាក់ទងនឹងស្ថានភាពច្បាប់នៃប្រទេសណាមួយ តំបន់ ឬទឹកដី ឬអាជ្ញាធរនៃប្រទេសនោះ ឬទាក់ទងនឹងការកំណត់ព្រំដែននៃប្រទេសនោះ ។

ការទទួលខុសត្រូវចំពោះមតិយោបល់ដែលបានបញ្ចេញនៅក្នុងអត្ថបទមានចុះហត្ថលេខា ក្នុងការសិក្សា និងការចូលរួមវិភាគទានផ្សេងទៀតគឺស្ថិតនៅលើអ្នកនិពន្ធតែម្នាក់ឯង ហើយការបោះពុម្ពផ្សាយនេះមិនមានន័យថាជាការយល់ស្របតាមដោយការិយាល័យពលកម្មអន្តរជាតិចំពោះមតិយោបល់ដែលបានបញ្ចេញនៅក្នុងការបោះពុម្ពផ្សាយនេះទេ។

ការយោងអំពីឈ្មោះក្រុមហ៊ុន និងផលិតផលពាណិជ្ជកម្ម ព្រមទាំងដំណើរការមិនបញ្ជាក់ថាជាការយល់ស្របតាមដោយការិយាល័យពលកម្មអន្តរជាតិឡើយ ហើយការដែលមិនបានបញ្ចេញការសម្គាល់ក្រុមហ៊ុនណាមួយ ផលិតផលពាណិជ្ជកម្មណាមួយ ឬដំណើរការគឺមិនមែនជាសញ្ញានៃការមិនយល់ព្រមដែរ។

ការបោះពុម្ពផ្សាយរបស់អង្គការពលកម្មអន្តរជាតិអាចរកបានតាមរយៈកន្លែងលក់សៀវភៅធំៗ ឬនៅការិយាល័យអង្គការពលកម្មអន្តរជាតិនៅប្រទេសជាច្រើន ឬដោយផ្ទាល់ពីកន្លែងបោះពុម្ពផ្សាយរបស់ការិយាល័យពលកម្មអន្តរជាតិ CH-1211 Geneva 22, Switzerland ។ សៀវភៅរាយឈ្មោះ ឬបញ្ជីនៃការបោះពុម្ពថ្មីៗអាចរកបានដោយមិនបង់ប្រាក់ពីអាសយដ្ឋានខាងលើ ឬតាមអ៊ីម៉ែល : pubvente@ilo.org ។

សូមមើលវេបសាយរបស់យើង : www.ilo.org/publns ។

---

បោះពុម្ពផ្សាយដោយការិយាល័យអង្គការពលកម្មអន្តរជាតិ ហ្សឺណែវ ប្រទេសស្វីស

# បុព្វកថា

សិក្ខាសាលាបណ្តុះបណ្តាល និងពិគ្រោះយោបល់ត្រីភាគីស្តីពីការវាស់វែងការងារសមរម្យនៅប្រទេសកម្ពុជា ត្រូវបានរៀបចំឡើងនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ចាប់ពីថ្ងៃទី៤ ដល់ថ្ងៃទី៦ ខែឧសភា ឆ្នាំ២០១១ ដោយមានកិច្ចសហការរៀបចំជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអង្គការពលកម្មអន្តរជាតិ។ កិច្ចប្រជុំនេះគឺជាការតាមដាន និងពិនិត្យមើលឡើងវិញពីសេចក្តីថ្លែងការណ៍របស់អង្គការ ILO ស្តីពីយុត្តិធម៌សង្គមសម្រាប់សកលភាវូបនីយកម្មមួយដែលមានភាពស្មើភាពគ្នា( ឆ្នាំ២០០៨)[១] ដែលបានស្នើឱ្យមានការបង្កើតនូវសូចនាករ ឬស្ថិតិសមស្របមួយ ដោយអាចមានជំនួយពីអង្គការ ILO ដើម្បីតាមដានមើលវឌ្ឍនភាពនៃការអនុវត្តរបៀបវារៈការងារសមរម្យរបស់អង្គការ ILO ។

នាពេលកន្លងមក ប្រទេសជាច្រើនបានស្នើសុំអង្គការ ILO ឱ្យគាំទ្រកិច្ចខិតខំប្រឹងប្រែងរបស់ពួកគេលើការតាមដាន និងវាយតម្លៃវឌ្ឍនភាពស្តីពីការងារសមរម្យ។ ជាការឆ្លើយតប អង្គការ ILO ដោយមានការគាំទ្រផ្នែកហិរញ្ញវត្ថុពីសហភាពអឺរ៉ុបកំពុងអនុវត្តន៍គម្រោងកិច្ចសហការបច្ចេកទេសមួយគឺ "ការតាមដាន និងវាយតម្លៃវឌ្ឍនភាពស្តីពីការងារសមរម្យ" (MAP)។ គម្រោងនេះធ្វើការជាមួយស្ថាប័នរដ្ឋាភិបាល សហជីពកម្មករ និងតំណាងនិយោជក ព្រមទាំងស្ថាប័នស្រាវជ្រាវដើម្បីពង្រឹងសមត្ថភាពនៅថ្នាក់ជាតិលើការតាមដាន និងវាយតម្លៃវឌ្ឍនភាពការងារសមរម្យដោយខ្លួនឯង។ ផ្អែកលើការពិគ្រោះយោបល់ជាមួយស្ថាប័នត្រីភាគី និងអ្នកពាក់ព័ន្ធជាច្រើននៅកម្ពុជានៅខែកញ្ញា ឆ្នាំ២០០៩ ប្រទេសកម្ពុជាត្រូវបានជ្រើសរើសជាប្រទេសមួយក្នុងចំណោមប្រទេសសាកល្បងដើម្បីចូលរួមក្នុងគម្រោង MAP នៅទូទាំងពិភពលោក។

សិក្ខាសាលាបណ្តុះបណ្តាល និងពិគ្រោះយោបល់ត្រីភាគីរយៈពេលពាថ្ងៃនេះគឺជាផ្នែកមួយនៃសកម្មភាពចំបងនៃគម្រោង MAP នៅកម្ពុជា។ កិច្ចប្រជុំនេះមានអ្នកចូលរួម៦៤នាក់ ដោយរួមមានអ្នកធ្វើគោលនយោបាយមកពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងផែនការ តំណាងមកពីសហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា (CAMFEBA) និងសហជីពកម្មករជាច្រើន ព្រមទាំងអ្នកជំនាញផ្នែកស្ថិតិមកពីវិទ្យាស្ថានជាតិស្ថិតិ (NIS)។

សិក្ខាសាលាបែបចូលរួមនេះមានសកម្មភាពដូចជាកិច្ចពិភាក្សាផ្នែកបច្ចេកទេសលើការអនុវត្តសូចនាករការងារសមរម្យក្នុងការបង្កើត ការតាមដាន និងការវាយតម្លៃគោលនយោបាយ និងកម្មវិធីអភិវឌ្ឍន៍ជាតិ។ អ្នកចូលរួមបានទទួលការណែនាំផ្នែកបច្ចេកទេសអំពីសូចនាករការងារសមរម្យ និងធ្វើលំហាត់អនុវត្តន៍ជាក់ស្តែងលើការវាយតម្លៃនិន្នាការការងារសមរម្យ ដោយផ្អែកលើការវិភាគនៃការអង្កេតតាមផ្ទះ និងទិន្នន័យរដ្ឋបាល។ លើសពីនេះ សិក្ខាសាលានេះជាឱកាសមួយសម្រាប់អ្នកពាក់ព័ន្ធក្នុងការកំណត់សូចនាករការងារសមរម្យជាអាទិភាពនៅកម្ពុជា

---

[១] សូមមើល: http://www.ilo.org/global/What_we_do/Publications/Officialdocuments/lang--en/docName--WCMS_099766/index.htm.

ជាពិសេសនៅក្នុងបរិបទនៃកម្មវិធីការងារសមរម្យសម្រាប់ប្រទេសនៅកម្ពុជានាពេលខាងមុខដែលកំពុងត្រូវបានបង្កើតឡើងសម្រាប់ឆ្នាំ២០១១-២០១៥។

របាយការណ៍នេះបង្ហាញនូវសេចក្តីសង្ខេបនៃកិច្ចពិភាក្សា និងដំណើរការនៃអង្គសិក្ខាសាលា និងអាចត្រូវបានប្រើប្រាស់ជាឯកសារយោងសម្រាប់អ្នកផលិត និងអ្នកប្រើប្រាស់ស្ថិតិការងារសមរម្យ។ ខ្ញុំសង្ឃឹមថាការបន្តគំនិតផ្តួចផ្តើមបែបនេះក្នុងការពង្រឹងការប្រមូល ការវិភាគ និងការតាមដានសូចនាករការងារសមរម្យនឹងចូលរួមចំណែកធ្វើឱ្យមានគោលនយោបាយ និងកម្មវិធីល្អប្រសើរឡើងដើម្បីសម្រេចបាននូវការងារសមរម្យនៅកម្ពុជា។

Jiyuan Wang
នាយក
ការិយាល័យប្រចាំប្រទេសរបស់អង្គការពលកម្មអន្តរជាតិសម្រាប់ប្រទេសថៃ កម្ពុជា និងសាធារណៈរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

**មាតិកា**


១. មតិស្វាគមន៍ និងបើកកម្មវិធី.......... ១

១.១. សន្ទរកថាស្វាគមន៍ដោយតំណាងអង្គការពលកម្មអន្តរជាតិ.......... ១

១.២. សន្ទរកថាស្វាគមន៍ដោយតំណាងនិយោជក.......... ២

១.៣. សន្ទរកថាស្វាគមន៍ដោយតំណាងកម្មករ.......... ៣

១.៤. សន្ទរកថាបើកកម្មវិធីដោយតំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ.......... ៤

២. សម័យប្រជុំទី១: ការតាមដាននិយោជន៍ជាតិ និងគំនិតផ្តួចផ្តើមនៃការអភិវឌ្ឍ.......... ៤

២.១. ការតាមដានកម្មវិធីអភិវឌ្ឍន៍ជាតិដែលទាក់ទងនឹងការងារសមរម្យនៅកម្ពុជា.......... ៤

២.២. ប្រព័ន្ធព័ត៌មានទីផ្សារការងារជាតិកម្ពុជា.......... ៥

២.៣. កម្មវិធីការងារសមរម្យសម្រាប់ប្រទេស ឆ្នាំ២០១១-២០១៥: ដំណើរការ អាទិភាព និងលទ្ធផល ៥

២.៤. ការពិភាក្សាពេញអង្គ.......... ៦

៣. សម័យប្រជុំទី២: សាវតារស្តីពីការវាស់វែងការងារសមរម្យ.......... ៦

៣.១. ក្របខណ្ឌអង្គការ ILO ស្តីពីការវាស់វែងការងារសមរម្យ.......... ៦

៣.២. ទស្សនៈនៃការវាស់វែងការងារសមរម្យនៅកម្ពុជា.......... ៨

៣.៣. ការពិភាក្សាពេញអង្គ.......... ៩

៤. សម័យប្រជុំទី៣: ការតាមដានវឌ្ឍនភាពស្តីពីការងារសមរម្យ (១).......... ១០

៤.១. ទស្សនៈទាន និយម័យ និងការបកស្រាយ.......... ១១

៤.២. ការរៀបចំតារាងទិន្នន័យចេញពីប្រភពទិន្នន័យអង្កេតជាតិដែលមានបច្ចុប្បន្ន.......... ១២

៤.៣. ការពិភាក្សាក្រុមដើម្បីកំណត់ពីសូចនាករការងារសមរម្យថ្នាក់ជាតិតាមប្រធានបទនីមួយៗ..... ១២

៤.៣.១. កាលានុវត្តភាពការងារ.......... ១៣

៤.៣.២. ប្រាក់ឈ្នួលគ្រប់គ្រាន់ និងផលិតភាពការងារ.......... ១៥

៤.៣.៣. ម៉ោងការងារសមរម្យ ការងាររួមផ្សំ ជីវិតផ្ទាល់ខ្លួន និងគ្រួសារ ស្ថិរភាព និង សន្តិសុខការងារ.......... ១៦

៥. សម័យប្រជុំទី៤: ការតាមដានវឌ្ឍនភាពស្តីពីការងារសមរម្យ (២).......... ១៧

៥.១. ទស្សនៈទាន និយម័យ និងការបកស្រាយ.......... ១៧

៥.២. ការរៀបចំតារាងទិន្នន័យចេញពីប្រភពទិន្នន័យអង្កេតជាតិដែលមានបច្ចុប្បន្ន........................ ១៨
៥.៣. ការពិភាក្សាក្រុមដើម្បីកំណត់ពីសូចនាករការងារសមរម្យថ្នាក់ជាតិតាមប្រធានបទនីមួយៗ.... ១៩
៥.៣.១. សុវត្ថិភាពនៃបរិស្ថានការងារ.................................................................. ១៩
៥.៣.២. សន្តិសុខសង្គម........................................................................................ ២០
៥.៣.៣. សំវាទសង្គម តំណាងកម្មករ និងតំណាងនិយោជក...................................... ២១

៦. សម័យប្រជុំទី៥: ការតាមដានវឌ្ឍនភាពស្តីពីការងារសមរម្យ (៣)............................................... ២២
៦.១. ទស្សនៈទាន និយម័យ និងការបកស្រាយ..................................................................... ២២
៦.២. ការរៀបចំតារាងទិន្នន័យចេញពីប្រភពទិន្នន័យអង្កេតជាតិដែលមានបច្ចុប្បន្ន........................ ២៣
៦.៣. ការពិភាក្សាក្រុមដើម្បីកំណត់ពីសូចនាករការងារសមរម្យថ្នាក់ជាតិតាមប្រធានបទនីមួយៗ..... ២៤
៦.៣.១. ការងារដែលត្រូវលុបបំបាត់ចោល.......................................................... ២៤
៦.៣.២. សមភាពនៃកាលានុវត្តភាព និងប្រព្រឹត្តកម្មក្នុងការងារ................................ ២៥
៦.៣.៣. បរិបទសេដ្ឋកិច្ច និងសង្គមសម្រាប់ការងារសមរម្យ...................................... ២៦

៧. សម័យប្រជុំទី៦: អាទិភាពសម្រាប់គម្រោងការជាតិតាមដានការងារសមរម្យ................................. ២៨

៨. ការសម្លឹងឆ្ពោះទៅមុខ: ការពង្រឹងការសម្របសម្រួលស្ថាប័ន និងការរកអត្តសញ្ញាណវិស័យជាអាទិភាព សម្រាប់កិច្ចសហការផ្នែកបច្ចេកទេសរវាងកម្ពុជា អង្គការពលកម្មអន្តរជាតិ និងដៃគូអភិវឌ្ឍន៍............. ៣០

៩. បូកសរុបលទ្ធផល និងមតិបិទកម្មវិធី........................................................................................ ៣៣

ឧបសម្ព័ន្ធ ១: បញ្ជីឈ្មោះអ្នកចូលរួម......................................................................................... ៣៥

ឧបសម្ព័ន្ធ ២: កម្មវិធីនៃសិក្ខាសាលា.......................................................................................... ៣៨

ឧបសម្ព័ន្ធ ៣: ទិដ្ឋភាពទូទៅនៃសូចនាករការងារសមរម្យដែលស្នើឡើងដោយក្រុមការងារសម្រាប់ ការតាមដានថ្នាក់ជាតិនៅកម្ពុជា និងដោយមានបង្ហាញពីប្រភពទិន្នន័យ............................ ៤៣

# តារាង


តារាងទី ១ : សូចនាករដែលស្នើឡើងដោយក្រុមការងារសម្រាប់ "កាលានុវត្តភាពការងារ" ........ ១៤

តារាងទី ២ : សូចនាករដែលស្នើឡើងដោយក្រុមការងារសម្រាប់ "ប្រាក់ឈ្នួលគ្រប់គ្រាន់ និងផលិតភាពការងារ" ........ ១៥

តារាងទី ៣ : សូចនាករដែលស្នើឡើងដោយក្រុមការងារសម្រាប់ "ម៉ោងការងារសមរម្យ" និង "ការងាររួមផ្សំ ជីវិតផ្ទាល់ខ្លួន និងគ្រួសារ" និង "ស្ថិរភាព និងសន្តិសុខការងារ" ........ ១៧

តារាងទី ៤ : សូចនាករដែលស្នើឡើងដោយក្រុមការងារសម្រាប់ "សុវត្ថិភាពនៃបរិស្ថានការងារ" ........ ២០

តារាងទី ៥ : សូចនាករដែលស្នើឡើងដោយក្រុមការងារសម្រាប់ "សន្តិសុខសង្គម" ........ ២១

តារាងទី ៦ : សូចនាករដែលស្នើឡើងដោយក្រុមការងារសម្រាប់ "សំវាទសង្គម តំណាងកម្មករ និង តំណាងនិយោជក" ........ ២២

តារាងទី ៧ : សូចនាករដែលស្នើឡើងដោយក្រុមការងារសម្រាប់ "ការងារដែលត្រូវលុបបំបាត់ចោល" ........ ២៥

តារាងទី ៨ : សូចនាករដែលស្នើឡើងដោយក្រុមការងារសម្រាប់ "សមភាពនៃកាលានុវត្តភាព និងប្រព្រឹត្តកម្មក្នុងការងារ" ........ ២៦

តារាងទី ៩ : សូចនាករដែលស្នើឡើងដោយក្រុមការងារសម្រាប់ "បរិបទសេដ្ឋកិច្ច និងសង្គមសម្រាប់ការងារសមរម្យ" ........ ២៧

តារាងទី ១០ : សូចនាករអាទិភាពសម្រាប់ការវាស់វែងការងារសមរម្យនៅកម្ពុជាដែលត្រូវបាន កំណត់ដោយអ្នកចូលរួម........ ២៩

# បញ្ជីពាក្យបំព្រួញ និងពាក្យកាត់

| | |
|---|---|
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| ACILS | មជ្ឈមណ្ឌលអាមេរិចសម្រាប់សាមគ្គីភាពការងារអន្តរជាតិ |
| ACILS/AFL-CIO | មជ្ឈមណ្ឌលអាមេរិចសម្រាប់សាមគ្គីភាពការងារអន្តរជាតិ/សហព័ន្ធអាមេរិចសម្រាប់ការងារ-សភានៃអង្គការវិស័យឧស្សាហកម្ម |
| BWI | អង្គការកម្មករសំណង់ និងព្រៃឈើអន្តរជាតិ |
| BWTUC | សហព័ន្ធសហជីពកម្មករសំណង់ និងព្រៃឈើកម្ពុជា |
| CAMFEBA | សហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា |
| CARD | ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ |
| CCAWDU | សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា |
| CCTU | សហភាពសហព័ន្ធសហជីពជាតិកម្ពុជា |
| CCU | សហភាពសហជីពកម្ពុជា |
| CDC | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| CEDAW | អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់រើសអើងប្រឆាំងនឹងនារី |
| CIYA | សមាគមន៍យុវជនឥស្លាមកម្ពុជា |
| CLEC | មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ |
| CLS | អង្កេតពលកម្មកុមារ |
| CMDG | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា |
| CNC | សហព័ន្ធសហជីពការងារជាតិកម្ពុជា |
| CPI | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ |
| CSES | អង្កេតសេដ្ឋកិច្ច-សង្គមកម្ពុជា |
| DOCL | នាយកដ្ឋានពលកម្មកុមារ |
| DOLVT | មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| DOSH | នាយកដ្ឋានពេទ្យការងារ និងសុវត្ថិភាព |

| | |
|---|---|
| DWCP | កម្មវិធីការងារសមរម្យសម្រាប់ប្រទេស |
| DWI | សូចនាករនៃការងារសមរម្យ |
| EC | គណៈកម្មការអឺរ៉ុប |
| ESSP | កម្មវិធីគាំទ្រវិស័យអប់រំ |
| EU | សហភាពអឺរ៉ុប |
| FLD | អង្គការអភិវឌ្ឍន៍ជីវភាពកសិករ |
| GDP | ផលិតផលក្នុងស្រុកសរុប |
| GSP | ប្រព័ន្ធអនុគ្រោះពន្ធទូទៅ |
| ICLS | សន្និសិទ្ធអន្តរជាតិសម្រាប់អ្នកស្ថិតិវិទ្យាផ្នែកពលកម្ម |
| ICSE | ស្តង់ដារអន្តរជាតិនៃចំណាត់ថ្នាក់ការងារ |
| ILO | អង្គការពលកម្មអន្តរជាតិ |
| ILO/AIDS | អង្គការពលកម្មអន្តរជាតិ/គម្រោងមេរោគហ៊ីវ/ជម្ងឺអេដស៍ |
| ILO/BFC | អង្គការពលកម្មអន្តរជាតិ/គម្រោងរោងចក្រកាន់តែប្រសើរឡើងនៅកម្ពុជា |
| ILO/ITP | អង្គការពលកម្មអន្តរជាតិ/គម្រោងគាំទ្រសិទ្ធិជនជាតិដើមភាគតិចនៅកម្ពុជា |
| ILO/MDG | អង្គការពលកម្មអន្តរជាតិ/គម្រោងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ |
| ILO/SPG | អង្គការពលកម្មអន្តរជាតិ/គម្រោងកិច្ចគាំពារផ្នែកសង្គម និងយែនឌ័រ |
| ISCED | ស្តង់ដារអន្តរជាតិនៃចំណាត់ថ្នាក់ការសិក្សា |
| ISCO | ស្តង់ដារអន្តរជាតិនៃចំណាត់ថ្នាក់មុខរបរ |
| ISIC | ស្តង់ដារអន្តរជាតិនៃចំណាត់ថ្នាក់ឧស្សាហកម្ម |
| JICA | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន |
| LFS | អង្កេតកម្លាំងពលកម្ម |
| LMI | ព័ត៌មានទីផ្សារការងារ |
| LMIS | ប្រព័ន្ធព័ត៌មានទីផ្សារការងារ |
| LO/FTF | ក្រុមប្រឹក្សាសហជីពការងារសម្រាប់សហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសដាណឺម៉ាក |
| LSCW | អង្គការជំនួយផ្នែកច្បាប់សម្រាប់កុមារ និងស្ត្រី |
| MAP | គម្រោង "ការតាមដាន និងវាយតម្លៃវឌ្ឍនភាពស្តីពីការងារសមរម្យ" |

| | |
|---|---|
| MDG | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ |
| MIME | ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល |
| MOEYS | ក្រសួងអប់រំ យុវជន និងកីឡា |
| MOLVT | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| MOP | ក្រសួងផែនការ |
| MOWA | ក្រសួងកិច្ចការនារី |
| NACC | សភាសម្ព័ន្ធសហជីពជាតិកម្ពុជា |
| NEA | ទីភ្នាក់ងារជាតិមុខរបរ និងការងារ |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| NIS | វិទ្យាស្ថានជាតិស្ថិតិ |
| NSDP | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| NSSF | បេឡាជាតិរបបសន្តិសុខសង្គម |
| PC | ជំរឿនប្រជាជន |
| SNA | ប្រព័ន្ធទិន្នន័យជាតិ |
| TME | កិច្ចប្រជុំត្រីភាគីនៃអ្នកជំនាញខាងវាស់វែងការងារសមរម្យ |
| TVETM | ការគ្រប់គ្រងការអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ |
| UNAIDS | កម្មវិធីអង្គការសហប្រជាជាតិរួមគ្នាស្តីពីមេរោគហ៊ីវ/ជម្ងឺអេដស៍ |
| UNESCO | អង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌នៃអង្គការសហប្រជាជាតិ |
| WIND | គម្រោងកែលម្អការងារនៅក្នុងកម្មវិធីអភិវឌ្ឍន៍អ្នកជិតខាង |
| WISH | គម្រោងកែលម្អការងារសម្រាប់ការងារតាមផ្ទះ |

## ១. មតិស្វាគមន៍ និងបើកកម្មវិធី

*អ្នកសម្របសម្រួល: លោក ហឿង សុផុន ប្រធាននាយកដ្ឋានព័ត៌មានទីផ្សារការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ*

## ១.១. សន្ទរកថាស្វាគមន៍ដោយតំណាងអង្គការពលកម្មអន្តរជាតិ

*លោកស្រី Monica D. Castillo ប្រធានអង្គភាពផលិតកម្មទិន្នន័យនៃការងារសមរម្យ នាយកដ្ឋានស្ថិតិនៃអង្គការពលកម្មអន្តរជាតិ (ILO Geneva)*

លោកស្រី Monica បានថ្លែងអំណរគុណដល់វាគ្មិនកិត្តិយស និងបានស្វាគមន៍អ្នកចូលរួមទាំងអស់។ លោកស្រីបានបង្ហាញនូវទស្សនៈសង្ខេបពីស្ថានភាពម៉ាក្រូសេដ្ឋកិច្ចជារួមនៅទ្វីបអាស៊ី បន្ទាប់ពីវិបត្តិហិរញ្ញវត្ថុសកលលោកដែលទាក់ទងនឹងកំណើនផលិតផលក្នុងស្រុកសរុប និងស្ថានភាពទីផ្សារការងារ។ របាយការណ៍ "ស្ត្រី និងទីផ្សារការងារនៅទ្វីបអាស៊ី: ការធ្វើឱ្យមានតុល្យភាពឡើងវិញសម្រាប់សមភាពយេនឌ័រ" ឆ្នាំ២០១១របស់អង្គការ ILO-ADB បានរកឃើញថាការអភិវឌ្ឍនៅទ្វីបអាស៊ីកំពុងដឹកនាំពិភពលោកឱ្យមានការងើបឡើងវិញយ៉ាងខ្លាំងពីវិបត្តិហិរញ្ញវត្ថុសកលលោក។ ការងើបឡើងវិញនេះត្រូវបានជម្រុញដោយការប្រើប្រាស់នៃផ្នែកឯកជន កំណើនថេរនៃការវិនិយោគ និងពាណិជ្ជកម្ម។

ក៏ប៉ុន្តែ របាយការណ៍នេះក៏បានបង្ហាញផងដែរថាកំណើនសេដ្ឋកិច្ច និងការងើបឡើងវិញនេះមិនបានដូចគ្នាទៅនឹងការងើបឡើងវិញនៃទីផ្សារការងារ ហើយការប្រមើលមើលនៃការងារនៅមានភាពមិនច្បាស់លាស់។ ដូចជានៅអាស៊ីខាងកើត កំណើននៃការងារបានចាប់ផ្តើម តែគុណភាពនៃការងារនៅតែជាបញ្ហាប្រឈមមួយយ៉ាងសំខាន់។ វឌ្ឍនភាពនៃការកាត់បន្ថយការងារបានចំណូលតិចមានភាពយឺតយ៉ាវ ហើយវិសមភាពនៃយេនឌ័រក្នុងទីផ្សារការងារនៅតែកើតមានឡើង ដែលមួយផ្នែកបានឆ្លុះបញ្ចាំងពីការកើនឡើងនៃការងារក្រៅប្រព័ន្ធ និងការកើនឡើងនៃការចូលរួមរបស់ស្ត្រីក្នុងការងារក្រៅប្រព័ន្ធ។

ដូចដែលអង្គការ ILO បានកំណត់នៅឆ្នាំ១៩៩៩ ទស្សនៈទាននៃការងារសមរម្យត្រូវបានកំណត់ថាជា "កាលានុវត្តភាពសម្រាប់ស្ត្រី និងបុរសក្នុងការទទួលបានការងារសមរម្យ និងមានផលិតភាពក្នុងលក្ខខណ្ឌនៃសេរីភាព សមធម៌ សុវត្ថិភាព និងសេចក្តីថ្លៃថ្នូរនៃមនុស្សជាតិ"។ ដើម្បីសម្រេចបានការងារសមរម្យ ប្រទេសជាច្រើនបានបង្កើតកម្មវិធីការងារសមរម្យសម្រាប់ប្រទេស (DWCP) តាមរយៈដំណើរការពិគ្រោះយោបល់ត្រីភាគីដែលមានការចូលរួមពីតំណាងមកពីរដ្ឋាភិបាល ស្ថាប័នរបស់និយោជក និងស្ថាប័នរបស់កម្មករ។ កម្ពុជាជាប្រទេសមួយក្នុងចំណោមប្រទេសដំបូងជាច្រើនដែលបានបញ្ចប់ដំណាក់កាលទី១នៃ DWCP និងបច្ចុប្បន្ននេះកំពុងតែបន្តដំណាក់កាលទី២។

លោកស្រី Monica បានសង្ខេបចំណាប់អារម្មណ៍របស់លោកស្រី ដោយសង្កត់ធ្ងន់ពីសារៈសំខាន់នៃការបន្តការប្តេជ្ញាចិត្តរបស់ត្រីភាគីនៅកម្ពុជាសម្រាប់របៀបវារៈការងារសមរម្យ តាមរយៈការបង្កើត និងការតាមដាន DWCP ។ លោកស្រីបានលើកទឹកចិត្តអ្នកចូលរួមទាំងអស់ និងអ្នកផលិត និងអ្នកប្រើប្រាស់ទិន្នន័យផ្សេងទៀតឱ្យគាំទ្រដល់ដំណើរការតាមដាន DWCP នៅដំណាក់បន្ទាប់ទៀត។

## ១.២. សន្ទរកថាស្វាគមន៍ដោយតំណាងនិយោជក

*លោកស្រី Sandra D'amico អនុប្រធានសហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា (CAMFEBA)*

ក្នុងនាមលោកវ៉ាន់ ស៊ូអៀង ប្រធាន CAMFEBA លោកស្រី Sandra បានថ្លែងអំណរគុណដល់អ្នករៀបចំសិក្ខាសាលា និងអ្នកជំនាញបច្ចេកទេសដែលបានផ្តល់នូវការណែនាំសម្រាប់សូចនាករការងារសមរម្យ ដែលនឹងអាចឱ្យអ្នកពាក់ព័ន្ធនៅកម្ពុជាកំណត់បានពីសូចនាករថ្នាក់ជាតិដើម្បីគាំទ្រការបង្កើត និងការតាមដានក្របខណ្ឌអភិវឌ្ឍន៍ជាតិ និង DWCP នៅកម្ពុជា។

DWCP នៅកម្ពុជាគឺជាកិច្ចខិតខំប្រឹងប្រែងសំខាន់មួយដើម្បីកាត់បន្ថយភាពក្រីក្រ និងជាមធ្យោបាយមួយក្នុងការសម្រេចបានការអភិវឌ្ឍដែលមានសមភាព មានការដាក់បញ្ចូល និងមាននិរន្តភាព។ ដើម្បីគាំទ្រកម្មវិធីការងារសមរម្យ CAMFEBA បានដាក់ចេញនូវកិច្ចខិតខំប្រឹងប្រែងជាច្រើនដើម្បីទទួលបានធាតុចូលពីសំណាក់និយោជកដើម្បីបង្ហាញទៅដល់សមាជិក និងប្រមូលគំនិតយោបល់ពីសមាជិកត្រលប់មកវិញ។ CAMFEBA សង្ឃឹមថា DWCP នៅកម្ពុជានឹងមានលក្ខណៈច្នៃប្រឌិត និងបានជួយដោះស្រាយបញ្ហាប្រឈមនានាដូចជាការបង្កើតការងារ ការលុបបំបាត់ពលកម្មកុមារ និងទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ កិច្ចគាំពារផ្នែកសង្គម ព្រមទាំងការរួមចំណែកធ្វើឱ្យមានភាពល្អប្រសើរឡើងនៃយន្តការទំនាក់ទំនង និងការសម្របសម្រួលជាមួយដៃគូសហជីពកម្មករ និងរាជរដ្ឋាភិបាល។

គោលបំណងសំខាន់ៗនៃសិក្ខាសាលានេះរួមមានៈ

- ការបណ្តុះបណ្តាលៈ ឧបករណ៍ជាមូលដ្ឋានសម្រាប់វាយតម្លៃភាពពាក់ព័ន្ធនៃទស្សនៈទាន និងសូចនាករការងារសមរម្យនៅក្នុងបរិបទប្រទេសកម្ពុជា។
- ការជ្រើសរើសសូចនាករៈ ការកំណត់ពីសូចនាករការងារសមរម្យដែលទាក់ទងនឹងបរិបទប្រទេសកម្ពុជា និងមានបញ្ជីសម្រាំងមួយនៃសូចនាករជាអាទិភាព។
- ការកំណត់ពីយន្តការកិច្ចសហការៈ ពិនិត្យមើលឡើងវិញនូវយន្តការរវាងអ្នកផលិតទិន្នន័យការងារសមរម្យ និងអ្នកប្រើប្រាស់ទិន្នន័យដែលចាំបាច់ធ្វើឱ្យលំហូរ និងការប្រើប្រាស់ព័ត៌មានសម្រាប់ការតាមដានវឌ្ឍនភាពស្តីពីការងារសមរម្យនៅកម្ពុជាបានល្អប្រសើរឡើង។

- ការកំណត់ពីគម្លាតនៃសមត្ថភាពផ្នែកបច្ចេកទេសៈ ការពិភាក្សាក្នុងចំណោមអ្នកពាក់ព័ន្ធជាតិដើម្បីកំណត់ពីវិស័យជាអាទិភាពសម្រាប់កិច្ចសហការផ្នែកបច្ចេកទេសនាពេលអនាគតក្នុងប្រទេសកម្ពុជារវាងអង្គការ ILO និងដៃគូអភិវឌ្ឍន៍នានាដើម្បីដោះស្រាយបញ្ហាប្រឈមដែលកំពុងកើតឡើងចំពោះការវាស់វែង និងការតាមដានការងារសមរម្យនៅកម្ពុជា។

មុននឹងបញ្ចប់សន្ទរកថា លោកស្រី Sandra មានមតិបន្ថែមថា CAMFEBA នឹងបន្តគាំទ្រ DWCP នៅកម្ពុជា។ លោកស្រីបានថ្លែងអំណរគុណដល់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈដែលបានផ្តល់ឱកាសដល់តំណាងនិយោជក និងតំណាងកម្មករក្នុងការចូលរួមចំណែក និងបានថ្លែងអំណរគុណដល់អង្គការ ILO ដែលបានគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុដល់សិក្ខាសាលានេះ។

## ១.៣. សន្ទរកថាស្វាគមន៍ដោយតំណាងកម្មករ

*លោកបណ្ឌិត វង្ស សុវណ្ណ ប្រធានសហភាពសហព័ន្ធសហជីពជាតិកម្ពុជា និងតំណាងនៃសហជីពកម្មករកម្ពុជា*

លោកបណ្ឌិត វង្ស សុវណ្ណ បានសម្តែងនូវទឹកចិត្តសប្បាយរីករាយដែលត្រូវបានអញ្ជើញឱ្យចូលរួមក្នុងសិក្ខាសាលានេះ។ ការងារសមរម្យគឺជាប្រធានបទមួយដែលទាក់ទងនឹងនិន្នាការកំណើនថ្មីៗក្នុងវិស័យដូចជាឧស្សាហកម្ម កសិកម្ម សំណង់ និងទេសចរណ៍ដែលមានតម្រូវការកម្លាំងពលកម្មយ៉ាងខ្លាំង។ ស្របពេលជាមួយគ្នានេះដែរ ប្រព័ន្ធច្បាប់ជាតិបានការពារសិទ្ធិសេរីភាព និងផលប្រយោជន៍សម្រាប់កម្មករនិយោជិត។ ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នអនុសញ្ញាស្នូលរបស់អង្គការ ILO ដូចជាអនុសញ្ញាលេខ៨៧ស្តីពីសេរីភាពខាងសមាគម និងការការពារសិទ្ធិនៃការបង្កើតសមាគម និងអនុសញ្ញាលេខ៩៨ស្តីពីសិទ្ធិនៃការបង្កើត និងសិទ្ធិនៃអនុសញ្ញារួម។

ចំនួនសហជីពមានការកើនឡើង។ ដើម្បីវាស់វែងការងារសមរម្យ សូចនាករច្រើនត្រូវតែប្រើប្រាស់ដើម្បីតាមដានវិសាលភាពនៃការងារឱ្យបានទូលំទូលាយដូចជាការបង្កើតការងារថ្មី ប្រាក់ឈ្នួលសមរម្យ សុខភាពលក្ខខណ្ឌការងារដែលមានសុវត្ថិភាព ការបង្កើនជំនាញ បង្កើនផលិតភាព និងការងារបៃតង។ ប្រទេសកម្ពុជាកំពុងតែធ្វើឱ្យរីកចំរើនជាបន្តបន្ទាប់លើការងារសមរម្យ បើទោះបីជានៅតែជួបប្រទះបញ្ហាប្រឈមក៏ដោយ។ មុននឹងធ្វើការបញ្ចប់មតិ លោកបណ្ឌិត វង្ស សុវណ្ណ បានស្នើសុំឱ្យអង្គការ ILO បន្តការគាំទ្រលើការជម្រុញឱ្យការអនុវត្តកម្មវិធីការងារសមរម្យបានទៅដល់គោលដៅ។

## ១.៤. សន្ទរកថាបើកកម្មវិធីដោយតំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

*ឯកឧត្តម សាត សាមុទ្រ អនុរដ្ឋលេខាធិការនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ*

ឯកឧត្តម សាត សាមុទ្របានថ្លែងអំណរគុណដល់សហភាពអឺរ៉ុប និងអង្គការ ILO ចំពោះកិច្ចសហការផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជាជីវៈក្នុងការរៀបចំសិក្ខាសាលាដែលមានសារៈសំខាន់នេះ និងបានថ្លែងអំណរគុណដល់អ្នកចូលរួមទាំងអស់។

ការងារសមរម្យគឺជាការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីធានាថាបុរស និងស្ត្រីមានឱកាសស្មើគ្នាក្នុងការទទួលបានការងារសមរម្យ ប្រាក់ឈ្នួលសមរម្យ លក្ខខណ្ឌការងារល្អ និងសុវត្ថិភាព សេរីភាពនៃការបញ្ចេញមតិ និងសេរីភាពនៃការធ្វើសេចក្តីសម្រេចចិត្តដែលជួយសម្រួលដល់ជីវភាពរស់នៅរបស់គេ។ កន្លងមក យើងមានសូចនាករមួយចំនួនដែលភាគច្រើនបានមកពីអង្កេត និងជំរឿនពីវិទ្យាស្ថានជាតិស្ថិតិ (NIS)។ ក្រៅពីនេះ សូចនាករផ្សេងទៀតមានដូចជាសិទ្ធិនៅកន្លែងធ្វើការ កិច្ចគាំពារផ្នែកសង្គម និងសំវាទសង្គមមានប្រភពទិន្នន័យចេញពីកំណត់ត្រារដ្ឋបាលរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ហេតុនេះហើយសិក្ខាសាលានេះត្រូវធ្វើការឆ្លុះបញ្ចាំងពីចំនុចខ្វះខាតនៃសូចនាករការងារសមរម្យនៅកម្ពុជា កំណត់ពីវិស័យជាអាទិភាពសម្រាប់ការវាស់វែងការងារសមរម្យ និងរកអត្តសញ្ញាណសូចនាករថ្មី និងធ្វើការកែលម្អសូចនាករឱ្យស្របនឹងតម្រូវការជាក់ស្តែងនៃអ្នកប្រើប្រាស់ទិន្នន័យ។

ដើម្បីសម្រេចបានគោលបំណងខាងលើ ប្រទេសកម្ពុជាត្រូវតែពង្រឹងសមត្ថភាពនៃវិទ្យាស្ថានជាតិស្ថិតិ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងស្ថាប័នពាក់ព័ន្ធក្នុងការប្រមូល ចងក្រង និងវិភាគទិន្នន័យតាមរយៈជំរឿនប្រជាជន អង្កេត និងកំណត់ត្រារដ្ឋបាល។ យើងត្រូវធានាឱ្យបានថាទិន្នន័យត្រឹមត្រូវអាចជឿជាក់បាន ទៀងទាត់ និងមានវិសាលភាពពេញលេញដែលអាចយកទៅបង្កើតសូចនាករដើម្បីវាស់វែងការងារសមរម្យ និងឈានទៅធ្វើការវាយតម្លៃវឌ្ឍនភាពស្តីពីការងារសមរម្យឱ្យបានត្រឹមត្រូវ។

មុនពេលបញ្ចប់ ឯកឧត្តម សាត សាមុទ្រ បានជម្រុញឱ្យមានការចូលរួមយ៉ាងសកម្មពីសំណាក់អ្នកចូលរួមទាំងអស់ដើម្បីពង្រឹងចំណេះដឹងរបស់ខ្លួននៅក្នុងសិក្ខាសាលានេះ។ ឯកឧត្តមបានថ្លែងអំណរគុណដល់អ្នកជំនាញជាតិ និងមកពីអង្គការ ILO ចំពោះបទបង្ហាញផ្នែកបច្ចេកទេស និងការគាំទ្រដល់សិក្ខាសាលា។

# ២. សម័យប្រជុំទី១: ការតាមដាននិយោជន៍ជាតិ និងគំនិតផ្តួចផ្តើមនៃការអភិវឌ្ឍ

## ២.១. ការតាមដានកម្មវិធីអភិវឌ្ឍន៍ជាតិដែលទាក់ទងនឹងការងារសមរម្យនៅកម្ពុជា

*អ្នកធ្វើបទបង្ហាញ: លោក អ៊ឹង សុគន្ធ អនុប្រធាននាយកដ្ឋានផែនការសង្គមនៃអគ្គនាយកដ្ឋានផែនការ ក្រសួងផែនការ*

លោក អ៊ឹង សុគន្ធ បានលើកឡើងពីគោលនយោបាយ និងកម្មវិធីជាតិរបស់រាជរដ្ឋាភិបាលកម្ពុជាស្តីអំពីផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) ដែលត្រូវបានធ្វើបច្ចុប្បន្នកម្មសម្រាប់ឆ្នាំ២០០៩-២០១៣ និងការបង្កើត ការតាមដាន និងការវាយតម្លៃវឌ្ឍនភាព។ ជាមួយគ្នាផងដែរ លោកបានចាប់អារម្មណ៍ពីលក្ខខណ្ឌតម្រូវសំខាន់ៗនៃទិន្នន័យការងារសមរម្យក្នុងការតាមដាន NSDP និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (CMDG) ហើយលោកក៏បានបង្ហាញអំពីធាតុផ្សំនៃក្របខណ្ឌសូចនាករសម្រាប់ NSDP និង CMDG ដែលទាក់ទងនឹងការងារ និងការងារសមរម្យ។

## ២.២. ប្រព័ន្ធព័ត៌មានទីផ្សារការងារជាតិកម្ពុជា

*អ្នកធ្វើបទបង្ហាញៈ ឯកឧត្តម ហុង ជឿន នាយកទីភ្នាក់ងារជាតិមុខរបរ និងការងារ (NEA)*

ឯកឧត្តម ហុង ជឿន បានបង្ហាញពីទិដ្ឋភាពរួមនៃប្រព័ន្ធព័ត៌មានទីផ្សារការងារជាតិកម្ពុជា (LMIS) និងតួនាទីរបស់ NEA ដែលត្រូវបានផ្តល់អណត្តិឱ្យដោយរាជរដ្ឋាភិបាល តាមរយៈអនុក្រិតលេខ១១៧ និងអនុក្រិតលេខ៦៧។ NEA នឹងបង្កើត និងវិភាគ LMI ដែលបានមកពីអង្កេតថ្នាក់ជាតិនានា និងប្រភពកំណត់ត្រារដ្ឋបាលដែលទាក់ទងនឹងសេដ្ឋកិច្ច ប្រជាជន កម្លាំងពលកម្ម ការមានការងារធ្វើ ការគ្មានការងារធ្វើ តម្រូវការ និងការផ្គត់ផ្គង់កម្លាំងពលកម្ម ការអប់រំ និងការបណ្តុះបណ្តាល និងប្រភេទផ្សេងៗទៀត។

ការរៀបចំជាលក្ខណៈស្ថាប័នជាមួយនឹងស្ថាប័នរដ្ឋាភិបាលផ្សេងទៀតដើម្បីបង្កើត ពង្រឹង និងថែរក្សា LMIS គឺជាការងារទូលំទូលាយមួយ និងពាក់ព័ន្ធស្ថាប័នសំខាន់ៗជាច្រើនដូចជា NIS ដែលជាស្ថាប័នចំបងនៃក្រុមប្រឹក្សាយោបល់ផ្នែកស្ថិតិ និងគណៈកម្មាធិការសម្របសម្រួលផ្នែកស្ថិតិ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ផ្នែកឯកជន សហជីពកម្មករ និងអង្គការមិនមែនរដ្ឋាភិបាល (NGO)។

## ២.៣. កម្មវិធីការងារសមរម្យសម្រាប់ប្រទេស ឆ្នាំ២០១១-២០១៥: ដំណើរការ អាទិភាព និងលទ្ធផល

*អ្នកធ្វើបទបង្ហាញៈ លោក ទុន សុភ័ណ អ្នកសម្របសម្រួលជាតិរបស់អង្គការ ILO*

លោក ទុន សុភ័ណ បានបង្ហាញពីទិដ្ឋភាពរួមនៃ DWCP ឆ្នាំ២០១១-២០១៥ ជាពិសេសវិស័យជាអាទិភាព និងលទ្ធផល ព្រមជាមួយនឹងយន្តការសម្រាប់ការបង្កើត ការអនុវត្ត និងការតាមដាន។

DWCP អនុវត្តន៍នូវអភិក្រមនៃការគ្រប់គ្រងដែលផ្តោតលើលទ្ធផល និងកំពុងត្រូវបានរៀបចំឡើងក្នុងជំហ៊ានចំនួន៦គឺ:(១)កំណត់ពីបរិបទប្រទេស (២)បង្កើតអាទិភាពនៃកម្មវិធីប្រចាំប្រទេស (៣)កំណត់ពីលទ្ធផល សូចនាករ គោលដៅ និងយុទ្ធសាស្ត្រដែលចង់បាន (៤)កំណត់ពីផែនការអនុវត្តន៍ និងក្របខណ្ឌ

តាមដាន និងការវាយតម្លៃ (៥) ការអនុវត្ត និងគ្រប់គ្រងកម្មវិធី និង(៦) ការតាមដាន ការពិនិត្យមើលឡើងវិញ និងការវាយតម្លៃ។ ការអនុវត្ត DWCP ដែលទទួលបានជោគជ័យ និងសមិទ្ធិផលនៃការងារសមរម្យនៅកម្ពុជានឹងអាស្រ័យលើការចូលរួម និងសកម្មភាពត្រីភាគីរឹងមាំ។

បន្ទាប់ពីបានពិគ្រោះយោបល់ត្រីភាគីនៅថ្នាក់ជាតិស្តីពីការបង្កើត DWCP ឆ្នាំ២០១១-២០១៥ មួយចំនួនរួចមក អាទិភាព និងលទ្ធផលជាបឋមត្រូវបានកំណត់ដូចជាការកែលម្អទំនាក់ទំនងវិជ្ជាជីវៈ និងសិទ្ធិនៅកន្លែងធ្វើការ ការលើកកម្ពស់បរិយាកាសដែលបង្កលក្ខណៈងាយស្រួលដល់ការងារ និងកិច្ចគាំពារផ្នែកសង្គម។ ការតាមដាន និងការវាយតម្លៃ DWCP ក៏កំពុងត្រូវបានបង្កើតឡើង និងរួមមានរបាយការណ៍អនុវត្តន៍ និងការពិនិត្យមើលកម្មវិធីឡើងវិញនៅចុងបញ្ចប់នៃគម្រោង។

## ២.៣. ការពិភាក្សាពេញអង្គ

អ្នកចូលរួមម្នាក់បានសួរវាគ្មិនមកពីក្រសួងផែនការថា ការវាស់វែងការងារសមរម្យអាចត្រូវបានផ្សារភ្ជាប់ ឬដាក់បញ្ចូលទៅក្នុងក្របខណ្ឌតាមដាន និងវាយតម្លៃ NSDP ឬ CMDG ទេ។ វាគ្មិនបានបង្ហាញពីលទ្ធភាពក្នុងការដាក់បញ្ចូលនេះ តែបានលើកឡើងថាប្រព័ន្ធសព្វថ្ងៃមិនទាន់បានដាក់បញ្ចូលផ្នែកការងារ ឬពលកម្មឱ្យបានគ្រប់ជ្រុងជ្រោយនៅឡើយទេ។ ហេតុនេះហើយ សិក្ខាសាលានេះអាចជាឱកាសយ៉ាងសំខាន់មួយដើម្បីស្វែងរកលទ្ធភាពក្នុងការផ្សារភ្ជាប់ទំនាក់ទំនងនេះ។

# ៣. សម័យប្រជុំទី២: សាវតាស្តីពីការវាស់វែងការងារសមរម្យ

## ៣.១. គម្រោងរបស់ ILO ស្តីពីការវាស់វែងការងារសមរម្យ

*អ្នកធ្វើបទបង្ហាញ: លោកស្រី Monica D. Castillo នាយកដ្ឋានស្ថិតិ ILO Geneva*

លោកស្រី Monica បានបង្ហាញពីទស្សនៈទាននៃការងារសមរម្យដែលត្រូវបានកំណត់ថាជា "កាលានុវត្តភាពសម្រាប់ស្ត្រី និងបុរសក្នុងការទទួលបានការងារសមរម្យ និងមានផលិតភាពក្នុងលក្ខខណ្ឌនៃសេរីភាព សមធម៌ សុវត្ថិភាព និងសេចក្តីថ្លៃថ្នូរនៃមនុស្សជាតិ"។ ក្រៅពីនេះ របៀបវារៈការងារសមរម្យដែល *សេចក្តីថ្លែងការណ៍របស់អង្គការ ILO ស្តីអំពីយុត្តិធម៌សង្គមសម្រាប់សកលភាវូបនីយកម្មមួយដែលមានភាពស្មើភាពគ្នា* បានអនុម័យជាគោលបំណងចម្បងរបស់អង្គការ ILO រួមមានគោលបំណងជាយុទ្ធសាស្ត្រ៤គឺៈ (១) ស្តង់ដារពលកម្មអន្តរជាតិ និងគោលការណ៍ជាមូលដ្ឋាន និងសិទ្ធិនៅកន្លែងធ្វើការ (២) ការបង្កើតការងារ (៣) កិច្ចគាំពារផ្នែកសង្គម និង (៤) សំវាទសង្គម និងគោលការណ៍ត្រីភាគី។

ការពិភាក្សារបស់ស្ថាប័នដឹកនាំអង្គការ ILO បានកំណត់គោលការណ៍ជាមូលដ្ឋានសម្រាប់ការវាស់វែងការងារសមរម្យដើម្បីជួយអ្នកពាក់ព័ន្ធក្នុងការវាយតម្លៃវឌ្ឍនភាពស្តីពីការងារសមរម្យ និងផ្តល់នូវព័ត៌មានដែលអាចប្រៀបធៀបបានសម្រាប់ការវិភាគ និងការបង្កើតគោលនយោបាយ។ ស្ថាប័នដឹកនាំបានកំណត់ពីរាល់ទម្រង់នៃការដាក់ចំណាត់ថ្នាក់ប្រទេស ឬការបង្កើតសន្ទស្សន៍រួមផ្សំមួយ និងបានស្នើឱ្យមានការគ្របដណ្តប់គ្រប់វិសាលភាពទាំងអស់នៃការងារសមរម្យរួមទាំងសិទ្ធិ កិច្ចគាំពារផ្នែកសង្គម និងសំវាទសង្គម។

នៅខែកញ្ញា ឆ្នាំ ២០០៨ កិច្ចប្រជុំត្រីភាគីនៃអ្នកជំនាញខាងវាស់វែងការងារសមរម្យ (TME) បានផ្តល់ជាអនុសាសន៍នូវតារាងសូចនាករមួយសម្រាប់ការវាស់វែងការងារសមរម្យ ដោយរួមមានទាំងព័ត៌មានជាប្រព័ន្ធនៃសិទ្ធិនៅកន្លែងធ្វើការ និងក្របខណ្ឌច្បាប់សម្រាប់ការងារសមរម្យដែលមានលក្ខណៈស្របគ្នានឹងប្រព័ន្ធត្រួតពិនិត្យរបស់អង្គការ ILO។ ជាមួយគ្នានោះដែរ TME បានទទួលស្គាល់ថាយែនឌ័រដែលជាការព្រួយបារម្ភអន្តរវិស័យនៃរបៀបវារៈការងារសមរម្យ និងការវាស់វែងគួរតែមានព័ត៌មានអំពីលទ្ធភាពនៃការងារសមរម្យនៃគ្រប់ធាតុផ្សំសំខាន់៧សម្រាប់ស្ត្រី និងបុរស។

លើសពីនេះ អាភិក្រមច្រើនស្រទាប់គួរតែត្រូវបានប្រើប្រាស់សម្រាប់សូចនាករដែលត្រូវបានប្រើប្រាស់ក្នុងការវាស់វែងការងារសមរម្យដូចខាងក្រោម:

- សូចនាករសំខាន់: បញ្ជីស្នូលជាមូលដ្ឋាននៃសូចនាករដើម្បីតាមដានវឌ្ឍនភាពនៃការងារសមរម្យ។
- សូចនាករបន្ថែម: ត្រូវបានប្រើប្រាស់ នៅពេលដែលចាំបាច់ និងពេលដែលមានទិន្នន័យ។
- សូចនាករបរិបទ: ដើម្បីផ្តល់ព័ត៌មានអំពីបរិបទសេដ្ឋកិច្ច និងសង្គមសម្រាប់ការងារសមរម្យ។
- សូចនាការនាពេលអនាគត: បច្ចុប្បន្ននេះមិនមានទេ តែត្រូវបានដាក់បញ្ចូល ដោយសារទិន្នន័យអាចងាយស្រួលស្វែងរកបាន។
- សូចនាករក្របខណ្ឌច្បាប់: ព័ត៌មានដែលមាននៅក្នុងក្របខណ្ឌច្បាប់។

យើងឃើញមានភាពជាន់គ្នានៃសូចនាករ DWI និង MDG តែ DWI មានលក្ខណៈទូលំទូលាយជាងក្នុងការគ្របដណ្តប់បញ្ហាទីផ្សារការងារ និងអាចបំពេញបន្ថែមលើសូចនាករ MDG ក្នុងការវាស់វែងវឌ្ឍនភាពនៃការកាត់បន្ថយភាពក្រីក្រ ការងារសមរម្យ និងការអនុវត្តកម្មវិធីការងារសមរម្យសម្រាប់ប្រទេស។ លើសពីនេះ អ្នកពាក់ព័ន្ធត្រីភាគីអាចប្រើប្រាស់ DWI ដើម្បីតាមដានការអនុវត្តផែនការអភិវឌ្ឍន៍ជាតិ និងទាញបានមេរៀនគោលនយោបាយ។

## ៣.២. ទស្សនៈនៃការវាស់វែងការងារសមរម្យនៅកម្ពុជា

*អ្នកធ្វើបទបង្ហាញ: លោក Phu Huynh, ILO/EC MAP, ILO Bangkok*

លោក Huynh បានបង្ហាញពីទស្សនៈទាននៃការងារសមរម្យក្នុងបរិបទនៃប្រទេសកម្ពុជាដែលមានលក្ខណៈ (១) កំណើនសេដ្ឋកិច្ចឆាប់រហ័ស និងការប្រែក្លាយរចនាសម្ព័ន្ធ (២) កំណើនឱកាសការងាររឹងមាំ តែគុណភាពការងារនៅតែជាការព្រួយបារម្ភ (៣) ការកើនឡើងនៃសារៈសំខាន់នៃកិច្ចគាំពារផ្នែកសង្គម និងសុវត្ថិភាព និងសុខភាពនៅកន្លែងធ្វើការ (៤) ប្រព័ន្ធទំនាក់ទំនងវិជ្ជាជីវៈដែលកំពុងកើនឡើង និង (៥) ក្រុមងាយរងគ្រោះដែលមានរួមមានស្ត្រី កុមារ និងជនពិការជាដើម។ DWCP ឆ្នាំ២០០៦-២០១០ និងគម្រោងកិច្ចសហការផ្នែកបច្ចេកទេសជាច្រើនរបស់អង្គការ ILO មានគោលបំណងគាំទ្រកម្ពុជាដើម្បីដោះស្រាយបញ្ហាប្រឈមក្នុងការងារសមរម្យទាំងអស់នេះ។

ប្រព័ន្ធស្ថិតិជាតិសម្រាប់ការវាស់វែងការងារសមរម្យពាក់ព័ន្ធនឹងប្រភពទិន្នន័យជាច្រើន និងអ្នកផលិត និងអ្នកប្រើប្រាស់ទិន្នន័យ។ ធាតុផ្សំទាំងនេះរួមមានការអង្កេតតាមផ្ទះ និងសហគ្រាស និងជំរឿនដែលអនុវត្តន៍ដោយ NIS និងកំណត់ត្រារដ្ឋបាលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសុខាភិបាល។ បច្ចុប្បន្ននេះ យោងតាមក្របខណ្ឌអង្គការ ILO DWI មួយចំនួនអាចត្រូវបានប្រមូលពីប្រភពដែលមានស្រាប់។ ក៏ប៉ុន្តែ ចន្លោះប្រហោងនៅតែមានចំពោះវិសាលភាពនៃទិន្នន័យទាំងនោះ។ ជាឧទាហរណ៍ អង្កេតកម្លាំងពលកម្ម និងអង្កេតពលកម្មកុមារចុងក្រោយត្រូវបានធ្វើឡើងនៅឆ្នាំ២០០១។

សរុបមកវិញ បញ្ហាប្រឈមចម្បងៗនៃការវាស់វែងការងារសមរម្យនៅកម្ពុជារួមមានៈ

- ចន្លោះប្រហោងនៃព័ត៌មានសំខាន់លើវិស័យជាអាទិភាពនៃការងារសមរម្យៈ ការងារក្រៅប្រព័ន្ធ និងការងារប្រកបដោយគ្រោះថ្នាក់ ការបណ្តុះបណ្តាលជំនាញ និងសមត្ថភាព ការគ្របដណ្តប់ផ្នែកសុវត្ថិភាពសង្គម អត្រាគ្របដណ្តប់នៃសហជីព និងអនុសញ្ញារួម និងពលកម្មកុមារ។
- ក្នុងករណីខ្លះ គេមានទិន្នន័យ តែសូចនាករមិនអាចដាក់ក្នុងតារាងបាន បើយោងតាមស្តង់ដារអន្តរជាតិ។
- ឧបសគ្គផ្នែកធនធានបានរារាំងមិនឱ្យមានការអង្កេតថ្មីៗ និងស៊េរីនៃពេលវេលាមិនពេញលេញសម្រាប់ការតាមដាននិន្នាការ និងការប្រៀបធៀបមូលដ្ឋានគោល។
- ខ្វះខាតយន្តការសម្របសម្រួលស្ថាប័នថ្នាក់ជាតិក្នុងចំណោមអ្នកផលិត និងអ្នកប្រើប្រាស់ទិន្នន័យសំខាន់ៗលើការប្រមូល ការវិភាគ និងការតាមដាន DWI។

ជាការឆ្លើយតបទៅនឹងបញ្ហាទាំងនេះនៅកម្ពុជា និងការប្រឈមដូចគ្នានេះនៅប្រទេសផ្សេងៗទៀត អង្គការ ILO កំពុងអនុវត្តន៍គម្រោង ILO/EC "ការតាមដាន និងវាយតម្លៃវឌ្ឍនភាពស្តីពីការងារសមរម្យ" (MAP) ។ គម្រោង MAP អនុវត្តន៍នៅប្រទេសចំនួន១០នៅទូទាំងសកលលោកដូចជាបង់ក្លាដេស កម្ពុជា ឥណ្ឌូណេស៊ី និងហ្វីលីពីននៅទ្វីបអាស៊ី។ គម្រោងនេះនឹងត្រូវអនុវត្តន៍ចាប់ពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១២ ដើម្បីពង្រឹងសមត្ថភាពរបស់ប្រទេសទាំងនោះលើការតាមដានវឌ្ឍនភាពនៃការងារសមរម្យដោយខ្លួនឯង។

សកម្មភាពគម្រោងនៅកម្ពុជារួមមានការសិក្សាពីសាវតារ និងសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិស្តីពីការវាស់វែងការងារសមរម្យ ការគាំទ្រដល់កម្ពុជាដើម្បីរៀបចំអង្កេតពលកម្មរួមបញ្ចូលគ្នាជាមួយការអង្កេតពលកម្មកុមារនៅឆ្នាំ២០១១/២០១២ ការបង្កើតឯកសារប្រចាំប្រទេសស្តីពីការងារសមរម្យនៅកម្ពុជា និងសិក្ខាសាលាបណ្តុះបណ្តាលថ្នាក់តំបន់ និងអន្តរជាតិមួយចំនួនទៀតដែលទាក់ទងនឹងការតាមដានការងារសមរម្យ។

## ៣.៣. ការពិភាក្សាពេញអង្គ

អ្នកចូលរួមម្នាក់មកពីអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកបានកត់សម្គាល់ថានៅកម្ពុជាចំនួនអ្នកស្វែងរកការងារមានច្រើនជាងចំនួនការងារថ្មី និងបានសួរថាអ្វីទៅជាការបង្កើតការងារ និងថាការងារអ្វីខ្លះដែលកំពុងត្រូវបានបង្កើតឡើង។

ឯកឧត្តម ហុង ជឿន មកពី NEA បានគូសបញ្ជាក់ថា រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាបានចែងពីឱកាសស្មើគ្នាសម្រាប់ពលរដ្ឋទាំងអស់។ បើទោះបីជាមានគោលនយោបាយបែបនេះយ៉ាងណាក៏ដោយ តាមភាពជាក់ស្តែង មានកត្តាជាច្រើនដែលបានរាំងខ្ទប់ការងារនៃគោលនយោបាយទាំងនេះ។ យើងត្រូវតែពិចារណាមើលអំពីការផ្គត់ផ្គង់ និងតម្រូវការការងារនៅក្នុងទីផ្សារការងារ ព័ត៌មានលម្អិតអំពីការងារដែលមានលក្ខណៈសម្បត្តិតម្រូវ ដើម្បីបំពេញតាមលក្ខខណ្ឌទាមទាររបស់និយោជក។ ហេតុដូច្នេះហើយ NEA ត្រូវបានបង្កើតឡើងដោយមានតួនាទីចម្បង២គឺ: (១) ផ្តល់សេវាកម្មការងារតាមរយៈការផ្តល់នូវការប្រឹក្សាយោបល់ និងការណែនាំមុខជំនាញ និង (២) មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈនៅភ្នំពេញ និងតាមខេត្តមួយចំនួនសម្រាប់អ្នកដែលមិនអាចធ្វើដំណើរមកទីក្រុងបាន។

លោកស្រី Monica បានកត់សម្គាល់ពីសារៈសំខាន់នៃការមានអង្កេតកម្លាំងពលកម្មញឹកញាប់ដើម្បីស្វែងយល់អំពីលក្ខណៈសម្បត្តិ និងនិន្នាការនៃទីផ្សារការងារ។ ទាក់ទងនឹងការងារសមរម្យ វាមានសារៈសំខាន់ក្នុងការក្រឡេកមើលទាំងអ្នកគ្មានការងារធ្វើ និងទាំងអ្នកធ្វើការងារមិនពេញលេញក្នុងករណីដូចជាម៉ោងការងារ និងជំនាញជាដើម។ ការធ្វើការងារមិនពេញលេញគឺជាបញ្ហាប្រឈមសំខាន់ និងទូទៅមួយនៅប្រទេសកំពុងអភិវឌ្ឍន៍ដូចជាកម្ពុជា។ អាស្រ័យហេតុនេះ យើងត្រូវការទិន្នន័យថ្មីៗដើម្បីដឹងថាមានមនុស្សប៉ុន្មាននាក់

ដែលបានពាក់ព័ន្ធនឹងការធ្វើការងារមិនពេញលេញដើម្បីដោះស្រាយបញ្ហានេះ ។ ព័ត៌មាននេះអាចត្រូវបានបំពេញបន្ថែមដោយលទ្ធផលនៃជំរឿនសហគ្រាសកម្ពុជាឆ្នាំ២០១១ ក្រៅពីអង្កេតសហគ្រាស និងកំណត់ត្រារដ្ឋបាលដែលបានតាមដានចំនួនអ្នកស្វែងរកការងារធ្វើ និងលក្ខខណ្ឌការងារ ។

អ្នកចូលរួមម្នាក់មកពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានសុំឱ្យបកស្រាយពីនិយមន័យនៃសូចនាករ "អត្រាដង់ស៊ីតេសហជីព" ។ ជាការឆ្លើយតប លោកស្រី Monica បានផ្តល់នូវនិយមន័យលក្ខណៈស្ថិតិ និងរូបមន្តសម្រាប់ការវាស់វែងរបស់វា និងបាននិយាយថាសម័យប្រជុំទី៤នឹងមានការពិភាក្សាបន្ថែមទៀតអំពីសូចនាករនេះ ។

អ្នកចូលរួមម្នាក់មកពីអង្គការ ILO បានស្នើសុំព័ត៌មានបន្ថែមទៀតពីជំរឿនសហគ្រាសកម្ពុជាឆ្នាំ២០១១ ។ NIS បានពន្យល់ថាជំរឿនសហគ្រាសត្រូវបានរៀបចំឡើងដោយមានជំនួយពីអង្គការ JICA ។ ការងារប្រមូលទិន្នន័យបានបញ្ចប់រួចហើយ ។ ឥឡូវនេះ យើងកំពុងតែបញ្ចូលទិន្នន័យ និងដាក់លេខកូដ ។ លទ្ធផលបឋមអាចនឹងត្រូវបានផ្សព្វផ្សាយនៅដើមឆ្នាំក្រោយ ។

អ្នកចូលរួមម្នាក់ទៀតបានសុំឱ្យមានការពន្យល់បន្ថែមអំពីភាពខុសគ្នារវាងវិស័យក្រៅប្រព័ន្ធ និងការងារក្រៅប្រព័ន្ធ ។ លោកស្រី Monica បានធ្វើការឆ្លើយតបថាវិស័យក្រៅប្រព័ន្ធទាក់ទងនឹងលក្ខណៈនៃសហគ្រាស បើនិយាយអំពីការចុះឈ្មោះជាផ្លូវការ ប្រព័ន្ធគណនេយ្យ និងការកត់ត្រាបញ្ជីជាដើម ។ ចំណែកឯការងារក្រៅប្រព័ន្ធកើតឡើងទាំងក្នុងសហគ្រាសក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ ។ ការងារក្រៅប្រព័ន្ធជានិច្ចជាកាលមិនអាស្រ័យលើថាតើការងារនោះស្ថិតនៅក្នុងសហគ្រាសក្រៅប្រព័ន្ធទេ ។ ឧទាហរណ៍ សហគ្រាសអាចចុះបញ្ជីតែក្នុងការអនុវត្ត សហគ្រាសនោះនៅតែអាចជួលកម្មករដែលអាចមានលក្ខខណ្ឌមិនស្ថិតក្រោមច្បាប់ដូចជាការរួមចំណែកក្នុងសុវត្ថិភាពសង្គម ការឈប់សម្រាកប្រចាំឆ្នាំ និងអត្ថប្រយោជន៍តាមច្បាប់ផ្សេងទៀត ។ ដូច្នេះ ការងារក្រៅប្រព័ន្ធទាក់ទងនឹងលក្ខណៈនៃការងារ ជាជាងសហគ្រាស ។

ជាចុងក្រោយ មន្ត្រីម្នាក់ទៀតមកពី NIS បានលើកឡើងថា Economic Census អាចត្រូវបានហៅថា Establishment Census ដោយសារតែបញ្ជីសំនួរបានគ្របដណ្តប់សហគ្រាសទាំងអស់ លើកលែងតែអ្វីដែលទាក់ទងនឹងផលិតកម្មកសិកម្ម ។ NIS មានផែនការធ្វើជំរឿនកសិកម្មនាពេលអនាគតផងដែរ ។

## ៤. សម័យប្រជុំទី៣: ការតាមដានវឌ្ឍនភាពស្តីពីការងារសមរម្យ (១)

- កាលានុវត្តភាពការងារ
- ប្រាក់ឈ្នួលគ្រប់គ្រាន់ និងផលិតភាពការងារ
- ម៉ោងការងារសមរម្យ
- ការងាររួមផ្សំ ជីវិតផ្ទាល់ខ្លួន និងគ្រួសារ

- ស្ថិរភាព និងសន្តិសុខការងារ

## ៤.១. ទស្សនៈទាន និយមន័យ និងការបកស្រាយ

*អ្នកធ្វើបទបង្ហាញ: លោកស្រី Monica D. Castillo នាយកដ្ឋានស្ថិតិ ILO Geneva*

លោកស្រី Monica បានបង្ហាញពីទិដ្ឋភាពរួមនៃសាវតារ និងស្តង់ដារអន្តរជាតិនៃប្រព័ន្ធទិន្នន័យជាតិ (SNA) ស្តង់ដារអន្តរជាតិនៃចំណាត់ថ្នាក់ឧស្សាហកម្ម (ISIC) ស្តង់ដារអន្តរជាតិនៃចំណាត់ការងារ (ICSE) ស្តង់ដារអន្តរជាតិនៃចំណាត់ថ្នាក់ការសិក្សា (ISCED) ស្តង់ដារអន្តរជាតិនៃចំណាត់ថ្នាក់មុខរបរ (ISCO) ។

បន្ទាប់មក លោកស្រីបានបង្ហាញពីនិយមន័យ ទស្សនៈទាន និងការបកស្រាយលម្អិតលើសូចនាករការងារសមរម្យនីមួយៗតាមធាតុផ្សំសំខាន់ៗដូចជា:

១) កាលានុវត្តភាពការងារ

- អនុបាតនៃចំនួនអ្នកមានការធ្វើធៀបជាមួយនឹងចំនួនប្រជាជន (S)
- អត្រាគ្មានការងារធ្វើ (S)
- យុវជនមិនបានចូលរៀន និងគ្មានការងារធ្វើ (S)
- ការងារក្រៅប្រព័ន្ធ (S)

២) ប្រាក់ឈ្នួលគ្រប់គ្រាន់ និងផលិតភាពការងារ

- អត្រាការងារបានចំណូលតិច (S)
- អត្រាផ្តល់ប្រាក់ទាប (ក្រោម២/៣នៃសមឌ្ឍរេខាប្រាក់ឈ្នួលក្នុង១ម៉ោង) (S)

៣) ម៉ោងការងារសមរម្យ

- ម៉ោងធ្វើការហួសប្រមាណ (ច្រើនជាង៤៨ម៉ោងក្នុង១សប្តាហ៍) (S)

៤) ការងាររួមផ្សំ ជីវិតផ្ទាល់ខ្លួន និងគ្រួសារ

៥) ស្ថិរភាព និងសន្តិសុខការងារ

- អត្រាការងារប្រកដោយគ្រោះថ្នាក់ (S)

ក្នុងករណីបើអាចធ្វើបាន សេចក្តីសម្រេចពីសន្និសិទ្ធអន្តរជាតិសម្រាប់អ្នកស្ថិតិវិទ្យាផ្នែកពលកម្ម (ICLS) ត្រូវបានបង្ហាញជាព័តិមានយោងបន្ថែមទៅកាន់អ្នកចូលរួម ។

## ៤.២. ការរៀបចំតារាងទិន្នន័យចេញពីប្រភពទិន្នន័យអង្កេតជាតិដែលមានបច្ចុប្បន្ន

*អ្នកធ្វើបទបង្ហាញ: លោក ហ៊ាង កាណុល អគ្គនាយករងនៃវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ*

លោក ហ៊ាង កាណុល បានបង្ហាញពីទិដ្ឋភាពរួមនៃវិទ្យាស្ថានជាតិស្ថិតិដូចជាអណត្តិផ្លូវការនៅក្នុងរាជរដ្ឋាភិបាលកម្ពុជា ការទទួលខុសត្រូវ និងទំហំនៃសិទ្ធិអំណាច។ NIS បានធ្វើអង្កេត និងជំរឿនមួយចំនួនដែលអាចត្រូវបានប្រើប្រាស់ដើម្បីវាស់វែងការងារសមរម្យ។ ជាពិសេស DWI អាចត្រូវបានប៉ាន់ប្រមាណដោយផ្អែកលើមូលដ្ឋាននៃទិន្នន័យដែលមានស្រាប់ពី (១)ជំរឿនប្រជាជនឆ្នាំ១៩៩៨ និងឆ្នាំ២០០៨ (២)អង្កេតសេដ្ឋកិច្ច-សង្គមឆ្នាំ២០០៤ ឆ្នាំ២០០៧ និងឆ្នាំ២០០៩ (៣)អង្កេតពលកម្មកុមារឆ្នាំ២០០១ និង(៤)អង្គការអន្តរជាតិដូចជាវិទ្យាស្ថានស្ថិតិនៃអង្គការ UNESCO អង្គការ UNAIDS អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ និងធនាគារពិភពលោក។

តារាង DWI ដែលត្រូវបានរៀបចំដោយ NIS បានមកពីជំរឿនប្រជាជន (ឆ្នាំ១៩៩៨ និងឆ្នាំ២០០៨) និងអង្កេតសេដ្ឋកិច្ច-សង្គមកម្ពុជា (ឆ្នាំ២០០៤ និងឆ្នាំ២០០៩) ដែលមាននៅក្នុងធាតុផ្សំសំខាន់៧ដែលពាក់ព័ន្ធត្រូវបានលើកយកមកបង្ហាញ។ បន្ថែមពីលើនេះ metadata ត្រូវបានពន្យល់ដើម្បីជួយអ្នកចូលរួមឱ្យធ្វើការបកស្រាយឱ្យបានល្អប្រសើរចំពោះភាពមានកម្រិតនៃតារាងទិន្នន័យ។

## ៤.៣. ការពិភាក្សាក្រុមដើម្បីកំណត់ពីសូចនាករការងារសមរម្យថ្នាក់ជាតិតាមប្រធានបទនីមួយៗ

*អ្នកសម្របសម្រួល: លោក ហឿង សុផុន ប្រធាននាយកដ្ឋានព័ត៌មានទីផ្សារការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ*

បន្ទាប់ពីបទបង្ហាញលក្ខណៈបច្ចេកទេសចំនួនពីររួចមក អ្នកចូលរួមទាំងអស់ត្រូវបានបែងចែកជាបីក្រុមសម្រាប់ការពិភាក្សាតាមប្រធានបទ។ ក្រុមនីមួយៗមានតំណាងមកពីត្រីភាគីដូចជាមកពីរដ្ឋាភិបាល ស្ថាប័ននិយោជក និងសហជីពកម្មករ ក្រៅពីអ្នកចូលរួមមកពីអង្គការមិនមែនរដ្ឋាភិបាល និងអង្គការអន្តរជាតិ។ ក្រុមនីមួយៗមានប្រធានក្រុមម្នាក់ អ្នកកត់ត្រាម្នាក់ និងអ្នកធ្វើបទបង្ហាញម្នាក់។ លើសពីនេះ ក្រុមនីមួយៗមានអ្នកជំនាញបច្ចេកទេសយ៉ាងតិចម្នាក់មកពីអង្គការពាក់ព័ន្ធដូចជា NIS ឬអង្គការ ILO ដើម្បីជួយ និងជម្រុញឱ្យមានភាពសកម្មក្នុងការពិភាក្សាក្រុម និងការចូលរួម។

ក្រុមនីមួយៗមានលំហាត់ពីរផ្នែក។ ផ្នែកទី១នៃលំហាត់គឺការវិភាគតារាងទិន្នន័យនៃ DWI និងឆ្លើយសំនួរដូចខាងក្រោម:

១) សម្រាប់សូចនាករទាំងនេះ តើនិន្នាការជាគន្លឹះណាដែលបានកើតមានឡើងក្នុងកំឡុងពេលស៊េរីទិន្នន័យដែលបានផ្តល់ឱ្យ? សូមលើកយកគោលសំខាន់នៃនិន្នាការដោយឡែកណាសម្រាប់ទិន្នន័យដែលបែងចែកតាម ( ប្រុស/ស្រី ទីប្រជុំជន/ទីជនបទ) ។

២) តើគោលនយោបាយជាតិ កម្មវិធី និងច្បាប់ ឬកត្តាអន្តរជាតិណាដែលអាចមានឥទ្ធិពលលើនិន្នាការទាំងអស់នេះ?

៣) តើការវាយតម្លៃសង្ខេបរបស់អ្នកយ៉ាងដូចម្តេចចំពោះវឌ្ឍនភាព ឬការផ្លាស់ប្តូរដែលកើតមានឡើងសម្រាប់សូចនាករនីមួយៗ?

៤) តើសូចនាករការងារសមរម្យផ្សេងណាទៀតដែលអាចជួយឱ្យអ្នកវិភាគបន្ថែមនូវសូចនាករទាំងអស់នេះ?

សម្រាប់ផ្នែកទី២ ក្រុមនីមួយៗពិនិត្យមើលបញ្ជី DWI ដែលត្រូវបានស្នើឡើង និងជម្រុញដោយអង្គការ ILO និងឆ្លើយសំនួរដូចខាងក្រោម:

១) ចំពោះអាទិភាពអភិវឌ្ឍន៍នៃប្រទេសកម្ពុជាលើការងារសមរម្យ តើសូចនាករណាមួយក្នុងចំណោមធាតុផ្សំសំខាន់ៗនៃការងារសមរម្យគួរត្រូវបានអនុម័តជាសូចនាករការងារសមរម្យសម្រាប់កម្ពុជា?

២) តើមានសូចនាករណាដែលទាក់ទងនឹងធាតុផ្សំសំខាន់ៗនៃការងារសមរម្យនេះមិនត្រូវបានដាក់បញ្ចូលក្នុងបញ្ជីរបស់អង្គការ ILO ដែលអ្នកអាចនឹងស្នើឡើងសម្រាប់ប្រទេសកម្ពុជា?

## ៤.៣.១. ការលានុវត្តភាពការងារ

សមាជិកនៅក្នុងក្រុមការងារសម្រាប់ប្រធានបទ "ការលានុវត្តភាពការងារ "" រួមមានមន្ត្រីរដ្ឋាភិបាល ១០នាក់ មន្ត្រីអង្គការ ILO ៤នាក់ តំណាងកម្មករ២នាក់ តំណាងនិយោជកម្នាក់ និងតំណាង NGO ម្នាក់ ។

ក្រុមនេះបានលើកឡើងអំពីការកើនឡើងនៃអនុបាតនៃចំនួនអ្នកមានការងារធ្វើធៀបជាមួយចំនួនប្រជាជនចាប់ពីឆ្នាំ២០០៤ ដល់ឆ្នាំ២០០៩ ជាពិសេសស្ត្រី ។ លើសពីនេះ យើងឃើញមានការថយចុះជាវិជ្ជមាននៃអ្នកប្រកបអាជីវកម្មប្រើទុនផ្ទាល់ខ្លួន និងអ្នកធ្វើការឱ្យគ្រួសារមិនគិតប្រាក់ឈ្នួលនៅក្នុងចំនួនអ្នកមានការងារធ្វើទាំងអស់សម្រាប់ទាំងបុរស និងស្ត្រី ។ គោលនយោបាយមួយចំនួនដែលអាចមានឥទ្ធិពលលើនិន្នាការនេះរួមមាន: ១) ការពង្រីកការងារក្នុងប្រព័ន្ធក្នុងវិស័យផលិតកម្ម ២) ការលើកលែងពន្ធនាំចេញសម្រាប់ផលិតផលសំលៀកបំពាក់ដែលអាចធ្វើឱ្យវិស័យនេះមានការរីកចម្រើន និង ៣) បង្កើនចំនួនកម្មករធ្វើការនៅបរទេស ។

ក្រុមនេះបានឯកភាពលើសូចនាករទាំង១០ដែលស្នើឡើងដោយក្របខណ្ឌអង្គការ ILO ដែលគួរតែត្រូវបានអនុម័តយល់ព្រមសម្រាប់ការតាមដានថ្នាក់ជាតិនៅកម្ពុជា ។ ក្នុងនោះផងដែរ ក្រុមបានស្នើឡើង

សូចនាករថ្មី២គឺ "និស្សិតមានការងារធ្វើបន្ទាប់ពីវគ្គបណ្តុះបណ្តាល/ការសិក្សា" និង "កម្មករនៅក្នុងសហគ្រាសខ្នាតតូចក្នុងវិស័យក្រៅប្រព័ន្ធ"។ ជាចុងក្រោយ ក្រុមបានកត់សម្គាល់ពីសារៈសំខាន់នៃការតាមដានអ្នកមានការងារដែលមានប្រាក់ឈ្នួលទាប និងអង្កេតពីចំនួននិស្សិតដែលបានបញ្ចប់ការបណ្តុះបណ្តាល/ការអប់រំក្នុងប្រព័ន្ធ ប៉ុន្តែមិនអាចស្វែងរកការងារធ្វើបាន។

**តារាង១**

**តារាងទី ១ : សូចនាករដែលស្នើឡើងដោយក្រុមការងារសម្រាប់ "កាលានុវត្តភាពការងារ"**

| សូចនាករ សម្គាល់ | សូចនាករ M = សូចនាករសំខាន់ A = សូចនាករបន្ថែម C = សូចនាករបរិបទ (គ្រប់សូចនាករដែលសម្គាល់ដោយ 'S' ត្រូវបែងចែកតាមភេទ) |
|---|---|
| EMPL-1 | M – អនុបាតនៃចំនួនអ្នកមានការងារធ្វើធៀបជាមួយចំនួនប្រជាជន អាយុ១៥ឆ្នាំឡើង (S) |
| EMPL-2 | M – អត្រាគ្មានការងារធ្វើ (S) |
| EMPL-3 | M – យុវជនមិនបានចូលរៀន និងគ្មានការងារធ្វើ អាយុ១៥-២៤ឆ្នាំ (S) |
| EMPL-4 | M – អ្នកមានការងារធ្វើក្នុងវិស័យក្រៅប្រព័ន្ធ (S) |
| EMPL-5 | A –អត្រាចូលរួមក្នុងកម្លាំងពលកម្ម អាយុ១៥ឆ្នាំឡើង |
| EMPL-6 | A –អត្រាគ្មានការងារធ្វើរបស់យុវជន អាយុ១៥-២៤ឆ្នាំ (S) |
| EMPL-7 | A –អ្នកគ្មានការងារធ្វើតាមកម្រិតនៃការសិក្សា (S) |
| EMPL-8 | A –អ្នកមានការងារធ្វើតាមស្ថានភាពក្នុងការងារ (S) |
| EMPL-9 | A – សមាមាត្រនៃអ្នកប្រកបអាជីវកម្មប្រើទុនផ្ទាល់ខ្លួន និងអ្នកធ្វើការឱ្យគ្រួសារមិនគិតប្រាក់ឈ្នួលនៅក្នុងចំនួនអ្នកមានការងារធ្វើទាំងអស់ (S) |
| EMPL-10 | A – ចំណែកនៃប្រាក់ឈ្នួលនៅក្នុងការងារមិនមែនកសិកម្ម (S) |
| n/a | A – អាត្រានិស្សិតមានការងារធ្វើបន្ទាប់ពីវគ្គបណ្តុះបណ្តាល/ការសិក្សា* |
| n/a | A – កម្មករនៅក្នុងសហគ្រាសខ្នាតតូចនៅក្នុងវិស័យក្រៅប្រព័ន្ធ* |

សម្គាល់: សូចនាករដែលលេខសូចនាករសម្គាល់ដកស្រង់ចេញពីក្របខណ្ឌកិច្ចប្រជុំត្រីភាគីនៃអ្នកជំនាញខាងវាស់វែងការងារសមរម្យ។ រីឯសូចនាករដែលមានសញ្ញា(*) មានលក្ខណៈជាក់លាក់ ឬត្រូវបានកែសម្រួលសម្រាប់កម្ពុជា។ ប្រភព: ការដកស្រង់ពីដំណើរការសិក្ខាសាលា។

## ៤.៣.២. ប្រាក់ឈ្នួលគ្រប់គ្រាន់ និងផលិតភាពការងារ

សមាជិកនៅក្នុងក្រុមការងារសម្រាប់ប្រធានបទ "ប្រាក់ឈ្នួលគ្រប់គ្រាន់ និងផលិតភាពការងារ "រួមមានមន្ត្រីរដ្ឋាភិបាល៨នាក់ មន្ត្រីអង្គការ ILO ៥នាក់ តំណាងនិយោជកម្នាក់ តំណាងកម្មករ៣នាក់ និងតំណាង NGO ម្នាក់។

ក្រុមនេះបានពិភាក្សាអំពីការកើនឡើងនៃប្រាក់ឈ្នួល តែបានសង្កត់ធ្ងន់លើការធ្លាក់ចុះអំណាចនៃការទិញដោយសារតែ CPI បន្តកើនឡើង បណ្តាលមកពីការនាំចូលទំនិញប្រើប្រាស់ វិបត្តិស្បៀងអាហារ និងវិបត្តិសេដ្ឋកិច្ច។ ប្រាក់ឈ្នួលសម្រាប់បុរសខ្ពស់ជាងស្ត្រីដែលបង្ហាញឱ្យឃើញពីឱកាសនៃការអប់រំ និងការធ្វើដំណើរ និងទំនៀមទម្លាប់សង្គម និងការរើសអើង។ យើងឃើញមានការថយចុះនៃអត្រាផ្តល់ប្រាក់ទាបចាប់ពីឆ្នាំ២០០៤ ដល់ឆ្នាំ២០០៩។ គោលនយោបាយ និងកម្មវិធីជាតិដែលអាចមានឥទ្ធិពលលើនិន្នាការនេះរួមមានយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល និងកម្មវិធីរបស់អង្គការ ILO ក្នុងឆ្នាំ២០១០ ក្នុងការបង្កើតសេវាការងារ និងមជ្ឈមណ្ឌលបណ្តុះបណ្តាល។

ក្នុងកំឡុងពេលពិភាក្សា ក្រុមបានកត់សម្គាល់ពីសារៈសំខាន់នៃការផ្តល់ការបណ្តុះបណ្តាលដល់អ្នកស្វែងរកការងារ និងការផ្សារភ្ជាប់ការផ្គត់ផ្គង់ពលកម្មមានជំនាញទៅនឹងតម្រូវទីផ្សារការងារទាំងនៅទីប្រជុំជន និងទីជនបទ។ ជាមួយគ្នានោះ ក្រុមបានពិភាក្សាពីប្រាក់ចំណូលរបស់កម្មករ និងអំណាចនៃការទិញរបស់កម្មករ និងភាពចាំបាច់ក្នុងការធានាថាប្រាក់ចំណូលត្រូវបានវាស់វែងដោយធៀបនឹងអតិផរណាថ្លៃទំនិញប្រើប្រាស់។ ក្នុងករណីនេះ ក្រុមបានយល់ឃើញថាសូចនាករ "ប្រាក់ឈ្នួលមធ្យមពិត" ដែលស្នើឡើងដោយអង្គការ ILO សម្រាប់អតិផរណាថ្លៃទំនិញ និងអំណាចនៃការទិញគួរតែត្រូវបានតាមដានដោយយកចិត្តទុកដាក់។ ជាងនេះទៅទៀត ក្រុមបានស្នើឡើងនូវសូចនាករបន្ថែមថ្មីមួយគឺ " ចំណាយមធ្យមប្រចាំខែរបស់កម្មករ "។

**តារាងទី ២ : សូចនាករដែលស្នើឡើងដោយក្រុមការងារសម្រាប់ "ប្រាក់ឈ្នួលគ្រប់គ្រាន់ និងផលិតភាពការងារ"**

| សូចនាករ សម្គាល់ | សូចនាករ M = សូចនាករសំខាន់ A = សូចនាករបន្ថែម C = សូចនាករបរិបទ (គ្រប់សូចនាករដែលសម្គាល់ដោយ 'S' ត្រូវបែងចែកតាមភេទ) |
|---|---|
| EARN-1 | M – ការងារបានចំណូលតិច (S) |
| EARN-2 | M – អត្រាផ្តល់ប្រាក់ទាប (ក្រោម ២/៣នៃសមឌ្ឍរេខាប្រាក់ឈ្នួល (median earnings) ក្នុង១ម៉ោង) (S) |
| EARN-3 | A – ប្រាក់ឈ្នួលមធ្យមក្នុង១ម៉ោងនៃមុខរបរជ្រើសរើស (S) |
| EARN-4 | A – ប្រាក់ឈ្នួលមធ្យមពិត (ធៀបទៅនឹងសន្ទស្សន៍ថ្លៃទំនិញ) (S) |
| EARN-5 | A – ប្រាក់ឈ្នួលអប្បបរមា ជា%នៃសមឌ្ឍរេខាប្រាក់ឈ្នួល (median wage) |

| | |
|---|---|
| EARN-6 | A – សន្ទស្សន៍ប្រាក់ឈ្នួលនៅក្នុងកម្មន្តសាល |
| EARN-7 | A – និយោជិតដែលទើបទទួលការបណ្តុះបណ្តាលមុខជំនាញ (ឆ្នាំមុន/៤សប្តាហ៍មុន) (S) |
| n/a | A – ចំណាយមធ្យមប្រចាំខែរបស់កម្មករ* |

សម្គាល់: សូចនាករដែលលេខសូចនាករសម្គាល់ដកស្រង់ចេញពីក្របខណ្ឌកិច្ចប្រជុំត្រីភាគីនៃអ្នកជំនាញខាងវាស់វែងការងារសមរម្យ។ រីឯសូចនាករដែលមានសញ្ញា(*) មានលក្ខណៈជាក់លាក់ ឬត្រូវបានកែសម្រួលសម្រាប់កម្ពុជា។

ប្រភព: ការដកស្រង់ពីដំណើរការសិក្ខាសាលា។

### ៤.៣.៣. ម៉ោងការងារសមរម្យ ការងាររួមផ្សំ ជីវិតផ្ទាល់ខ្លួន និងគ្រួសារ ស្ថិរភាព និងសន្តិសុខការងារ

សមាជិកនៅក្នុងក្រុមការងារសម្រាប់ប្រធានបទ "ម៉ោងការងារសមរម្យ" "ការងាររួមផ្សំ ជីវិតផ្ទាល់ខ្លួន និងគ្រួសារ" និង"ស្ថិរភាព និងសន្តិសុខការងារ" រួមមានមន្ត្រីរដ្ឋាភិបាល៦នាក់ មន្ត្រីអង្គការ ILO ៥នាក់ តំណាងកម្មករម្នាក់ តំណាងនិយោជកម្នាក់ និងតំណាង NGO ម្នាក់។

ជាបឋម ក្រុមបានពិភាក្សាពីការកើនឡើងចំនួនកម្មករក្នុងម៉ោងធ្វើការហួសប្រមាណ ជាពិសេសបុរសនៅទីប្រជុំជន ដោយសារតែមានឱកាសការងារ ចំណាកស្រុកពីជនបទទៅទីក្រុង កំណើនភាពក្រីក្រ និងការធ្លាក់ចុះចំណូលប្រចាំគ្រួសារដែលបណ្តាលមកពីវិបត្តិសេដ្ឋកិច្ចឆ្នាំ២០០៨ និងតួនាទីរបស់បុរសដែលជាអ្នកស្វែងរកប្រាក់ចំណូលចម្បងប្រចាំគ្រួសារ។ ពេលវេលាទាក់ទងនឹងការមានការងារធ្វើមិនពេញលេញបានថយចុះ ដោយសារតែឱកាសការងារពេញម៉ោងមានការកើនឡើង។

ក្រុមក៏បានពិភាក្សាអំពីទស្សនៈទាននៃម៉ោងការងារ និងប្រាក់ឈ្នួលសមរម្យសម្រាប់កម្មករទាំងអស់ និងប្រាក់ឈ្នួលមិនស្មើភាព និងម៉ោងការងាររវាងបុរស និងស្ត្រី។ ស្ត្រីមួយចំនួនកំពុងធ្វើការក្នុងចំនួនម៉ោងដ៏ច្រើន តែទទួលបានប្រាក់ឈ្នួលតិច ឬមិនបានទាល់តែសោះទាំងនៅក្នុងវិស័យក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ។ នៅចុងបញ្ចប់ ក្រុមបានឯកភាពរក្សាទុកសូចនាករទាំងអស់ដែលបានស្នើឡើងដោយអង្គការ ILO សម្រាប់ "ម៉ោងការងារសមរម្យ" "ការងាររួមផ្សំ ជីវិតផ្ទាល់ខ្លួន និងគ្រួសារ" និង "ស្ថិរភាព និងសន្តិសុខការងារ" ហើយមិនបានស្នើសុំសូចនាករថ្មីណាមួយឡើយ។

**តារាងទី ៣ : សូចនាករដែលស្នើឡើងដោយក្រុមការងារសម្រាប់ "ម៉ោងការងារសមរម្យ" "ការងាររួមផ្សំ ជីវិតផ្ទាល់ខ្លួន និងគ្រួសារ" និង "ស្ថិរភាព និងសន្តិសុខការងារ"**

| | |
|---|---|
| សូចនាករ សម្គាល់ | សូចនាករ M = សូចនាករសំខាន់ A = សូចនាករបន្ថែម C = សូចនាករបរិបទ (គ្រប់សូចនាករដែលសម្គាល់ដោយ 'S' ត្រូវបែងចែកតាមភេទ) |
| HOUR-1 | M – ម៉ោងធ្វើការហួសប្រមាណ (ច្រើនជាង៤៨ម៉ោងក្នុង១សប្តាហ៍ "ម៉ោងធម្មតា") (S) |
| HOUR-2 | A – ម៉ោងធ្វើការធម្មតា (ស្តង់ដារម៉ោងធ្វើការ) (S) |
| HOUR-3 | A – ម៉ោងធ្វើការប្រចាំឆ្នាំក្នុងនិយោជិតម្នាក់ (S) |
| HOUR-4 | A – អត្រាពេលវេលាទាក់ទងនឹងការមានការងារធ្វើមិនពេញលេញ (S) |
| STAB-1 | M – ការងារប្រកបដោយគ្រោះថ្នាក់ (S) |
| STAB-2 | A – រយៈពេលកាន់ការងារ (S) |
| STAB-3 | A – ចំនួន និងប្រាក់ឈ្នួលកម្មករបណ្តោះអាសន្ន/កម្មករប្រចាំថ្ងៃ (S) |

សម្គាល់: សូចនាករដែលលេខសូចនាករសម្គាល់ដកស្រង់ចេញពីក្របខណ្ឌកិច្ចប្រជុំត្រីភាគីនៃអ្នកជំនាញខាងវាស់វែងការងារសមរម្យ ។ រីឯសូចនាករដែលមានសញ្ញា(*) មានលក្ខណៈជាក់លាក់ ឬត្រូវបានកែសម្រួលសម្រាប់កម្ពុជា។ ប្រភព: ការដកស្រង់ពីដំណើរការសិក្ខាសាលា។

## ៥. សម័យប្រជុំទី៤: ការតាមដានវឌ្ឍនភាពស្តីពីការងារសមរម្យ (២)

- សុវត្ថិភាពនៃបរិស្ថានការងារ
- សន្តិសុខសង្គម
- សំវាទសង្គម តំណាងកម្មករ និងតំណាងនិយោជក

### ៥.១. ទស្សនៈទាន និយមន័យ និងការបកស្រាយ

*អ្នកធ្វើបទបង្ហាញ: លោក Phu Huynh, ILO/EC MAP, ILO Bangkok*

លោក Huynh បានបង្ហាញពីនិយមន័យ ទស្សនៈទាន និងការបកស្រាយដែលសង្កត់ធ្ងន់លើ DWI សំខាន់ៗតាមធាតុផ្សំសំខាន់ៗនេះ:

១) សុវត្ថិភាពនៃបរិស្ថានការងារ

- អត្រាគ្រោះថ្នាក់ការងារ , ស្លាប់

២) សន្តិសុខសង្គម

- ចំណែករបស់ប្រជាជនអាយុពី៦៥ឆ្នាំឡើងដែលបានទទួលអត្ថប្រយោជន៍ពីសោធន (S)
- ការចំណាយនៃសន្តិសុខសង្គមសាធារណៈ (%នៃផលិតផលក្នុងស្រុកសរុប)

៣) សំវាទសង្គម តំណាងកម្មករ និងតំណាងនិយោជក

- អត្រាដង់ស៊ីតេសហជីពកម្មករ (S)
- សហគ្រាសជាកម្មសិទ្ធិរបស់អង្គការនិយោជក (អត្រា)
- អត្រាវិសាលភាពនៃអនុសញ្ញារួម (S)
- សូចនាករសម្រាប់គោលការណ៍ជាមូលដ្ឋាន និងសិទ្ធិនៅកន្លែងធ្វើការ (សេរីភាពក្នុងការបង្កើតសមាគម និងអនុសញ្ញារួម) ត្រូវបានកំណត់ដោយការិយាល័យ

ទាក់ទងនឹង "សុវត្ថិភាពនៃបរិស្ថានការងារ" យើងកត់សម្គាល់ឃើញថាគ្រោះថ្នាក់ការងារអាចកើតឡើងមិនត្រឹមតែកើតឡើងនៅកន្លែងធ្វើការប៉ុណ្ណោះទេ វាថែមទាំងកើតឡើងក្នុងកំឡុងពេលធ្វើដំណើរពីផ្ទះទៅកាន់កន្លែងធ្វើការ ឬការបណ្តុះបណ្តាលដែលទាក់ទងនឹងការងារ។ លើសពីនេះ ការកើនឡើង ឬការធ្លាក់ចុះនៃអត្រាគ្រោះថ្នាក់ការងារអាចឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរនៅក្នុងច្បាប់ជាតិ ឬប្រព័ន្ធរាយការណ៍។ សេចក្តីសម្រេចរបស់ ICLS (ឆ្នាំ១៩៩៨) ទាក់ទងនឹងគ្រោះថ្នាក់ការងារក៏ត្រូវបានបង្ហាញផងដែរ។

ទាក់ទងនឹង "សន្តិសុខសង្គម" វិញ សូចនាករសំខាន់២ត្រូវបានបង្ហាញ និងបាននិយាយយោងទៅដល់សេចក្តីសម្រេចរបស់ ICLS (ឆ្នាំ១៩៥៧) ស្តីពីស្ថិតិសន្តិសុខសង្គម និងអនុសញ្ញាលេខ១០២ស្តីពីសន្តិសុខសង្គម (បទដ្ឋានអប្បបរមា)។ ជុំវិញ "សំវាទសង្គម តំណាងកម្មករ និងតំណាងនិយោជក" សូចនាករសំខាន់៤ត្រូវបានពិភាក្សា រួមមានទាំងរបៀបដែលសូចនាករត្រូវបានដាក់ក្នុងតារាង និងការនិយាយយោងទៅដល់អនុសញ្ញា និងសេចក្តីសម្រេចដែលពាក់ព័ន្ធ។ ទាំងនេះរួមមានអនុសញ្ញាលេខ៨៧ស្តីពីសេរីភាពខាងសមាគម និងកិច្ចការពារក្នុងការរៀបចំ អនុសញ្ញាលេខ៩៨ស្តីពីសិទ្ធិក្នុងការរៀបចំ និងអនុសញ្ញារួម និងអនុសញ្ញាលេខ១០០ស្តីពីប្រាក់បំណាច់ស្មើគ្នា។

## ៥.២. ការរៀបចំតារាងទិន្នន័យចេញពីប្រភពទិន្នន័យអង្កេតជាតិដែលមានបច្ចុប្បន្ន

*អ្នកធ្វើបទបង្ហាញៈ លោក ហឿង សុផុន ប្រធាននាយកដ្ឋានព័ត៌មានទីផ្សារការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ*

លោក ហឿង សុផុន បានបង្ហាញពីទិដ្ឋភាពរួមនៃនាយកដ្ឋានព័ត៌មានទីផ្សារការងារ (LMI) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ លោកបានលើកឡើងពីតារាងទិន្នន័យនៃ DWI ដោយផ្អែកលើកំណត់ត្រារដ្ឋបាលផ្លូវការពីនាយកដ្ឋានពេទ្យការងារ និងនាយកដ្ឋានវិវាទការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ការព្រួយបារម្ភចម្បង១នៃតារាងទិន្នន័យដែលបានបង្ហាញទាក់ទងនឹងភូមិសាស្ត្រ

គ្របដណ្ដប់មានកម្រិត សេរីរយៈពេលខ្លីសម្រាប់សូចនាករមួយចំនួន និងការរៀបចំតារាងសូចនាករដោយយោងតាមនិយមន័យ និងស្តង់ដារអន្តរជាតិ។

ទាក់ទងនឹងសុវត្ថិភាពសង្គម ទិដ្ឋភាពនៃកិច្ចគាំពារផ្នែកសង្គមសព្វថ្ងៃរួមមាន: ១) បេឡាជាតិរបបសន្តិសុខសង្គម(NSSF) សម្រាប់និយោជិតក្នុងវិស័យឯកជនដែលបានផ្ដល់នូវការធានារ៉ាប់រងលើការងារ ២) បេឡាជាតិរបបសន្តិសុខសង្គម(NSSF-C) សម្រាប់មន្ត្រីរាជការដែលបានផ្ដល់នូវអត្ថប្រយោជន៍ពីសោធន ៣) កម្មវិធីគាំទ្រផ្នែកសុខភាពសង្គមផ្សេងៗទៀតដែលសំដៅទៅលើប្រជាពលរដ្ឋក្រីក្រ និងកម្មករនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ៤) ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ (CARD) និង ៥) កម្មវិធីបណ្ដាញសុវត្ថិភាពសង្គម (ឬជំនួយផ្នែកសង្គម) ផ្សេងៗទៀតដែលសំដៅទៅលើអ្នកក្រីក្រ និងអ្នកងាយរងគ្រោះ។ ជុំវិញសំវាទសង្គម ប្រព័ន្ធដោះស្រាយវិវាទការងារត្រូវបានបង្កើតឡើងដោយមានយន្តការផ្សះផ្សារ និងអាជ្ញាកណ្ដាល ខណៈពេលដែលកម្មករ និងនិយោជកបានចូលរួមយ៉ាងច្រើនក្នុងកិច្ចសន្ទនាជាទៀងទាត់។ នៅកម្ពុជា រាជរដ្ឋាភិបាលក៏បានអនុម័តលើគោលនយោបាយមួយដើម្បីលើកកម្ពស់អនុសញ្ញារួមឱ្យកាន់តែទូលំទូលាយថែមទៀតផងដែរ។

បញ្ហាប្រឈមនៃប្រព័ន្ធទិន្នន័យរដ្ឋបាលសម្រាប់ការតាមដានការងារសមរម្យរួមមានដូចខាងក្រោម:

- ប្រព័ន្ធទិន្នន័យនៅតាមក្រសួងមិនមានលក្ខណៈឆ្លើយតបទៅនឹងតម្រូវការរបស់រដ្ឋាភិបាលជាពិសេសទាក់ទងនឹងការងារសមរម្យ។
- មន្ត្រីរដ្ឋាភិបាលដែលទទួលខុសត្រូវលើ LMI និងការងារស្ថិតិនៅថ្នាក់រាជធានី និងខេត្តខ្វះជំនាញបច្ចេកទេសក្នុងការប្រមូល និងចងក្រងទិន្នន័យ។
- ការប្រមូលទិន្នន័យ និងព័ត៌មានគ្របដណ្ដប់តែចំពោះវិស័យក្នុងប្រព័ន្ធប៉ុណ្ណោះ។
- ខ្វះខាតការទទួលខុសត្រូវរបស់ប្រធានមន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈខេត្ត។
- ទិន្នន័យ និងព័ត៌មានដែលប្រមូលបានជារឿយៗមិនថ្មី និងមិនត្រូវបានវិភាគឱ្យបានស៊ីជម្រៅ។

## ៥.៣. ការពិភាក្សាក្រុមដើម្បីកំណត់ពីសូចនាករការងារសមរម្យថ្នាក់ជាតិតាមប្រធានបទនីមួយៗ

### ៥.៣.១. សុវត្ថិភាពនៃបរិស្ថានការងារ

សមាជិកនៅក្នុងក្រុមការងារសម្រាប់ប្រធានបទ "សុវត្ថិភាពនៃបរិស្ថានការងារ " រួមមានមន្ត្រីរដ្ឋាភិបាល ១០នាក់ មន្ត្រីអង្គការ ILO ៤នាក់ តំណាងនិយោជកម្នាក់ តំណាងកម្មករ២នាក់ និងតំណាង NGO ម្នាក់។

ក្រុមផ្ដោតការយកចិត្តទុកដាក់ទៅលើករណីគ្រោះថ្នាក់ការងារដែលកើនឡើង ទាំងស្លាប់ និងមិនស្លាប់។ ករណីគ្រោះថ្នាក់មិនស្លាប់សម្រាប់ស្ត្រីខ្ពស់ជាងបុរស តែករណីស្លាប់សម្រាប់បុរសមានចំនួនច្រើនជាងស្ត្រី។ ក៏ប៉ុន្តែ ចំនួនអធិការកិច្ចការងារនៅតែមិនប្រែប្រួលនាឆ្នាំកន្លងមក។ គោលនយោបាយ និងកម្មវិធីជាតិដែល

មានឥទ្ធិពលលើនិន្នាការនេះរួមមានច្បាប់ការងារប្រទេសកម្ពុជា ការផ្លាស់ប្តូរលក្ខខណ្ឌការងារ និងការរាយការណ៍កើនឡើងពីសហគ្រាសក្នុងប្រព័ន្ធ កម្មវិធីសុខភាព និងសុវត្ថិភាពការងាររបស់អង្គការ ILO ដូចជា WIND និង WISH ផែនការមេសម្រាប់សុខភាព និងសុវត្ថិភាពរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយមានកិច្ចសហការជាមួយអង្គការ ILO ការកសាងសមត្ថភាព និងការផ្តួចផ្តើមលើការលើកកម្ពស់ការយល់ដឹងពីសុខភាព និងសុវត្ថិភាពការងារ។ ក្នុងការវិភាគសូចនាករនីមួយៗ ក្រុមក៏បានលើកឡើងពីការលំបាកក្នុងការវាយតម្លៃនិន្នាការទាំងនេះឱ្យបានពេញលេញ ដោយសារតែខ្វះខាតទិន្នន័យដែលគ្រប់ជ្រុងជ្រោយ។

ក្រុមបានឯកភាពលើសូចនាករទាំង៤ដែលស្នើឡើងដោយអង្គការ ILO តែបានកែសម្រួលសូចនាករ២ដែលទាក់ទងនឹងគ្រោះថ្នាក់ការងារ ដោយដាក់បន្ថែមនូវការបែងចែកតាម ISIC និង ISCO។

**តារាងទី ៤ : សូចនាករដែលស្នើឡើងដោយក្រុមការងារសម្រាប់ "សុវត្ថិភាពនៃបរិស្ថានការងារ"**

| | |
|---|---|
| សូចនាករ សម្គាល់ | សូចនាករ M = សូចនាករសំខាន់ A = សូចនាករបន្ថែម C = សូចនាករបរិបទ (គ្រប់សូចនាករដែលសម្គាល់ដោយ 'S' ត្រូវបែងចែកតាមភេទ) |
| SAFE-1 | M – អត្រាគ្រោះថ្នាក់ការងារ , ស្លាប់ (ក្នុងនិយោជិត១0000នាក់) តាមការកំណត់របស់ ISIC និង ISCO* |
| SAFE-2 | A – អត្រាគ្រោះថ្នាក់ការងារ , មិនស្លាប់ (ក្នុងនិយោជិត១0000នាក់) តាមការកំណត់របស់ ISIC និង ISCO* |
| SAFE-3 | A – ពេលវេលាបាត់បង់ដោយសារគ្រោះថ្នាក់ការងារ |
| SAFE-4 | A – អធិការកិច្ចការងារ (ចំនួនអធិការក្នុងនិយោជិត១0000នាក់) |

សម្គាល់: សូចនាករដែលលេខសូចនាករសម្គាល់ដកស្រង់ចេញពីក្របខណ្ឌកិច្ចប្រជុំត្រីភាគីនៃអ្នកជំនាញខាងវាស់វែងការងារសមរម្យ។ រីឯសូចនាករដែលមានសញ្ញា (*) មានលក្ខណៈជាក់លាក់ ឬត្រូវបានកែសម្រួលសម្រាប់កម្ពុជា។

ប្រភព: ការដកស្រង់ពីដំណើរការសិក្ខាសាលា។

## ៥.៣.២. សន្តិសុខសង្គម

សមាជិកនៅក្នុងក្រុមការងារសម្រាប់ប្រធានបទ "សន្តិសុខសង្គម"រួមមានមន្ត្រីរដ្ឋាភិបាល៨នាក់ មន្ត្រីអង្គការ ILO ៥នាក់ តំណាងនិយោជកម្នាក់ តំណាងកម្មករ៣នាក់ និងតំណាង NGO ម្នាក់។

ក្រុមបានពិនិត្យមើលការកើនឡើងការចំណាយថែរក្សាសុខភាពដោយគ្រួសារឯកជន ដែលមានន័យថាការចំណាយសាធារណៈបានកើនឡើង តែនៅតែមានកម្រិត។ និន្នាការនេះត្រូវបានតម្រែតម្រង់ជាចំបងដោយកិច្ចខិតខំប្រឹងប្រែងនៃបេឡាជាតិរបបសន្តិសុខសង្គម (NSSF)។

នៅខណៈដែលក្រុមបានឯកភាពអនុម័តលើសូចនាករទាំង៣ដែលស្នើឡើងដោយអង្គការ ILO ក្រុមបានសម្រេចចិត្តមិនដាក់បញ្ចូលសូចនាករ " ការចំណាយលើការថែរក្សាសុខភាពដោយគ្រួសារឯកជន " សម្រាប់ការតាមដាននៅកម្ពុជា។ មិនតែប៉ុណ្ណោះ ក្រុមបានយល់ព្រមដាក់បន្ថែមសូចនាករថ្មីចំនួន៣ដូចដែលបានបង្ហាញនៅក្នុងតារាងទី៥ ទាក់ទងនឹងការចំណាយរបស់រដ្ឋាភិបាលសម្រាប់អ្នកគ្មានការងារធ្វើ មនុស្សចាស់ជរា និងកុមាររងាយរងគ្រោះ។

**តារាងទី ៥ : សូចនាករដែលស្នើឡើងដោយក្រុមការងារសម្រាប់ "សន្តិសុខសង្គម"**

| | |
|---|---|
| សូចនាករ សម្គាល់ | សូចនាករ M = សូចនាករសំខាន់ A = សូចនាករបន្ថែម C = សូចនាករបរិបទ (គ្រប់សូចនាករដែលសម្គាល់ដោយ 'S' ត្រូវបែងចែកតាមភេទ) |
| SECU-1 | M – ចំណែករបស់ប្រជាជនអាយុពី៦៥ឆ្នាំឡើងដែលបានទទួលអត្ថប្រយោជន៍ពីសោធន (S) |
| SECU-2 | M – ការចំណាយនៃសន្តិសុខសង្គមសាធារណៈ (% of GDP) |
| SECU-4 | A – ចំណែករបស់ប្រជាជនដែលបានទទួលការថែរក្សាសុខភាព (ជាមូលដ្ឋាន) (S) |
| n/a | A – ការចំណាយរបស់រដ្ឋាភិបាលដើម្បីគាំទ្រអ្នកគ្មានការងារធ្វើ* |
| n/a | A – ការចំណាយរបស់រដ្ឋាភិបាលសម្រាប់ការថែទាំកុមារអាយុក្រោម៣ឆ្នាំ* |
| n/a | A – ការចំណាយរបស់រដ្ឋាភិបាលដើម្បីបង្កើត និងដំណើរការមណ្ឌលសម្រាប់មនុស្សចាស់ជរា និងកុមាររងាយរងគ្រោះ* |

សម្គាល់: សូចនាករដែលលេខសូចនាករសម្គាល់ដកស្រង់ចេញពីក្របខណ្ឌកិច្ចប្រជុំត្រីភាគីនៃអ្នកជំនាញខាងវាស់វែងការងារសមរម្យ។ រីឯសូចនាករដែលមានសញ្ញា(*) មានលក្ខណៈជាក់លាក់ ឬត្រូវបានកែសម្រួលសម្រាប់កម្ពុជា។ ប្រភព: ការដកស្រង់ពីដំណើរការសិក្ខាសាលា។

## ៥.៣.៣. សំវាទសង្គម តំណាងកម្មករ និងតំណាងនិយោជក

សមាជិកនៅក្នុងក្រុមការងារសម្រាប់ប្រធានបទ " សំវាទសង្គម តំណាងកម្មករ និងតំណាងនិយោជក" រួមមានមន្ត្រីរដ្ឋាភិបាល៦នាក់ មន្ត្រីអង្គការ ILO ៥នាក់ តំណាងកម្មករម្នាក់ តំណាងនិយោជកម្នាក់ និងតំណាង NGO ៣នាក់។

ក្រុមបានពិភាក្សាពីសារៈសំខាន់នៃសហជីពកម្មករ និងសមាគមនិយោជក។ នាឆ្នាំកន្លងមក មានការកើនឡើងចំនួនសហជីពកម្មករ និងសមាជិកសមាគមនិយោជកដូចជា CAMFEBA ជាដើម។ ជាមួយគ្នាផងដែរ អ្នកចូលរួមបានពិភាក្សាអំពីភាពចាស់ទុំនៃអ្នកដឹកនាំសហជីពក្នុងការរៀបចំកូដកម្ម និងទំនាក់ទំនងវិជ្ជាជីវៈល្អរវាងកម្មករ និងនិយោជកដែលអាចធ្វើឱ្យមានការដោះស្រាយវិវាទការងារ។ នេះត្រូវបានឆ្លុះ

បញ្ហាំងនៅក្នុងការថយចុះនៃចំនួនកូដកម្ម និងចំនួនកម្មករដែលបានចូលរួម។ គោលនយោបាយ និងកម្មវិធីជាតិដែលមានឥទ្ធិពលលើនិន្នាការមានដូចជាអនុសញ្ញាស្នូលរបស់អង្គការ ILO ដែលត្រូវបានអនុម័តដោយប្រទេសកម្ពុជា មាត្រា៣៦នៃច្បាប់រដ្ឋធម្មនុញ្ញប្រទេសកម្ពុជា និងច្បាប់ការងារប្រទេសកម្ពុជាជាដើម។ ចុងក្រោយ ក្រុមបានឯកភាពលើការដាក់បញ្ចូលសូចនាករទាំងអស់ដែលបានស្នើឡើងដោយអង្គការ ILO។

**តារាងទី ៦ : សូចនាករដែលស្នើឡើងដោយក្រុមការងារសម្រាប់ "សំវាទសង្គម តំណាងកម្មករ និងតំណាងនិយោជក់**

| សូចនាករសម្គាល់ | សូចនាករ M = សូចនាករសំខាន់ A = សូចនាករបន្ថែម C = សូចនាករបរិបទ (គ្រប់សូចនាករដែលសម្គាល់ដោយ 'S' ត្រូវបែងចែកតាមភេទ) |
|---|---|
| DIAL-1 | M – អត្រាដង់ស៊ីតេសហជីព (S) |
| DIAL-2 | M – សហគ្រាសជាកម្មសិទ្ធិរបស់អង្គការនិយោជក (អត្រា) |
| DIAL-3 | M – អត្រាវិសាលភាពនៃអនុសញ្ញារួម (S) |
| DIAL-4 | M – សូចនាករសម្រាប់គោលការណ៏ជាមូលដ្ឋាន និងសិទ្ធិនៅកន្លែងធ្វើការ (សេរីភាពក្នុងការបង្កើតសមាគម និងអនុសញ្ញារួម) ត្រូវបានអភិវឌ្ឍន៍ដោយការិយាល័យ |
| DIAL-5 | A – កូដកម្ម និងឡុកអៅ/អត្រានៃថ្ងៃមិនបានធ្វើការ |

សម្គាល់: សូចនាករដែលលេខសូចនាករសម្គាល់ដកស្រង់ចេញពីក្របខណ្ឌកិច្ចប្រជុំត្រីភាគីនៃអ្នកជំនាញខាងវាស់វែងការងារសមរម្យ។ រីឯសូចនាករដែលមានសញ្ញា(*) មានលក្ខណៈជាក់លាក់ ឬត្រូវបានកែសម្រួលសម្រាប់កម្ពុជា។ ប្រភព: ការដកស្រង់ពីដំណើរការសិក្ខាសាលា។

## ៦. សម័យប្រជុំទី៥: ការតាមដានវឌ្ឍនភាពស្តីពីការងារសមរម្យ

- ការងារដែលត្រូវលុបបំបាត់ចោល
- សមភាពនៃកាលានុវត្តភាព និងប្រព្រឹត្តកម្មក្នុងការងារ
- បរិបទសេដ្ឋកិច្ច និងសង្គមសម្រាប់ការងារសមរម្យ

### ៦.១. ទស្សនៈទាន និយមន័យ និងការបកស្រាយ

*អ្នកធ្វើបទបង្ហាញ: លោក Phu Huynh, ILO/EC MAP, ILO Bangkok*

លោក Huynh បានបង្ហាញពីនិយមន័យ ទស្សនៈទាន និងការបកស្រាយការណែនាំសម្រាប់ DWI ចម្បង៧សម្រាប់ធាតុផ្សំសំខាន់៧នេះ:

១) ការងារដែលត្រូវលុបបំបាត់ចោល

- ឧបទេវហេតុរបស់កុមារនៅក្នុងពលកម្មកុមារ (S)

២) សមភាពនៃកាលានុវត្តភាព និងប្រព្រឹត្តកម្មក្នុងការងារ

- ការងារបែងចែកតាមភេទ
- ការចូលរួមចំណែករបស់ស្ត្រីក្នុងការងារនៅក្នុង ISCO-៨៨ ក្រុម១១ និង១៣

៣) បរិបទសេដ្ឋកិច្ច និងសង្គមសម្រាប់ការងារសមរម្យ

- កុមារមិនបានចូលរៀន (S)
- ការប៉ាន់ស្មាន%នៃប្រជាជនក្នុងអាយុធ្វើការដែលមានមេរោគហ៊ីវវិជ្ជមាន (S)
- ផលិតភាពការងារ (GDP ក្នុងនិយោជិតម្នាក់ កម្រិត និងអត្រាកំណើន)
- ប្រាក់ចំណូលមិនស្មើភាព (percentile ratio P90/P10ចំណូល ឬការប្រើប្រាស់)
- អត្រាអតិផរណា (CPI)
- អ្នកមានការងារធ្វើតាមសកម្មភាពសេដ្ឋកិច្ច
- ការសិក្សានៃប្រជាជនពេញវ័យ (អត្រាអក្ខរកម្មប្រជាជនពេញវ័យ អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សារបស់ប្រជាជនពេញវ័យ) (S)
- ការរួមចំណែកការងារក្នុង GDP

ទាក់ទងនឹង "ការងារដែលត្រូវលុបបំបាត់ចោល" ពលកម្មកុមារបានឆ្លុះបញ្ចាំងពីការចូលរួមរបស់កុមារក្នុងការងារហាមឃាត់ ហើយទូទៅជាងនេះគឺប្រភេទការងារដែលមានចែងនៅក្នុងច្បាប់ជាតិ អនុសញ្ញាស្តីពីអាយុអប្បបរមារបស់អង្គការ ILO ឆ្នាំ១៩៧៣ (លេខ១៣៨) និងអនុសញ្ញាស្តីពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ឆ្នាំ១៩៩៩ (លេខ១៨២) និងអនុសាសន៍បំពេញបន្ថែមទៀងផងដែរ (លេខ១៤៦ និងលេខ១៩០)។

ទាក់ទងនឹង "សមភាពនៃកាលានុវត្តភាព និងប្រព្រឹត្តកម្មក្នុងការងារ" ការងារបែងចែកតាមភេទមានឥទ្ធិពលអវិជ្ជមានលើប្រសិទ្ធភាពទីផ្សារការងារ និងត្រូវបានគេរកឃើញថាជាកត្តាកំណត់យ៉ាងសំខាន់នៃភាពខុសគ្នាលើប្រាក់ឈ្នួលរវាងបុរស និងស្ត្រី។ លើសពីនេះ ការចូលរួមចំណែករបស់ស្ត្រីក្នុងការងារនៅក្នុងអនុក្រុម ISCO នីមួយៗគឺជាការបង្ហាញយ៉ាងសំខាន់នៃកាលានុវត្តភាពសម្រាប់ស្ត្រីដើម្បីធ្វើការងារគ្រប់ប្រភេទនៅក្នុងសកម្មភាពសេដ្ឋកិច្ច និងកម្រិតក្រុមការងារដែលមានការគាំទ្រដល់ស្ត្រី។

## ៦.២. ការរៀបចំតារាងទិន្នន័យចេញពីប្រភពទិន្នន័យអង្កេតជាតិដែលមានបច្ចុប្បន្ន

*អ្នកធ្វើបទបង្ហាញ: លោក សុខ កុសល អនុប្រធាននាយកដ្ឋាននៃវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ*

លោក សុខ កុសល បានបង្ហាញពីតារាងទិន្នន័យពី DWI ជាច្រើនដែលផ្អែកលើអង្កេតពលកម្មកុមារនៅកម្ពុជា (ឆ្នាំ២០០១) CSES (ឆ្នាំ២០០៤ និងឆ្នាំ២០០៩) និងជំរឿនប្រជាជន (ឆ្នាំ១៩៩៨ និងឆ្នាំ

២០០៨)។ លើសពីនេះ សូចនាករសម្រាប់បរិបទសេដ្ឋកិច្ច និងសង្គមត្រូវបានសង្កត់ធ្ងន់ដោយផ្អែកលើប្រភពទិន្នន័យអង្កេតថ្នាក់ជាតិជាច្រើន ក្រៅពីទិន្នន័យកំណត់ត្រាជាតិ និងទិន្នន័យរដ្ឋបាលអប់រំជាដើម។

ក្នុងការពិនិត្យមើល "គម្លាតប្រាក់ឈ្នួលនៃយែនឌ័រ" និង"ប្រាក់ឈ្នួល/ប្រាក់ចំណូលមិនស្មើភាព" យើងបានកត់សម្គាល់ឃើញថាកម្មករភេទប្រុសកម្ពុជាជាច្រើនមានសកម្មភាពសេដ្ឋកិច្ចច្រើនដែលទទួលបានប្រាក់កម្រៃ នៅពេលដែលស្ត្រីតែងតែមានសកម្មភាពសេដ្ឋកិច្ចតែមួយ ដោយសារតែការទទួលខុសត្រូវលើការងារផ្ទះ និងការងារប្រចាំគ្រួសារដែលមិនបានប្រាក់កម្រៃ។ អាស្រ័យហេតុនេះ យើងបានណែនាំថា DWI ដែលទាក់ទងនឹងប្រាក់ចំណូលគួរតែដាក់ក្នុងតារាងដាច់ដោយឡែកសម្រាប់ទាំងសកម្មភាពសេដ្ឋកិច្ចចម្បង និងសកម្មភាពសេដ្ឋកិច្ចទាំងអស់ ដើម្បីសិក្សាឱ្យបានល្អប្រសើរសម្រាប់វិសមភាពរវាងបុរស និងស្ត្រី។

## ៦.៣. ការពិភាក្សាក្រុមដើម្បីកំណត់ពីសូចនាករការងារសមរម្យថ្នាក់ជាតិតាមប្រធានបទនីមួយៗ

### ៦.៣.១. ការងារដែលត្រូវលុបបំបាត់ចោល

សមាជិកនៅក្នុងក្រុមការងារសម្រាប់ប្រធានបទ " ការងារដែលត្រូវលុបបំបាត់ចោល " រួមមានមន្ត្រីរដ្ឋាភិបាល១០នាក់ មន្ត្រីអង្គការ ILO ៤នាក់ តំណាងកម្មករ២នាក់ តំណាងនិយោជកម្នាក់ និងតំណាង NGO ម្នាក់។

ក្រុមបានពិភាក្សាអំពីគ្រោះថ្នាក់នៃពលកម្មកុមារ ដោយសារតែអត្រាកុមារនៅក្នុងសកម្មភាពសេដ្ឋកិច្ចនៅខ្ពស់នៅកម្ពុជា ដោយភាគរយសម្រាប់កុមារាខ្ពស់ជាងកុមារីបន្តិច និងមានអត្រាខ្ពស់នៅតំបន់ជនបទបើប្រៀបធៀបនឹងទីប្រជុំជន។ ជាមួយគ្នាផងដែរ ក្រុមបានសង្កត់ធ្ងន់លើការជួយកុមារឱ្យចេញផុតពីការងារគ្រោះថ្នាក់ និងទម្រង់ធ្ងន់ធ្ងរផ្សេងទៀតនៃពលកម្មកុមារ។ ដោយសារតែលទ្ធភាពនៃការសិក្សាទាក់ទងនឹងពលកម្មកុមារ ក្រុមបានលើកឡើងថាអនុបាតរបស់កុមារីមិនបានចូលរៀនខ្ពស់ជាងកុមារាទាំងនៅកម្រិតបឋមសិក្សា និងមធ្យមសិក្សា។ គោលនយោបាយ និងច្បាប់ជាតិដែលពាក់ព័ន្ធរួមមានយុទ្ធសាស្ត្រចតុកោណរបស់រដ្ឋាភិបាល ផែនការមេដើម្បីលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារឆ្នាំ២០០៨-២០១២ និងគោលនយោបាយអប់រំជាតិផ្សេងៗទៀតជាដើម។

ក្រុមបានអនុម័តលើសូចនាករទាំង២ដែលស្នើឡើងដោយក្របខណ្ឌ DWI របស់អង្គការ ILO និងបានស្នើឱ្យមានការបែងចែកនៃ"ពលកម្មកុមារប្រកដោយគ្រោះថ្នាក់"តាមប្រភេទនៃគ្រោះថ្នាក់។

**តារាងទី ៧ : សូចនាករដែលស្នើឡើងដោយក្រុមការងារសម្រាប់ " ការងារដែលត្រូវលុបបំបាត់ចោល"**

| | |
|---|---|
| សូចនាករ សម្គាល់ | សូចនាករ M = សូចនាករសំខាន់ A = សូចនាករបន្ថែម C = សូចនាករបរិបទ (គ្រប់សូចនាករដែលសម្គាល់ដោយ 'S' ត្រូវបែងចែកតាមភេទ) |
| ABOL-1 | M – ពលកម្មកុមារ (ដូចដែលបានកំណត់ដោយសេចក្តីសម្រេចរបស់ ICLS) (S) |
| ABOL-2 | A – ពលកម្មកុមារប្រកបដោយគ្រោះថ្នាក់តាមប្រភេទគ្រោះថ្នាក់ (S)* |

សម្គាល់: សូចនាករដែលលេខសូចនាករសម្គាល់ដកស្រង់ចេញពីក្របខណ្ឌកិច្ចប្រជុំត្រីភាគីនៃអ្នកជំនាញខាងវាស់វែងការងារសមរម្យ ។ រីឯសូចនាករដែលមានសញ្ញា(*) មានលក្ខណៈជាក់លាក់ ឬត្រូវបានកែសម្រួលសម្រាប់កម្ពុជា ។
ប្រភព: ការដកស្រង់ពីដំណើរការសិក្ខាសាលា ។

## ៦.៣.២. សមភាពនៃកាលានុវត្តភាព និងប្រព្រឹត្តកម្មក្នុងការងារ

សមាជិកនៅក្នុងក្រុមការងារសម្រាប់ប្រធានបទ "សមភាពនៃកាលានុវត្តភាព និងប្រព្រឹត្តកម្មក្នុងការងារ" រួមមានមន្ត្រីរដ្ឋាភិបាល៨នាក់ មន្ត្រីអង្គការ ILO ៥នាក់ តំណាងនិយោជកម្នាក់ តំណាងកម្មករ៣នាក់ និងតំណាង NGO ម្នាក់ ។

ក្រុមបានសង្កត់ធ្ងន់ថាស្ត្រីមានតំណាងតិចតួចជាអ្នកធ្វើច្បាប់ មន្ត្រីជាន់ខ្ពស់ អ្នកគ្រប់គ្រង និងអ្នកមានជំនាញវិជ្ជាជីវៈ ។ ផ្ទុយមកវិញ ពួកគេមានតំណាងច្រើនជាអ្នកបម្រើការផ្នែកសេវាកម្ម និងកម្មករផ្នែកលក់ ។ ការព្រួយបារម្ភចម្បងមួយគឺការកើនឡើងគម្លាតប្រាក់ឈ្នួលនៃយែនឌ័រ ។ គោលនយោបាយ និងកម្មវិធីជាតិដែលពាក់ព័ន្ធមានដូចជាយុទ្ធសាស្ត្រចតុកោណរបស់រដ្ឋាភិបាល និង NSDP ជាដើម ។

ក្រុមបានឯកភាពដាក់បញ្ចូលសូចនាករទាំងអស់ដែលស្នើឡើងដោយអង្គការ ILO ទៅក្នុងបញ្ជីថ្នាក់ជាតិនៅកម្ពុជា ដោយបានលើកឡើងពីសារៈសំខាន់នៃការតាមដានការប្រៀបធៀបប្រាក់ឈ្នួល និងប្រភេទនៃការងាររបស់បុរស និងស្ត្រី ។ លើសពីនេះ ក្រុមបានសម្រេចផ្លាស់ប្តូរឈ្មោះពី "ការបែងចែងការងារតាមភេទ" ទៅជា "ការចូលរួមចំណែករបស់ស្ត្រីក្នុងការងារតាមមុខរបរ (ប្រភេទទិន្នន័យ ISCO)" និងបន្ថែមសូចនាករថ្មី២ដែលទាក់ទងនឹងការងារសម្រាប់ជនពិការ និងការងារសម្រាប់ជនរងគ្រោះដោយសារការកេងប្រវ័ញ្ចផ្លូវភេទ ។

**តារាងទី ៨ : សូចនាករដែលស្នើឡើងដោយក្រុមការងារសម្រាប់ "សមភាពនៃកាលានុវត្តភាព និងប្រព្រឹត្តកម្មក្នុងការងារ**

| | |
|---|---|
| សូចនាករ សម្គាល់ | សូចនាករ M = សូចនាករសំខាន់ A = សូចនាករបន្ថែម C = សូចនាករបរិបទ (គ្រប់សូចនាករដែលសម្គាល់ដោយ 'S' ត្រូវបែងចែកតាមភេទ) |
| EQUA-1 | M – ការចូលរួមចំណែករបស់ស្ត្រីក្នុងការងារតាមមុខរបរ (ប្រភេទទិន្នន័យ ISCO)* |
| EQUA-2 | M – ការចូលរួមចំណែករបស់ស្ត្រីក្នុងមុខរបរបែងចែកតាមភេទ ក្នុង ISCO-៨៨ ក្រុម១១ និង ក្រុម១២ |
| EQUA-3 | A –គម្លាតប្រាក់ឈ្នួលនៃយេនឌ័រ |
| EQUA-4 | A – សូចនាករសម្រាប់គោលការណ៍ជាមូលដ្ឋាន និងសិទ្ធិនៅកន្លែងធ្វើការ (ការលុបបំបាត់ការរើសអើងក្នុងការងារ និងមុខរបរ) ត្រូវបានអភិវឌ្ឍន៍ដោយការិយាល័យ |
| EQUA-5 | A – វិធានការសម្រាប់ការរើសអើងដោយពូជសាសន៍ /ជនជាតិភាគតិច/កម្មករចំណាកស្រុក/(ថ្មី) /កម្មករនៅជនបទ នៅកន្លែងដែលមានការពាក់ព័ន្ធ និងអនុវត្តន៍នៅថ្នាក់ជាតិ |
| n/a | A – កាលានុវត្តភាពការងារសម្រាប់ជនពិការ* |
| n/a | A – កាលានុវត្តភាពការងារសម្រាប់ជនរងគ្រោះដោយសារការកេងប្រវ័ញ្ចផ្លូវភេទ* |

សម្គាល់: សូចនាករដែលលេខសូចនាករសម្គាល់ដកស្រង់ចេញពីក្របខណ្ឌកិច្ចប្រជុំត្រីភាគីនៃអ្នកជំនាញខាងវាស់វែងការងារសមរម្យ ។ រីឯសូចនាករដែលមានសញ្ញា(*) មានលក្ខណៈជាក់លាក់ ឬត្រូវបានកែសម្រួលសម្រាប់កម្ពុជា ។

ប្រភព: ការដកស្រង់ពីដំណើរការសិក្ខាសាលា ។

## ៦.៣.៣. បរិបទសេដ្ឋកិច្ច និងសង្គមសម្រាប់ការងារសមរម្យ

សមាជិកនៅក្នុងក្រុមការងារសម្រាប់ប្រធានបទ " បរិបទសេដ្ឋកិច្ច និងសង្គមសម្រាប់ការងារសមរម្យ រួមមានមន្ត្រីរដ្ឋាភិបាល៦នាក់ មន្ត្រីអង្គការ ILO ៥នាក់ តំណាងកម្មករម្នាក់ តំណាងនិយោជកម្នាក់ និងតំណាង NGO ៣នាក់ ។

នៅក្នុងប្រភេទចុងក្រោយនេះ ក្រុមបានពិភាក្សាពីកំណើនសេដ្ឋកិច្ចនៅកម្ពុជាដែលមានទំនាក់ទំនងយ៉ាងខ្លាំងទៅនឹងការបង្កើតការងារនៅក្នុងវិស័យជាច្រើនដូចជាទេសចរណ៍ សំណង់ និងសេវាកម្ម។ អ្នកចូលរួមក៏បានលើកឡើងអំពីអត្រាកំណើនផលិតភាពពលកម្មខ្ពស់ និងវិជ្ជមានពីឆ្នាំ២០០៤ ដល់ឆ្នាំ២០០៩។ គោលនយោបាយ និងច្បាប់ជាតិដែលមានឥទ្ធិពលលើនិន្នាការនេះមានច្បាប់វិនិយោគទុន (សម្រាប់ឧស្សាហកម្ម និងសំណង់) NSDP ការលើកលែងពន្ធសម្រាប់ផលិតផលកសិកម្ម និងឧស្សាហកម្ម និងស្ថេរភាពនយោបាយ ។ ចុងក្រោយ ក្រុមបានសម្រេចរក្សាទុកសូចនាករទាំងអស់ដែលស្នើឡើងដោយអង្គការ ILO ។

**តារាងទី ៩ : សូចនាករដែលស្នើឡើងដោយក្រុមការងារសម្រាប់ " បរិបទសេដ្ឋកិច្ច និងសង្គមសម្រាប់ការងារសមរម្យ"**

| សូចនាករ សម្គាល់ | សូចនាករ M = សូចនាករសំខាន់ A = សូចនាករបន្ថែម C = សូចនាករបរិបទ (គ្រប់សូចនាករដែលសម្គាល់ដោយ 'S' ត្រូវបែងចែកតាមភេទ) |
|---|---|
| CONT-1 | C – កុមារមិនបានចូលរៀន (%តាមអាយុ) (S) |
| CONT-2 | C – ការប៉ាន់ស្មាន%នៃប្រជាជនក្នុងអាយុធ្វើការដែលមានមេរោគហ៊ីវវិជ្ជមាន (S) |
| CONT-3 | C – ផលិតភាពការងារ (GDP ក្នុងនិយោជិតម្នាក់ , កម្រិត និងអត្រាកំណើន) |
| CONT-4 | C – ប្រាក់ចំណូលមិនស្មើភាព (percentile ratio P90/P10 ចំណូល ឬការប្រើប្រាស់) |
| CONT-5 | C – អត្រាអតិផរណា (CPI) |
| CONT-6 | C – អ្នកមានការធ្វើតាមសកម្មភាពសេដ្ឋកិច្ច |
| CONT-7 | C – ការសិក្សានៃប្រជាជនពេញវ័យ (អត្រាអក្ខរកម្មប្រជាជនពេញវ័យ អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សារបស់ប្រជាជនពេញវ័យ) (S) |
| CONT-8 | C – ការងាររួមចំណែកក្នុង GDP |
| CONT-9 | C – (បន្ថែម) - GDP ពិតក្នុងមនុស្សម្នាក់ in PPP$ (កម្រិត និងអត្រាកំណើន) |
| CONT-10 | C – (បន្ថែម) -ស្ត្រីចូលរួមចំណែកក្នុងការងារតាមឧស្សាហកម្ម (ប្រភេទទិន្នន័យ ISIC) |
| CONT-11 | C – (បន្ថែម) - ប្រាក់ឈ្នួល/ប្រាក់ចំណូលមិនស្មើភាព (percentile ratio P90/P10) |
| CONT-12 | C – (បន្ថែម) - សូចនាករនៃភាពក្រីក្រ (គម្លាត និងអត្រា) |

សម្គាល់: សូចនាករដែលលេខសូចនាករសម្គាល់ដកស្រង់ចេញពីក្របខណ្ឌកិច្ចប្រជុំត្រីភាគីនៃអ្នកជំនាញខាងវាស់វែងការងារសមរម្យ។

ប្រភព: ការដកស្រង់ពីដំណើរការសិក្ខាសាលា។

## ៧. សម័យប្រជុំទី៦: អាទិភាពសម្រាប់គម្រោងការជាតិតាមដានការងារសមរម្យ

*អ្នកសម្របសម្រួល: លោក Phu Huynh, ILO/EC MAP, ILO Bangkok និង លោកស្រី Monica D. Castillo នាយកដ្ឋានស្ថិតិ ILO Geneva*

សម័យប្រជុំនេះបានចាប់ផ្តើមដោយមានការពិភាក្សា និងការពិនិត្យមើលយ៉ាងទូលំទូលាយលើសូចនាករដែលអ្នកចូលរួមបានកំណត់សម្រាប់ការតាមដានថ្នាក់ជាតិនៅក្នុងសម័យប្រជុំទី៣ដល់ទី៥។ យើងបានកត់សម្គាល់ឃើញថាអ្នកចូលរួមបានឯកភាពដាក់បញ្ចូលសូចនាករស្នើរតែទាំងអស់តាមក្របខណ្ឌអន្តរជាតិដើម្បីវាស់វែងការងារសមរម្យដូចដែលបានស្នើឡើងដោយ TME ។ លើសពីនេះ សូចនាករថ្មីមួយចំនួនត្រូវបានស្នើឡើង និងកំណត់ដោយអ្នកចូលរួមដើម្បីបំពេញបន្ថែមលើក្របខណ្ឌអន្តរជាតិដែលបានស្នើឡើងដោយ TME។ នេះបានបញ្ជាក់ឱ្យឃើញពីចំនុចវិជ្ជមានថា DWI អាចត្រូវបានកែសម្រួលឱ្យស្របតាមបរិបទជាតិដើម្បីធ្វើការវាស់វែងភាពជាក់ស្តែងនៃការងារសមរម្យនៅកម្ពុជាឱ្យបានល្អប្រសើរ។ សរុបមក អ្នកចូលរួមបានបង្កើតសូចនាករថ្មីចំនួន៨ដែលជាក់លាក់សម្រាប់កម្ពុជា ដោយមានការកែសម្រួលតិចតួចលើសូចនាករមានស្រាប់ដែលបានស្នើឡើងដោយអង្គការ ILO ចំពោះកម្រិតនៃការបែងចែក។

ជាងនេះទៅទៀត សូចនាករខ្លះត្រូវបានដាក់ក្នុងតារាងរួចរាល់ហើយ ដោយផ្អែកលើទិន្នន័យដែលប្រមូលបាន និងមាននៅក្នុងជំរឿនប្រជាជន អង្កេតសេដ្ឋកិច្ច-សង្គមកម្ពុជា អង្កេតពលកម្មកុមារ ទិន្នន័យជាតិ និងកំណត់ត្រារដ្ឋបាលមកពី MOLVT និងក្រសួងផ្សេងៗទៀត។ សម្រាប់សូចនាករដែលបច្ចុប្បន្នមិនទាន់មានទិន្នន័យ ប្រភពទិន្នន័យដែលអាចប្រមូលបានមានដូចជាអង្កេតតាមផ្ទះ ឬកំណត់ត្រាទិន្នន័យរដ្ឋបាលត្រូវបានរកឃើញ និងធ្វើការកំណត់សម្រាប់ការបង្កើតនាពេលអនាគត។ ក្នុងករណីនេះហើយ អង្កេតកម្លាំងពលកម្ម-អង្កេតពលកម្មកុមារនៅកម្ពុជាដែលត្រូវបានគ្រោងឡើងក្នុងឆ្នាំ២០១១-២០១២ ក៏ត្រូវបានពិភាក្សាដោយសារតែនេះជាប្រភពទិន្នន័យសំខាន់មួយសម្រាប់ DWI មួយចំនួន។

សរុបមកវិញ អ្នកចូលរួមបានរៀបចំបញ្ជីសូចនាករចំនួន៦៣សម្រាប់ការតាមដានការងារសមរម្យនៅថ្នាក់ជាតិនៅកម្ពុជា។ ដោយដឹងថាយើងត្រូវការធនធានសំខាន់ៗដូចជាបញ្ជីសូចនាករលម្អិតមួយជាទៀងទាត់ដើម្បីប្រមូល និងរៀបចំទិន្នន័យសម្រាប់ការតាមដាន អ្នកចូលរួមបានសម្រេចចិត្តថាបញ្ជីសូចនាករស្នូលជាអាទិភាពមួយគួរតែត្រូវបានជ្រើសរើស។ ហេតុនេះហើយ ការបោះឆ្នោតគឺជាឱកាសមួយសម្រាប់អ្នកចូលរួមម្នាក់ៗក្នុងការដាក់កម្រិតលើសូចនាករ ដោយផ្អែកលើភាពសំខាន់សម្រាប់បរិបទជាក់ស្តែងនៅកម្ពុជា។ លើសពីនេះ យើងបានកត់សម្គាល់ឃើញថាបញ្ជីស្នូលនេះគួរតែឆ្លុះបញ្ចាំងពីអាទិភាពជាបឋមនៃ DWCP ឆ្នាំ២០១១-២០១៥ ដូចដែលបានបង្ហាញនៅក្នុងសម័យប្រជុំទី១។ ទាំងអស់នេះរួមមានការកែលម្អទំនាក់ទំនង

វិជ្ជាជីវៈ និងសិទ្ធិនៅកន្លែងធ្វើការ ការលើកកម្ពស់បរិយាកាសដែលបង្កលក្ខណៈងាយស្រួលដល់ការងារ និងកិច្ចគាំពារផ្នែកសង្គម។

អ្នកចូលរួមម្នាក់ៗទទួលបានសន្លឹកឆ្នោតចំនួន១០ ដោយអនុញ្ញាតឱ្យបោះបានច្រើនបំផុត២សម្លេងប៉ុណ្ណោះសម្រាប់ធាតុផ្សំសំខាន់នៃការងារសមរម្យណាមួយ។ បន្ទាប់ពីដំណើរការបោះឆ្នោតដោយបើកចំហរួចមកសម្លេងឆ្នោតត្រូវបានរាប់។ ទោះបីជាមានការណែនាំក៏ដោយ ការបោះឆ្នោតមិនបានផ្ដល់សម្លេងទៅគ្រប់ធាតុផ្សំសំខាន់ៗទេ។ ហេតុនេះហើយ យើងមិនមានសូចនាករជាអាទិភាពត្រូវបានជ្រើសរើសសម្រាប់ "សមភាពនៃកាលានុវត្តភាព និងប្រព្រឹត្តកម្មក្នុងការងារ" ទេ។ បញ្ជីអាទិភាពនៃសូចនាករចំនួន២០សម្រាប់ការតាមដានការងារសមរម្យនៅកម្ពុជាត្រូវបានបង្ហាញនៅក្នុងតារាងទី១០។

**តារាងទី ១០ : សូចនាករអាទិភាពសម្រាប់ការវាស់វែងការងារសមរម្យនៅកម្ពុជាដែលត្រូវបានកំណត់ដោយអ្នកចូលរួម**

| សូចនាករ | សូចនាករសម្គាល់ | សម្លេងឆ្នោត |
|---|---|---|
| ១. ម៉ោងធ្វើការហួសប្រមាណ (ច្រើនជាង៤៨ម៉ោងក្នុង១សប្ដាហ៍ "ម៉ោងធម្មតា") | HOUR-1 | ២២ សម្លេង |
| ២. អត្រាគ្រោះថ្នាក់ការងារ , ស្លាប់ (ក្នុងនិយោជិត១០000នាក់) តាមការកំណត់របស់ ISIC និង ISCO* | SAFE-1 | ២១ សម្លេង |
| ៣. ការងារប្រកបដោយគ្រោះថ្នាក់ | STAB-1 | ១៩ សម្លេង |
| ៤. អត្រាគ្មានការងារធ្វើ | EMPL-2 | ១៨ សម្លេង |
| ៥. ពលកម្មកុមារប្រកបដោយគ្រោះថ្នាក់តាមប្រភេទគ្រោះថ្នាក់* | ABOL-2 | ១៦ សម្លេង |
| ៦. ពលកម្មកុមារ (ដូចដែលបានកំណត់ដោយសេចក្ដីសម្រេច ICLS) | ABOL-1 | ១៣ សម្លេង |
| ៦a. ការចំណាយនៃសន្តិសុខសង្គមសាធារណៈ (% នៃ GDP) | SECU-2 | ១៣ សម្លេង |
| ៨. កុមារមិនបានចូលរៀន (%តាមអាយុ) | CONT-1 | ១១ សម្លេង |
| ៨a. ចំណែករបស់ប្រជាជនដែលបានទទួលការថែរក្សាសុខភាព(ជាមូលដ្ឋាន) | SECU-4 | ១១ សម្លេង |
| ១០. អត្រាដង់ស៊ីតេសហជីព | DIAL-1 | ១០ សម្លេង |
| ១០a. ចំណែករបស់ប្រជាជនអាយុពី៦៥ឆ្នាំឡើងដែលបានទទួលអត្ថប្រយោជន៍ពីសោធន | SECU-1 | ១០ សម្លេង |
| ១០b. ការងារបានចំណូលតិច | EARN-1 | ១០ សម្លេង |
| ១៣. ប្រាក់ឈ្នួលមធ្យមពិត (ធៀបទៅនឹងសន្ទស្សន៍ថ្លៃទំនិញ) | EARN-4 | ៩ សម្លេង |
| ១៤. អត្រាគ្មានការងារធ្វើរបស់យុវជន អាយុ១៥-២៤ឆ្នាំ | EMPL-6 | ៧ សម្លេង |

| | | |
|---|---|---|
| ១៤a.ប្រាក់ឈ្នួលមធ្យមក្នុង១ម៉ោងនៃមុខរបរជ្រើសរើស | EARN-3 | ៧ សម្លេង |
| ១៤b.ប្រាក់ឈ្នួលអប្បបរមា ជា%នៃសមន្យរេខាប្រាក់ឈ្នួល (median wage) | EARN-5 | ៧ សម្លេង |
| ១៤c. ចំនួន និងប្រាក់ឈ្នួលកម្មករប្រចាំថ្ងៃ | STAB-3 | ៧ សម្លេង |
| ១៤d. អត្រាគ្រោះថ្នាក់ការងារ , មិនស្លាប់ (ក្នុងនិយោជិត១០០០០នាក់) តាមការកំណត់របស់ ISIC និង ISCO* | SAFE-2 | ៧ សម្លេង |
| ១៤e. អធិការកិច្ចការងារ (ចំនួនអធិការក្នុងនិយោជិត១០០០០នាក់) | SAFE-4 | ៧ សម្លេង |
| ១៤f. សូចនាករសម្រាប់គោលការណ៍ជាមូលដ្ឋាន និងសិទ្ធិនៅកន្លែងធ្វើការ (សេរីភាព ក្នុងការបង្កើតសមាគម និងអនុសញ្ញារួម) ត្រូវបានអភិវឌ្ឍន៍ដោយការិយាល័យ | DIAL-4 | ៧ សម្លេង |

សម្គាល់: សូចនាករដែលលេខសូចនាករសម្គាល់ដកស្រង់ចេញពីក្របខណ្ឌកិច្ចប្រជុំត្រីភាគីនៃអ្នកជំនាញខាងវាស់វែងការងារសមរម្យ ។ រីឯសូចនាករដែលមានសញ្ញា(*) មានលក្ខណៈជាក់លាក់ ឬត្រូវបានកែសម្រួលសម្រាប់កម្ពុជា ។

ប្រភព: ការដកស្រង់ពីដំណើរការសិក្ខាសាលា ។

## ៨. ការសម្លឹងឆ្ពោះទៅមុខ: ការពង្រឹងការសម្របសម្រួលស្ថាប័ន និងការរកអត្តសញ្ញាណវិស័យជាអាទិភាពសម្រាប់កិច្ចការផ្នែកបច្ចេកទេសរវាងកម្ពុជា អង្គការពលកម្មអន្តរជាតិ និងដៃគូអភិវឌ្ឍន៍

*អ្នកសម្របសម្រួល: លោកស្រី Monica D. Castillo នាយកដ្ឋានស្ថិតិ ILO Geneva*

សម័យប្រជុំចុងក្រោយគឺជាវេទិកាសម្រាប់អ្នកចូលរួមក្នុងការពិនិត្យមើលយន្តការសម្របសម្រួលថ្មីសម្រាប់ស្ថាប័នជាតិដែលពាក់ព័ន្ធនឹងការផលិតស្ថិតិការងារសមរម្យ និងសម្រាប់អ្នកផលិត និងអ្នកប្រើប្រាស់ទិន្នន័យការងារសមរម្យ ។ ក្នុងការពិចារណាលើគម្លាត និងបញ្ហាប្រឈមក្នុងការវាស់វែងការងារសមរម្យនៅកម្ពុជា និងកំណត់ពីវិស័យសម្រាប់កិច្ចសហការ និងជំនួយពីអង្គការ ILO និងដៃគូអភិវឌ្ឍន៍ផ្សេងទៀតដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ អ្នកចូលរួមបានឆ្លើយតបយ៉ាងសកម្មទៅសំនួរណែនាំចំនួន២គឺ:

អ្នកចូលរួមម្នាក់មកពីអង្គការ ILO បាននិយាយថាមានគំនិតផ្តួចផ្តើមមួយចំនួននៅក្នុង MOLVT និងក្នុងគណៈកម្មាធិការអន្តរក្រសួងនៅកម្ពុជា តែគេនៅមិនទាន់មានយន្តការជាក់លាក់ណាមួយនៅឡើយសម្រាប់ការងារសមរម្យនេះ ។ លោកបាននិយាយទៀតថាកិច្ចប្រជុំពិនិត្យមើលឡើងវិញប្រចាំឆ្នាំអាចត្រូវបានធ្វើឡើងដើម្បីតាមដានវឌ្ឍនភាពស្តីពីការងារសមរម្យក្នុងចំណោមអ្នកពាក់ព័ន្ធទាំងអស់ ។

មន្ត្រីម្នាក់មកពី NIS បាននិយាយថាទស្សនៈទាននៃការងារសមរម្យគឺថ្មីណាស់សម្រាប់កម្ពុជា ហើយមានមនុស្សជាច្រើនមិនបានស្គាល់ ។ អាស្រ័យហេតុនេះ យើងចាំបាច់ត្រូវបង្កើតអ្នកទំនាក់ទំនងកណ្តាលមួយ

ដែលមានការចូលរួមពីក្រសួងផ្សេងៗ ស្ថាប័ននិយោជក និងសហជីពការងារ ដោយសារតែស្ថាប័នទាំងនោះមានព័ត៌មាន និងទិន្នន័យទាក់ទងនឹងការងារសមរម្យផ្សេងគ្នា។ ជាមួយគ្នាផងដែរ យើងនៅតែត្រូវការជំនួយផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ ព្រមទាំងការពិគ្រោះយោបល់ពីអង្គការ ILO សម្រាប់ជួយអ្នកដែលធ្វើការងារពាក់ព័ន្ធនឹងការងារសមរម្យ។ ជាចុងក្រោយ លោកបានលើកឡើងពីសារៈសំខាន់នៃអ្នកទំនាក់ទំនងកណ្តាលត្រីភាគី និងការធ្វើបច្ចុប្បន្នកម្មទិន្នន័យពលកម្ម និងការងារ និងប្រព័ន្ធចែករំលែកព័ត៌មានក្នុងចំណោមអ្នកពាក់ព័ន្ធ។

មន្ត្រីម្នាក់មកពី NEA បានលើកឡើងថា NIS មានការទទួលខុសត្រូវលើស្ថិតិនៅកម្ពុជា។ សម្រាប់ការប្រមូលទិន្នន័យទាក់ទងនឹងការងារសមរម្យ យើងចាំបាច់ត្រូវបង្កើតគណៈកម្មាធិការមួយដើម្បីកំណត់ពីវិធីសាស្ត្រប្រមូលទិន្នន័យ។ លោកក៏បាននិយាយដល់ប្រភពនៃសូចនាករទិន្នន័យដែលអាចដកស្រង់ចេញពីកំណត់ត្រារដ្ឋបាល ឬមកពី NIS និងបានគូសបញ្ជាក់ពីសារៈសំខាន់នៃការបណ្តុះបណ្តាលដល់មន្ត្រីលើការប្រមូលទិន្នន័យការងារសមរម្យពីកំណត់ត្រារដ្ឋបាល និងកំណត់ពីស្តង់ដារនៃបញ្ជីសំនួរអង្កេតលើកម្លាំងពលកម្ម។

មន្ត្រីម្នាក់មកពី MOLVT បានបង្ហាញថានៅកម្ពុជាមានគណៈកម្មាធិការច្រើន តែមួយចំនួនមិនបានបំពេញការងារមានប្រសិទ្ធភាព ដោយសារតែមិនមានសមត្ថភាព និងការប្តេជ្ញាចិត្តពីសមាជិក។ ហេតុនេះការជ្រើសរើសអ្នកមានសមត្ថភាព មានជំនាញ និងមានឆន្ទៈដើម្បីចូលក្នុងគណៈកម្មាធិការគឺជាចំនុចសំខាន់។

មន្ត្រីម្នាក់ពី CARD បាននិយាយថាស្ថាប័នរបស់លោកមានក្រុមការងារថ្នាក់ក្រសួងចំនួន៦ ជាពិសេសក្រុមការងារកិច្ចគាំពារផ្នែកសង្គមដែលមានការពាក់ព័ន្ធមួយចំនួនទៅនឹងការងារសមរម្យនៅកម្ពុជា។ លោកបានស្នើសុំថា CARD ជាសមាជិកម្នាក់នៅក្នុងយន្តការសម្របសម្រួលនេះ។ ជាចុងក្រោយ លោកបានលើកសំនួរចំនួន៣: ១) តើស្ថាប័នជំនាញណាមួយនៅកម្ពុជាដែលទទួលបន្ទុកវាស់វែងការងារសមរម្យ? ២) តើស្ថាប័ននោះអាចធ្វើសេចក្តីសម្រេចចិត្តផ្នែកនយោបាយបានកម្រិតណា? និង ៣) តើយន្តការនេះនឹងជាន់គ្នាជាមួយការទទួលខុសត្រូវរបស់ CARD ទេ ដោយសារតែមានការងារស្រដៀងគ្នាមួយចំនួន។

មន្ត្រីម្នាក់មកពី MOLVT បានពន្យល់ថាការងារសមរម្យទាក់ទងសំខាន់ជាមួយនឹង MOLVT តែយើងនៅតែត្រូវការកិច្ចសហការជាមួយ NIS លើបញ្ហាស្ថិតិ និងជាមួយ CARD លើទិន្នន័យសម្រាប់កិច្ចគាំពារផ្នែកសង្គម។

មន្ត្រីម្នាក់ទៀតមកពី NIS បានអះអាងថាអណត្តិនៃការងារសមរម្យដំបូងបានចាប់ផ្តើមជាមួយ MOLVT។ ក្រោយមក វាបានពាក់ព័ន្ធត្រីភាគីដោយរួមទាំងស្ថាប័ននិយោជក និងស្ថាប័នកម្មករ ហើយការចូលរួមរបស់ NIS នៅមានកម្រិត។ ហេតុនេះហើយ បើនិយាយទៅ ទស្សនៈទាននៃការងារសមរម្យមានលក្ខណៈថ្មីស្រឡាងសម្រាប់ NIS។

បន្ទាប់ពីការពិភាក្សាយ៉ាងសកម្មរួចមក លោកស្រី Monica បានសង្ខេបលទ្ធផលសំខាន់ៗពីការពិភាក្សាដូចខាងក្រោម៖

*១) តើយន្តការជាស្ថាប័ន និងដំណើរការណាដែលគួរត្រូវបានបង្កើត ឬពង្រឹងរវាងអ្នកផលិត និងអ្នកប្រើប្រាស់ទិន្នន័យសម្រាប់ការតាមដានវឌ្ឍនភាពស្តីពីការងារសមរម្យនៅកម្ពុជា? តើអង្គការពលកម្មអន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានាអាចជួយគាំទ្រដល់អ្នកពាក់ព័ន្ធជាតិនៅក្នុងកិច្ចប្រឹងប្រែងនេះដោយរបៀបណា?*

- បង្កើតគណៈកម្មាធិការអន្តរក្រសួងលើការងារសមរម្យ (មានការចូលរួមពីអង្គការ ILO, MOLVT, CARD និង NIS)។
- បង្កើតគណៈកម្មាធិការដើម្បីកំណត់ពីការប្រមូលទិន្នន័យការងារសមរម្យ ដោយគណៈកម្មាធិការមិនស្ថិតនៅក្រោមក្រសួងណាមួយដោយផ្ទាល់ ហើយមានសមាជិកសកម្ម និងមានសមត្ថភាព។
- បង្កើតអ្នកទំនាក់ទំនងកណ្តាលនៅកម្រិតអន្តរក្រសួងនៅកម្ពុជា។
- បង្កើតអ្នកទំនាក់ទំនងកណ្តាលសម្រាប់ត្រីភាគីដើម្បីតាមដានការងារសមរម្យ។
- អង្គការ ILO គួរតែបន្តផ្តល់ជំនួយផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ។
- រៀបចំសិក្ខាសាលាផ្ទៀងផ្ទាត់របស់អង្គការ ILO ដើម្បីតាមដានការងារសមរម្យ។
- បង្កើត ឬធ្វើបច្ចុប្បន្នកម្មឧបករណ៍តាមដានវឌ្ឍនភាពស្តីពីការងារសមរម្យ។
- ដាក់ឱ្យនៅថ្នាក់មជ្ឈិមនៃស្ថិតិនៃការងារសមរម្យ និងដំណើរការផ្សព្វផ្សាយ។
- បន្តផ្តល់ជំនួយបច្ចេកទេស និងទិន្នន័យថ្មីៗ និងបង្កើតប្រព័ន្ធចែករំលែកព័ត៌មានសម្រាប់អ្នកប្រើប្រាស់ទិន្នន័យទាំងអស់។
- អ្នកពាក់ព័ន្ធទាំងអស់គួរតែអាចប្រមូលសូចនាករដែលពាក់ព័ន្ធ និងដាក់បញ្ចូលក្នុងផែនការការងារ ឬកម្មវិធីរបស់ខ្លួន។

*២) ចំពោះការប្រមូលទិន្នន័យ ការវិភាគទិន្នន័យ និងការតាមដាន និងការកសាងសមត្ថភាពស្តីពីការវាស់វែងការងារសមរម្យ តើអាទិភាព និងសកម្មភាពជាក់លាក់នានានៅកម្ពុជាណាដែលគួរអនុវត្តន៍បន្តទៅមុខទៀត? តើអង្គការពលកម្មអន្តរជាតិ និងដៃគូអភិវឌ្ឍន៍អាចជួយគាំទ្រដល់អ្នកពាក់ព័ន្ធជាតិនៅក្នុងកិច្ចខិតខំប្រឹងប្រែងនេះដោយរបៀបណា?*

- រៀបចំការបណ្តុះបណ្តាលដល់គណៈកម្មាធិការជំនាញ ជាពិសេសសមាជិកស្នូល និងរៀបចំការបណ្តុះបណ្តាលតាមដានវាយតម្លៃ។
- បង្កើតក្រុមប្រឹក្សាជាតិសម្រាប់កិច្ចសហការផ្នែកបច្ចេកទេសដែលដឹកនាំដោយ MOLVT និងមានការចូលរួមពីសមាជិកសហជីព។
- ធ្វើបច្ចុប្បន្នកម្ម និងរៀបចំអង្កេតកម្លាំងពលកម្មនៅកម្ពុជា។

- រៀបចំសិក្ខាសាលាកសាងសមត្ថភាពដល់មន្ត្រី MOLVT ដើម្បីបំពេញតម្រូវការបណ្តុះបណ្តាលជាក់ស្តែង ដោយផ្អែកលើសូចនាករជាក់លាក់ ។
- ពង្រឹងលទ្ធភាពទទួលបានព័ត៌មានទាក់ទងនឹងការងារសមរម្យសម្រាប់អ្នកពាក់ព័ន្ធទាំងអស់ ។
- លើកកម្ពស់ការយល់ដឹងស្តីពីសូចនាករការងារសមរម្យ និងការវិភាគទៅកាន់អ្នកនយោបាយ និងអ្នកធ្វើគោលនយោបាយ ។
- ពិនិត្យមើលឡើងវិញពីប្រភពនៃការប្រមូលទិន្នន័យការងារសមរម្យ និងផ្តល់នូវការបណ្តុះបណ្តាលជាក់ស្តែងលើការប្រមូលទិន្នន័យ ។
- ផ្តល់នូវគោលការណ៍ណែនាំនៃការប្រមូលទិន្នន័យសម្រាប់បញ្ជីសំនួរដែលមានលក្ខណៈស្តង់ដារ និងដំណើរការ ព្រមទាំងការបង្ហាត់បង្ហាញពីការវិភាគទិន្នន័យដោយប្រើប្រាស់កម្មវិធីកុំព្យូទ័រ ។

## ៩. បូកសរុបលទ្ធផល និងបិទកម្មវិធី

លោកស្រី Monica តំណាងឱ្យអង្គការ ILO បានសម្តែងនូវការអរគុណយ៉ាងជ្រាលជ្រៅចំពោះអ្នកចូលរួមទាំងអស់មកពីស្ថាប័នរដ្ឋាភិបាលជាច្រើន ស្ថាប័ននិយោជក សហជីព និងអង្គការមិនមែនរដ្ឋាភិបាលដែលបានបង្ហាញនូវការយកចិត្តទុកដាក់ និងចូលរួមយ៉ាងសកម្មក្នុងសិក្ខាសាលារយៈពេល៣ថ្ងៃនេះ ។ ជាមួយគ្នាផងដែរ លោកស្រីបានកោតសរសើរដល់កិច្ចសហការល្អប្រសើរនៅក្នុងការពិភាក្សាដើម្បីសម្រេចលើសូចនាករអាទិភាពចំនួន២០ដើម្បីវាស់វែងការងារសមរម្យនៅកម្ពុជា និងកំណត់ពីជំនួយផ្នែកបច្ចេកទេស និងយន្តការសម្របសម្រួលសម្រាប់ត្រីភាគីលើការគាំទ្រ DWCP ។ ជាចុងក្រោយ លោកស្រីបានថ្លែងអំណរគុណដល់សហភាពអឺរ៉ុបដែលបានផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុដល់ការរៀបចំសិក្ខាសាលានេះ ។ លោកស្រីបានជម្រុញឱ្យអ្នកពាក់ព័ន្ធត្រីភាគីកម្ពុជាបង្ហាញនូវភាពរឹងមាំដែលបានមកពីសិក្ខាសាលា និងបន្តកិច្ចខិតខំប្រឹងប្រែងនេះដើម្បីវាស់វែង និងតាមដានការងារសមរម្យនៅកម្ពុជាឱ្យបានកាន់តែល្អប្រសើរឡើង ។

លោក សូវ ឈុនតេក សមាជិកក្រុមប្រឹក្សានាយក និងតំណាងឱ្យ CAMFEBA បានសម្តែងនូវការកោតសរសើរដល់ការចូលរួមរបស់ត្រីភាគី និងកិច្ចសហការក្នុងសិក្ខាសាលានេះ ។ លោកបានលើកឡើងពីសារៈសំខាន់នៃការពង្រឹងសំវាទសង្គមដើម្បីបង្កើត និងអនុវត្តន៍កម្មវិធីលើការវាស់វែងការងារសមរម្យនេះ ។ ជាចុងក្រោយ លោកបាននិយាយថា CAMFEBA បានប្តេជ្ញាចិត្ត និងបានត្រៀមខ្លួនដើម្បីចូលរួមចំណែក និងផ្តល់នូវការគាំទ្រដល់ការផ្តួចផ្តើមដ៏សំខាន់នេះដើម្បីតាមដានការងារសមរម្យនៅកម្ពុជា ។

លោកបណ្ឌិត វង្ស សុវណ្ណ ប្រធាន CCTU និងតំណាងសហជីពកម្មករកម្ពុជាបានសម្តែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអង្គការ ILO ដែលបានគាំទ្រ DWCP នៅកម្ពុជា និងបានបង្ហាញនូវការប្តេជ្ញាចិត្តទាំងស្រុងដើម្បីជួយសម្រេចបានការងារសមរម្យសម្រាប់កម្មករទាំងអស់នៅកម្ពុជា ។ លោកក៏បានទទួល

ស្គាល់ពីតម្លៃនៃសិក្ខាសាលា និងការតាមដានការងារសមរម្យជាទូទៅសម្រាប់ទាំងនិយោជក និងកម្មករនិយោជិត។ លោកបានអរគុណ MOLVT ដែលបានរៀបចំសិក្ខាសាលានេះ អ្នកចូលរួមទាំងអស់ដែលបានចូលរួមយ៉ាងសកម្ម និងអ្នកជំនាញជាតិ និងអន្តរជាតិដែលបានផ្តល់មតិយោបល់បច្ចេកទេសជាច្រើន។

ឯកឧត្តម សាត សាមុទ្រ អនុរដ្ឋលេខាក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានបង្ហាញនូវការកោតសរសើរចំពោះ EU និងអង្គការ ILO សម្រាប់ការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុនៅក្នុងសិក្ខាសាលានេះ។ សិក្ខាសាលានេះមានសារៈសំខាន់ណាស់ក្នុងការរកអត្តសញ្ញាណសូចនាករការងារសមរម្យដើម្បីវាស់វែងការងារសមរម្យនៅកម្ពុជា។ មុននឹងបិទអង្គសិក្ខាសាលា ឯកឧត្តមបានស្នើសុំឱ្យអ្នកពាក់ព័ន្ធត្រីភាគីទាំងអស់ និងស្ថាប័នពាក់ព័ន្ធខិតខំធ្វើការបន្ថែមទៀតដើម្បីដោះស្រាយបញ្ហាប្រឈមដែលបានរកឃើញនៅក្នុងអង្គសិក្ខាសាលា ជាពិសេសការពិនិត្យមើលឡើងវិញនូវគម្លាតនៃការវាស់វែងការងារសមរម្យ។

# ឧបសម្ព័ន្ធ ១: បញ្ជីឈ្មោះអ្នកចូលរួម

| ល.រ | ឈ្មោះ | ភេទ | ស្ថាប័ន | តួនាទី |
|---|---|---|---|---|
| **រដ្ឋាភិបាល** | | | | |
| ១ | សយ អ៊ីង | ប | CARD | អគ្គនាយករង |
| ២ | វ៉ៃន សុវត្ថា | ប | CDC | អគ្គនាយករង |
| ៣ | ឆឹង វិជ្ជា | ប | DOLVT ខេត្តកំពង់ចាម | ប្រធានការិយាល័យ |
| ៤ | ស៊ីម សុវឌ្ឍនៈ | ប | DOLVT ខេត្តកំពង់ឆ្នាំង | ប្រធានការិយាល័យ |
| ៥ | អ៊ុយ សារឿន | ស | DOLVT ខេត្តកំពង់ស្ពឺ | ប្រធានការិយាល័យ |
| ៦ | ហៀក សុខន | ស | DOLVT ខេត្តកំពត | ប្រធានការិយាល័យ |
| ៧ | ស៊ី ឌី | ប | DOLVT ខេត្តព្រះសីហនុ | អនុប្រធាន |
| ៨ | ផាន់ សារ៉េត | ស | DOLVT ខេត្តស្វាយរៀង | មន្ត្រី |
| ៩ | អ៊ុង វណ្ណឌី | ប | DOLVT ខេត្តតាកែវ | ប្រធានការិយាល័យ |
| ១០ | រាម ច័ន្ទវណ្ណា | ប | MIME | អនុប្រធាន |
| ១១ | យិន សំបូរ | ប | MOEYS | អគ្គនាយករង |
| ១២ | ជួន សុម៉ាលី | ស | នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន នៃក្រសួងមហាផ្ទៃ | មន្ត្រី |
| ១៣ | កែវ សុវណ្ណមុន្នី | ប | MOLVT | ប្រធានការិយាល័យ |
| ១៤ | ងុយ រិទ្ធ | ប | MOLVT | អនុប្រធាន |
| ១៥ | បូ ច័ន្ទវាសនា | ស | នាយកដ្ឋានវិវាទការងារ DOLVT | អនុប្រធាន |
| ១៦ | ចិន យ៉ាន់សូថា | ប | នាយកដ្ឋានអធិការកិច្ចការងារ DOLVT | អនុប្រធាន |
| ១៧ | យ៉ាវ នី | ប | MOLVT/DOCL | ប្រធានការិយាល័យ |
| ១៨ | កូវ ប៊ុនធឿន | ប | MOLVT/ DOSH | មន្ត្រី |
| ១៩ | សេង សារ៉ាមុនី | ប | MOLVT/TVETM | មន្ត្រី |
| ២០ | អ៊ឹង សុគន្ធ | ប | អគ្គនាយកដ្ឋានផែនការ MOP | អនុប្រធាន |

| | | | | |
|---|---|---|---|---|
| ២១ | ជុតលាង វ៉ាន់នី | ស | MOWA | អគ្គនាយករង |
| ២២ | ហុង ជឿន | ប | NEA | អគ្គនាយក |
| ២៣ | ស៊ុម ហុង | ប | NEA | អនុប្រធាន |
| ២៤ | ហ៊ាង កាណុល | ប | NIS/MOP | អគ្គនាយករង |
| ២៥ | នួននិស្ស័យ កុសល | ប | NIS/MOP | ប្រធានការិយាល័យ |
| ២៦ | សេង ចិន្តា | ប | NIS/MOP | ជំនួយការអនុប្រធាន |
| ២៧ | សុខ កុសល | ប | NIS/MOP | អនុប្រធាន |
| ២៨ | ជួរ រតនៈ | ប | NSSF | ប្រធាន |
| ២៩ | ខួង ច័ន្ទតារា | ប | NSSF | អនុប្រធានការិយាល័យ |
| ៣០ | ម៉ូវ រដ្ឋា | ប | NSSF | មន្ត្រី |
| **ដៃគូសង្គម និងអង្គការមិនមែនរដ្ឋាភិបាល** | | | | |
| ៣១ | ឌីជេរ វ៉ែល | ប | ACILS/AFL-CIO | នាយកប្រចាំប្រទេស |
| ៣២ | យុន ថារ៉ូ | ប | ACILS | មន្ត្រីកម្មវិធី |
| ៣៣ | រស់ កាន | ស | ACILS | មន្ត្រីកម្មវិធី |
| ៣៤ | ស៊ីវ សុធា | ប | BWI | អ្នកសម្របសម្រួលគម្រោងថ្នាក់ជាតិ |
| ៣៥ | សុខ សុវណ្ណដេត | ប | BWTUC | ប្រធាន |
| ៣៦ | ដាញ់ អេងកក្កដា | ប | CAMFEBA | អ្នកគ្រប់គ្រង |
| ៣៧ | ហួន សុខភានាថ | ប | CAMFEBA | មន្ត្រីផ្នែកច្បាប់ |
| ៣៨ | សាន់ដ្រា អាមីកូ | ស | CAMFEBA | អនុប្រធាន |
| ៣៩ | សូវ ឈុនតេក | ប | CAMFEBA | សមាជិកក្រុមប្រឹក្សានាយក |
| ៤០ | អ៊ុំ វិសាល | ប | CCAWDU | មន្ត្រីផ្នែកច្បាប់ |
| ៤១ | វង្ស សុវណ្ណ | ប | CCTU | ប្រធាន |
| ៤២ | ម៉ៃ សុភត្រា | ប | CCU | សមាជិក |
| ៤៣ | សៀន សុខនី | ស | CIYA | អ្នកហាត់ការ |
| ៤៤ | ឈន សុខា | ស | CLEC | មន្ត្រីកម្មវិធី |
| ៤៥ | ម៉ម ញឹម | ស | CNC | ប្រធាន |
| ៤៦ | ស្រេង ដាណេ | ស | FLD | មន្ត្រី |

| | | | | |
|---|---|---|---|---|
| ៤៧ | កៅ ពឿន | ប | LO/FTF | អ្នកសម្របសម្រួលគម្រោង |
| ៤៨ | ហុង សុភា | ប | LSCW | ជំនួយការគម្រោង |
| ៤៩ | ឃ្លាំង សុវណ្ណា | ស | LSCW | គ្រូបណ្ដុះបណ្ដាល |
| ៥០ | នួន ចន្ថា | ប | NACC | សមាជិក |
| **អង្គការពលកម្មអន្តរជាតិ** | | | | |
| ៥១ | រស់ ប៊ុនឡេង | ប | ILO | មន្ត្រីហិរញ្ញវត្ថុ |
| ៥២ | ឃ្លាំង រីម | ប | ILO | អ្នកសម្របសម្រួលគម្រោងថ្នាក់ជាតិ |
| ៥៣ | ម៉ារ៉េ ហ្គាវីន | ស | ILO | មន្ត្រីទំនាក់ទំនង |
| ៥៤ | ប៉េង ឡូឌី | ស | ILO | ជំនួយការកម្មវិធី |
| ៥៥ | ហេង សិលទិ | ស | ILO | អ្នកសម្របសម្រួលគម្រោងថ្នាក់ជាតិ |
| ៥៦ | ទុន សុភ័ណ | ប | ILO | អ្នកសម្របសម្រួលគម្រោងថ្នាក់ជាតិ |
| ៥៧ | យឹម សេរីវឌ្ឍនៈ | ប | ILO | អ្នកសម្របសម្រួលគម្រោងថ្នាក់ជាតិ |
| ៥៨ | ប៉ោ ដួង | ស | ILO/AIDS | អ្នកសម្របសម្រួលគម្រោងថ្នាក់ជាតិ |
| ៥៩ | អាលីស ឡេវីសាយ | ស | ILO/BFC | អ្នកហាត់ការ |
| ៦០ | អ៊ីនដ្រា សូរ៉េន | ស | ILO/BFC | ប្រធានគម្រោង |
| ៦១ | គ្លួរៀរ អានហ្គួ | ស | ILO/ITP | អ្នកសម្របសម្រួលគម្រោងថ្នាក់ជាតិ |
| ៦២ | សេក សោភ័ណ | ប | ILO/ITP | អ្នកសម្របសម្រួលគម្រោងថ្នាក់ជាតិ |
| ៦៣ | ជា សុផល | ប | ILO/MDG | អ្នកសម្របសម្រួលគម្រោងថ្នាក់ជាតិ |
| ៦៤ | ទូ ភារី | ស | ILO/SPG | អ្នកសម្របសម្រួលគម្រោងថ្នាក់ជាតិ |
| **អ្នកជំនាញបច្ចេកទេសមកពីអង្គការ ILO** | | | | |
| ៦៥ | Elisa Benes | ស | ILO/Geneva | អ្នកជំនាញស្ថិតិ |
| ៦៦ | Suradee Bhadrasiri | ស | ILO/Bangkok | មន្ត្រីកម្មវិធី |
| ៦៧ | Monica D. Castillo | ស | ILO/Geneva | ប្រធាន អង្គភាពផលិតកម្មទិន្នន័យការងារសមរម្យ |
| ៦៨ | Phu Huynh | ប | ILO/Bangkok | មន្ត្រី LMI |

## ឧបសម្ព័ន្ធ ២: កម្មវិធីនៃសិក្ខាសាលា

**សិក្ខាសាលាបណ្តុះបណ្តាល និងពិគ្រោះយោបល់ត្រីភាគី**

**ស្តីពី**

**" ការវាស់វែងការងារសមរម្យនៅប្រទេសកម្ពុជា"**

**ថ្ងៃទី០៤-០៦ ខែឧសភា ឆ្នាំ២០១១**

**សណ្ឋាគារភ្នំពេញ រាជធានីភ្នំពេញ**

| ថ្ងៃពុធ ទី០៤ ខែឧសភា ឆ្នាំ២០១១ | |
|---|---|
| ៨:០០-៨:៤៥ | ការចុះឈ្មោះអ្នកចូលរួម |
| ៨:៤៥-៩:០០ | ពិធីបើកសិក្ខាសាលា<br>- ប្រកាសហេតុ (អ្នករៀបចំកម្មវិធីនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ)<br>- គោរពទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា |
| ៩:០០-១០:០០ | សន្ទរកថាស្វាគមន៍ និងបើកអង្គសិក្ខាសាលា<br>• សន្ទរកថាស្វាគមន៍របស់លោកស្រី Monica D. Castillo ប្រធានអង្គភាពផលិតកម្មទិន្នន័យការងារសមរម្យ នាយកដ្ឋានស្ថិតិនៃអង្គការពលកម្មអន្តរជាតិ (ILO Geneva)<br>• មតិស្វាគមន៍របស់លោកស្រី Sandra D'amico អនុប្រធានសហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា (CAMFEBA)<br>• មតិរបស់លោកបណ្ឌិត វង្ស សុវណ្ណ ប្រធានសហភាពសហព័ន្ធសហជីពជាតិកម្ពុជា តំណាងនៃសហជីពកម្មករកម្ពុជា<br>• សន្ទរកថាបើកសិក្ខសាលារបស់ឯកឧត្តម សាត សាមុទ្រ អនុរដ្ឋលេខាធិការនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ១០:០០-១០:១៥ | សម្រាក ពិសារភេសជ្ជៈ |
| ១០:១៥-១១:៣០ | សម័យប្រជុំទី១: ការតាមដាននិយោជន៍ជាតិ និងគំនិតផ្តួចផ្តើមនៃការអភិវឌ្ឍ<br>• *ការតាមដានកម្មវិធីអភិវឌ្ឍន៍ជាតិដែលទាក់ទងនឹងការងារសមរម្យនៅកម្ពុជា* (លោក អ៊ឹង សុគន្ធ អនុប្រធាននាយកដ្ឋានផែនការសង្គមនៃអង្គនាយកដ្ឋានផែនការ)<br>សម័យប្រជុំនឹងលើកឡើងអំពីតម្រូវការទិន្នន័យការងារសមរម្យសំខាន់ៗក្នុងការតាមដានផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ និងគោលដៅអភិវឌ្ឍន៍សហវត្សរ៍កម្ពុជា និងបង្ហាញអំពីសមាភាគដែលទាក់ទងនឹងក្របខណ្ឌសូចនាករនៃផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ និងគោលដៅអភិវឌ្ឍន៍សហវត្សរ៍កម្ពុជាដែលពាក់ព័ន្ធនឹងនិយោជន៍ និងការងារសមរម្យ។ |

| | |
|---|---|
| | • *ប្រព័ន្ធព័ត៌មានទីផ្សារការងារជាតិកម្ពុជា* (ឯកឧត្តម ហុង ជឿន នាយកទីភ្នាក់ងារជាតិមុខរបរ និងការងារ)<br>សម័យប្រជុំនឹងផ្តល់នូវទស្សនៈនៃប្រព័ន្ធព័ត៌មានទីផ្សារការងារជាតិកម្ពុជា និងកត់សម្គាល់ពីសូចនាករស្ថិតិដែលជាគន្លឹះ ប្រភពទិន្នន័យជាតិ និងលទ្ធផល ។ ការបង្ហាញពីការសម្របសម្រួលស្ថាប័នជាមួយទីភ្នាក់ងាររដ្ឋាភិបាលនានាដើម្បីអភិវឌ្ឍន៍ ធ្វើឱ្យប្រសើរឡើង និងថែរក្សាប្រព័ន្ធ ។<br>• *កម្មវិធីការងារសមរម្យសម្រាប់ប្រទេស ឆ្នាំ២០១១-២០១៥: ដំណើរការ អាទិភាព និងលទ្ធផល* (លោក ទុន សុភ័ណ អ្នកសម្របសម្រួលជាតិរបស់អង្គការពលកម្មអន្តរជាតិសម្រាប់កម្ពុជា)<br>បទបង្ហាញនឹងលើកឡើងពីទស្សនៈនៃកម្មវិធីជាតិការងារសមរម្យសម្រាប់ប្រទេស ឆ្នាំ២០១១-២០១៥ ជាពិសេសវិស័យអាទិភាព និងលទ្ធផលស្របតាមយន្តការសម្រាប់ការរៀបចំ ការអនុវត្ត និងការតាមដានកម្មវិធី ។<br>• ការពិភាក្សាពេញអង្គ |
| ១១:៣០-១២:៣០ | សម័យប្រជុំទី២: សាវតារស្តីពីការវាស់វែងការងារសមរម្យ<br>• *គម្រោងរបស់អង្គការ ILO ស្តីពីការវាស់វែងការងារសមរម្យ* (លោកស្រី Monica D. Castillo, ILO Geneva)<br>សម័យប្រជុំនឹងលើកឡើងនូវទស្សនៈទាននៃគម្រោងការអន្តរជាតិសម្រាប់ការវាស់វែងការងារសមរម្យដែលបានអនុម័ត និងលើកទឹកចិត្តដោយអង្គការពលកម្មអន្តរជាតិ ដោយរាប់បញ្ចូលនូវសូចនាករក្របខណ្ឌគតិយុត្តសម្រាប់ការងារសមរម្យ ។<br>• *ទស្សនៈនៃការវាស់វែងការងារសមរម្យនៅកម្ពុជា* (លោក Phu Huynh, ILO/EC MAP, ILO Bangkok)<br>សម័យប្រជុំនឹងផ្តល់នូវទស្សនៈនៃគម្រោងរបស់គណៈកម្មការអឺរ៉ុប និងអង្គការពលកម្មអន្តរជាតិស្តីពី "ការតាមដាន និងវាយតម្លៃវឌ្ឍនភាពស្តីពីការងារសមរម្យ" និងបង្ហាញសាវតារស្តីពីប្រភពជាបឋមនៃទិន្នន័យជាតិសម្រាប់វាស់វែងការងារសមរម្យ ។ ការពិភាក្សាពីការផ្សារភ្ជាប់រវាងសូចនាករការងារសមរម្យ និងកម្មវិធីការងារសមរម្យសម្រាប់ប្រទេសកម្ពុជា និងកត់សម្គាល់ពីបញ្ហាប្រឈមមួយចំនួន និងអាទិភាពក្នុងការផលិត និងការតាមដាននៃសូចនាករការងារសមរម្យនៅក្នុងប្រទេស ។<br>• ការពិភាក្សាពេញអង្គ |
| ១២:៣០-១៣:៤៥ | សម្រាក ពិសារអាហារថ្ងៃត្រង់ |
| ១៣:៤៥-១៥:៣០ | សម័យប្រជុំទី៣: ការតាមដានវឌ្ឍនភាពស្តីពីការងារសមរម្យ<br>**- កាលានុវត្តភាពការងារ**<br>**- ប្រាក់ឈ្នួលគ្រប់គ្រាន់ និងផលិតភាពការងារ**<br>**- ម៉ោងការងារសមរម្យ**<br>**- ការងាររួមផ្សំ ជីវិតផ្ទាល់ខ្លួន និងគ្រួសារ** |

| | |
|---|---|
| | **- ស្ថិរភាព និងសន្តិសុខការងារ**<br>• *ទស្សនៈទាន និយម័យ និងការបកស្រាយ* (លោកស្រី Monica D. Castillo, ILO Geneva)<br>• *ការរៀបចំតារាងទិន្នន័យចេញពីប្រភពទិន្នន័យអង្កេតជាតិដែលមានបច្ចុប្បន្ន* (លោក ហ៊ាង កាណុល អគ្គនាយករងនៃវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ)<br>• ការពិភាក្សាពេញអង្គ |
| ១៥:៣០-១៥:៤៥ | សម្រាក ពិសារភេសជ្ជៈ |
| ១៥:៤៥-១៧:០០ | សម័យប្រជុំទី៣: ការតាមដានវឌ្ឍនភាពស្តីពីការងារសមរម្យ<br>*ការពិភាក្សា និងលំហាត់ការងារតាមក្រុម* |
| **ថ្ងៃព្រហស្បត្តិ៍ ទី០៥ ខែឧសភា ឆ្នាំ២០១១** | |
| ៩:០០-១០:០០ | សម័យប្រជុំទី៣: ការតាមដានវឌ្ឍនភាពស្តីពីការងារសមរម្យ<br>*ការរាយការណ៍ត្រឡប់ទៅឱ្យសម័យប្រជុំពេញអង្គអំពីលទ្ធផលនៃលំហាត់ការងារតាមក្រុម* |
| ១០:០០-១០:១៥ | សម្រាក ពិសារភេសជ្ជៈ |
| ១០:១៥-១២:០០ | សម័យប្រជុំទី៤: ការតាមដានវឌ្ឍនភាពស្តីពីការងារសមរម្យ<br>- សុវត្ថិភាពនៃបរិស្ថានការងារ<br>- សន្តិសុខសង្គម<br>- សំវាទសង្គម តំណាងកម្មករ និងតំណាងនិយោជិត<br>• *ទស្សនៈទាន និយម័យ និងការបកស្រាយ* (លោក Phu Huynh, ILO/EC MAP, ILO Bangkok)<br>• *ការរៀបចំតារាងទិន្នន័យចេញពីប្រភពទិន្នន័យអង្កេតជាតិដែលមានបច្ចុប្បន្ន* (លោក ហឿង សុផុន ប្រធាននាយកដ្ឋានព័ត៌មានទីផ្សារការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ) |
| ១២:០០-១៣:៣០ | សម្រាក ពិសារអាហារថ្ងៃត្រង់ |
| ១៣:៣០-១៥:០០ | សម័យប្រជុំទី៤: ការតាមដានវឌ្ឍនភាពស្តីពីការងារសមរម្យ (បន្ត)<br>*ការពិភាក្សា និងលំហាត់ការងារតាមក្រុម*<br>*ការរាយការណ៍ត្រឡប់ទៅឱ្យសម័យប្រជុំពេញអង្គអំពីលទ្ធផលនៃលំហាត់ការងារតាមក្រុម* |
| ១៥:០០-១៥:១៥ | សម្រាក ពិសារភេសជ្ជៈ |
| ១៥:១៥-១៧:០០ | សម័យប្រជុំទី៥: ការតាមដានវឌ្ឍនភាពស្តីពីការងារសមរម្យ<br>- ការងារដែលត្រូវលុបបំបាត់ចោល<br>- សមភាពនៃកាលានុវត្តភាព និងប្រព្រឹត្តកម្មក្នុងការងារ<br>- បរិបទសេដ្ឋកិច្ច និងសង្គមសម្រាប់ការងារសមរម្យ<br>• *ទស្សនៈទាន និយម័យ និងការបកស្រាយ* (លោកស្រី Monica D. Castillo, ILO Geneva)<br>• *ការរៀបចំតារាងទិន្នន័យចេញពីប្រភពទិន្នន័យអង្កេតជាតិដែលមានបច្ចុប្បន្ន* (លោក សុខ កុសល អនុប្រធាននាយកដ្ឋាននៃវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ) |

| ថ្ងៃសុក្រ ទី០៥ ខែឧសភា ឆ្នាំ២០១១ | |
|---|---|
| ៩:០០-១០:៤៥ | សម័យប្រជុំទី៥: ការតាមដានវឌ្ឍនភាពស្តីពីការងារសមរម្យ (បន្ត)<br>*ការពិភាក្សា និងលំហាត់ការងារតាមក្រុម*<br>*ការរាយការណ៍ត្រឡប់ទៅឱ្យសម័យប្រជុំពេញអង្គអំពីលទ្ធផលនៃលំហាត់ការងារតាមក្រុម* |
| ១០:៤៥-១១:១៥ | សម្រាក ពិសារភេសជ្ជៈ |
| ១១:១៥-១២:១៥ | សម័យប្រជុំទី៦: អាទិភាពសម្រាប់គម្រោងការជាតិតាមដានការងារសមរម្យ<br>សម័យប្រជុំនឹងត្រួតពិនិត្យមើលបញ្ជីពេញលេញនៃសូចនាករការងារសមរម្យនៅកម្ពុជាដែលបានស្នើឡើងដោយក្រុមការងារនៅក្នុងសម័យប្រជុំទី៣ដល់ទី៥ និងពិភាក្សាពីគម្លាតដែលមាន (សូចនាករដែលមិនទាន់អាចរកបានពីឧបករណ៍ស្ថិតិដែលមានបច្ចុប្បន្ន) និងមធ្យោបាយដែលអាចវាស់វែងវា។<br>សម័យប្រជុំនឹងពិនិត្យឡើងវិញដោយសង្ខេបនូវអាទិភាពជាបឋមនៃកម្មវិធីការងារសមរម្យសម្រាប់ប្រទេស ឆ្នាំ២០១១-២០១៥ និងកង្វល់នៃការអភិវឌ្ឍជាតិដទៃទៀតដែលពាក់ព័ន្ធនឹងការងារសមរម្យនៅក្នុងសម័យប្រជុំទី១។ បន្ទាប់មក តាមរយៈលំហាត់សម្របសម្រួល អ្នកចូលរួមម្នាក់ៗនឹងបោះឆ្នោតជ្រើសរើសយកបញ្ជីសម្រាំងមួយនៃសូចនាករការងារសមរម្យកម្ពុជាដែលជាអាទិភាព ចេញពីបញ្ជីពេញលេញដែលបានស្នើឡើងដោយក្រុមការងារនៅក្នុងសម័យប្រជុំទី៣ ដល់ទី៥។ សូចនាករអាទិភាពនឹងត្រូវបានផ្តល់អនុសាសន៍ និងលើកទឹកចិត្តសម្រាប់ការតាមដានកម្រិតជាតិនៅក្នុងបរិបទនៃកម្មវិធីការងារសមរម្យសម្រាប់ប្រទេស ឆ្នាំ២០១១-២០១៥ និងបន្តទៀត។ |
| ១២:១៥-១៤:០០ | សម្រាក ពិសារអាហារថ្ងៃត្រង់ |
| ១៤:០០-១៤:៣០ | សម័យប្រជុំទី៦: អាទិភាពសម្រាប់គម្រោងការជាតិតាមដានការងារសមរម្យ<br>*ការរាយការណ៍នូវតារាងអាទិភាពនៃសូចនាករការងារសមរម្យកម្ពុជាដែលបានផ្តល់អនុសាសន៍សម្រាប់ការតាមដាននៅថ្នាក់ជាតិ)* |
| ១៤:៣០-១៥:៣០ | សម័យប្រជុំទី៧: **ការសម្លឹងឆ្ពោះទៅមុខ: ការពង្រឹងការសម្របសម្រួលស្ថាប័ន និងការរកអត្តសញ្ញាណវិស័យជាអាទិភាពសម្រាប់កិច្ចផ្នែកសហការបច្ចេកទេសរវាងកម្ពុជា អង្គការពលកម្មអន្តរជាតិ និងដៃគូអភិវឌ្ឍន៍។**<br>សម័យប្រជុំនឹងផ្តល់នូវវេទិកាសម្រាប់អ្នកចូលរួមដើម្បីពិនិត្យមើលឡើងវិញនូវយន្តការកិច្ចសហការរវាងទីភ្នាក់ងារជាតិដែលពាក់ព័ន្ធនឹងការផលិតស្ថិតិការងារសមរម្យ ក៏ដូចជារវាងអ្នកផលិត និងអ្នកប្រើប្រាស់ទិន្នន័យការងារសមរម្យ។ សម័យប្រជុំនឹងពិចារណាពីគម្លាត និងបញ្ហាប្រឈមនៅក្នុងការវាស់វែងការងារសមរម្យនៅកម្ពុជាដូចដែលបានពិភាក្សានៅក្នុងសម័យប្រជុំរយៈពេល៣ថ្ងៃ និងកំណត់ពីវិស័យសម្រាប់កិច្ចសហការ និងការគាំទ្រពីអង្គការពលកម្មអន្តរជាតិ និងដៃគូអភិវឌ្ឍន៍ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ។ អ្នកចូលរួមនឹងពិចារណាពីសំនួរណែនាំដូចខាងក្រោម:<br>១) តើយន្តការជាស្ថាប័ន និងដំណើរការណាដែលគួរត្រូវបានបង្កើត ឬពង្រឹងរវាងអ្នកផលិត និងអ្នកប្រើប្រាស់ទិន្នន័យសម្រាប់ការតាមដានវឌ្ឍនភាពស្តីពីការងារសមរម្យនៅកម្ពុជា? តើអង្គការពលកម្មអន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានាអាចជួយគាំទ្រដល់អ្នកពាក់ព័ន្ធជាតិនៅក្នុងកិច្ចប្រឹងប្រែងនេះដោយរបៀបណា? |

| | |
|---|---|
| | ២) ចំពោះការប្រមូលទិន្នន័យ ការវិភាគទិន្នន័យ និងការតាមដាន និងការកសាងសមត្ថភាពស្តីពីការវាស់វែងការងារសមរម្យ តើអាទិភាព និងសកម្មភាពជាក់លាក់នានានៅកម្ពុជាណាដែលគួរអនុវត្តន៏បន្តទៅមុខទៀត? តើអង្គការពលកម្មអន្តរជាតិ និងដៃគូអភិវឌ្ឍន៏អាចជួយគាំទ្រដល់អ្នកពាក់ព័ន្ធជាតិនៅក្នុងកិច្ចខិតខំប្រឹងប្រែងនេះដោយរបៀបណា?<br>*អ្នកសម្របសម្រួល:* លោកស្រី Monica D. Castillo, ILO Geneva)<br>**ការបូកសរុបបញ្ចប់** |
| ១៥:៣០-១៦:០០ | សម្រាក ពិសារភេសជ្ជៈ |
| ១៦:០០-១៧:០០ | ពិធីបិទអង្គសិក្ខាសាលា<br>• សន្ទរកថារបស់លោកស្រី Monica D. Castillo ប្រធានអង្គភាពផលិតកម្មទិន្នន័យការងារសមរម្យ នាយកដ្ឋានស្ថិតិនៃអង្គការពលកម្មអន្តរជាតិ (ILO Geneva)<br>• មតិរបស់លោក សូវ ឈុនតេក សមាជិកក្រុមប្រឹក្សានាយកនៃសហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា (CAMFEBA)<br>• មតិរបស់លោកបណ្ឌិត វង្ស សុវណ្ណ ប្រធានសហភាពសហព័ន្ធសហជីពជាតិកម្ពុជា តំណាងនៃសហជីពកម្មករកម្ពុជា<br>• សន្ទរកថាបិទអង្គសិក្ខាសាលារបស់ឯកឧត្តម សាត សាមុទ្រ អនុរដ្ឋលេខាធិការនៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>ពិធីចែកវិញ្ញាបនបត្រដល់សិក្ខាកាមដែលបានចូលរួម |
| ១៧:០០ | ប្រកាសបិទកម្មវិធី |

## ឧបសម្ព័ន្ធ ៣៖ និដ្ឋភាពរួមនៃសូចនាករការងារសមរម្យដែលស្នើឡើង ដោយក្រុមការងារសម្រាប់ការតាមដានថ្នាក់ជាតិនៅកម្ពុជា និងដោយមានបង្ហាញពីប្រភពទិន្នន័យ

| ធាតុផ្សំសម្រាប់របៀបវារៈការងារសមរម្យ | សូចនាករសម្គាល់ | សូចនាករ M = សូចនាករសំខាន់ A = សូចនាករបន្ថែម C = សូចនាករបរិបទ (គ្រប់សូចនាករដែលសម្គាល់ដោយ 'S' ត្រូវបែងចែកតាមភេទ) | ប្រភពទិន្នន័យ |
|---|---|---|---|
| កាលានុវត្តភាពការងារ | EMPL-1 | M – អនុបាតនៃចំនួនអ្នកមានការងារធ្វើធៀបជាមួយចំនួនប្រជាជន អាយុ១៥ឆ្នាំឡើង (S) | LFS/PC/CSES |
| | EMPL-2 | M – អត្រាគ្មានការងារធ្វើ (S) | LFS/PC/CSES |
| | EMPL-3 | M – យុវជនមិនបានចូលរៀន និងគ្មានការងារធ្វើ អាយុ១៥-២៤ឆ្នាំ (S) | LFS/PC/CSES |
| | EMPL-4 | M – អ្នកមានការងារធ្វើក្នុងវិស័យក្រៅប្រព័ន្ធ (S) | N/A |
| | EMPL-5 | A –អត្រាចូលរួមក្នុងកម្លាំងពលកម្ម អាយុ១៥ឆ្នាំឡើង | LFS/PC/CSES |
| | EMPL-6 | A –អត្រាគ្មានការងារធ្វើរបស់យុវជន អាយុ១៥-២៤ឆ្នាំ (S) | LFS/PC/CSES |
| | EMPL-7 | A –អ្នកគ្មានការងារធ្វើតាមកម្រិតនៃការសិក្សា (S) | LFS/PC/CSES |
| | EMPL-8 | A –អ្នកមានការងារធ្វើតាមស្ថានភាពក្នុងការងារ (S) | LFS/PC/CSES |
| | EMPL-9 | A – សមាមាត្រនៃអ្នកប្រកបអាជីវកម្មប្រើទុនផ្ទាល់ខ្លួន និងអ្នកធ្វើការឱ្យគ្រួសារមិនគិតប្រាក់ឈ្នួលនៅក្នុងចំនួនអ្នកមានការងារធ្វើទាំងអស់ (S) | LFS/PC/CSES |
| | EMPL-10 | A – ចំណែកនៃប្រាក់ឈ្នួលនៅក្នុងការងារមិនមែនកសិកម្ម (S) | LFS/PC/CSES |
| | N/A | A – អាត្រានិស្សិតមានការងារធ្វើបន្ទាប់ពីវគ្គបណ្តុះបណ្តាល/ការសិក្សា* | N/A |
| | N/A | A – កម្មករនៅក្នុងសហគ្រាសខ្នាតតូចនៅក្នុងវិស័យក្រៅប្រព័ន្ធ* | N/A |
| ប្រាក់ឈ្នួលគ្រប់គ្រាន់ និងផលិតភាពការងារ | EARN-1 | M – ការងារបានចំណូលតិច (S) | CSES |
| | EARN-2 | M – អត្រាផ្តល់ប្រាក់ទាប (ក្រោម ២/៣នៃសមឌ្ឍរេខាប្រាក់ឈ្នួល (median earnings) ក្នុង១ម៉ោង) (S) | CSES |

| | | | |
|---|---|---|---|
| | EARN-3 | A – ប្រាក់ឈ្នួលមធ្យមក្នុង១ម៉ោងនៃមុខរបរជ្រើសរើស (S) | CSES |
| | EARN-4 | A – ប្រាក់ឈ្នួលមធ្យមពិត (ធៀបទៅនឹងសន្ទស្សន៍ថ្លៃទំនិញ) (S) | CSES and National accounts |
| | EARN-5 | A – ប្រាក់ឈ្នួលអប្បបរមា ជា%នៃសមឌ្ឍរេខាប្រាក់ឈ្នួល (median wage) | CSES |
| | EARN-6 | A – សន្ទស្សន៍ប្រាក់ឈ្នួលនៅក្នុងកម្មន្តសាល | N/A |
| | EARN-7 | A – និយោជិតដែលទើបទទួលការបណ្តុះបណ្តាលមុខជំនាញ (ឆ្នាំមុន/៤សប្តាហ៍មុន) (S) | N/A |
| | N/A | A – ចំណាយមធ្យមប្រចាំខែរបស់កម្មករ* | N/A |
| ម៉ោងការងារសមរម្យ | HOUR-1 | M – ម៉ោងធ្វើការហួសប្រមាណ (ច្រើនជាង៤៨ម៉ោងក្នុង១សប្តាហ៍ "ម៉ោងធម្មតា") (S) | LFS/CSES |
| | HOUR-2 | A – ម៉ោងធ្វើការធម្មតា (ស្តង់ដារម៉ោងធ្វើការ) (S) | LFS/CSES |
| | HOUR-3 | A – ម៉ោងធ្វើការប្រចាំឆ្នាំក្នុងនិយោជិតម្នាក់ (S) | N/A |
| | HOUR-4 | A – អត្រាពេលវេលាទាក់ទងនឹងការមានការងារធ្វើមិនពេញលេញ (S) | LFS/CSES |
| ការងាររួមផ្សំជីវិតផ្ទាល់ខ្លួន និងគ្រួសារ | - | - | |
| ការងារដែលត្រូវលុបបំបាត់ចោល | ABOL-1 | M – ពលកម្មកុមារ (ដូចដែលបានកំណត់ដោយសេចក្តីសម្រេចរបស់ ICLS) (S) | CLS |
| | ABOL-2 | A – ពលកម្មកុមារប្រកបដោយគ្រោះថ្នាក់តាមប្រភេទគ្រោះថ្នាក់ (S)* | CLS |
| ស្ថិរភាព និងសន្តិសុខការងារ | STAB-1 | M – ការងារប្រកបដោយគ្រោះថ្នាក់ (S) | N/A |
| | STAB-2 | A – រយៈពេលកាន់ការងារ (S) | N/A |
| | STAB-3 | A – ចំនួន និងប្រាក់ឈ្នួលកម្មករបណ្តោះអាសន្ន/កម្មករប្រចាំថ្ងៃ (S) | N/A |
| សមភាពនៃកាលានុវត្តភាព និងប្រព្រឹត្តកម្ម | EQUA-1 | M – ការចូលរួមចំណែករបស់ស្ត្រីក្នុងការងារតាមមុខរបរ (ប្រភេទទិន្នន័យ ISCO)* | LFS/PC/CSES |
| | EQUA-2 | M – ការចូលរួមចំណែករបស់ស្ត្រីក្នុងមុខរបរបែងចែកតាម | LFS/PC/CSES |

| | | | |
|---|---|---|---|
| ក្នុងការងារ | | ភេទក្នុង ISCO-៨៨ ក្រុម១១ និង ក្រុម១២ | |
| | EQUA-3 | A –គម្លាតប្រាក់ឈ្នួលនៃយេនឌ័រ | CSES |
| | EQUA-4 | A – សូចនាករសម្រាប់គោលការណ៍ជាមូលដ្ឋាន និងសិទ្ធិនៅកន្លែងធ្វើការ (ការលុបបំបាត់ការរើសអើងក្នុងការងារ និងមុខរបរ) ត្រូវបានអភិវឌ្ឍន៍ដោយការិយាល័យ | N/A |
| | EQUA-5 | A – វិធានការសម្រាប់ការរើសអើងដោយពូជសាសន៍/ជនជាតិភាគតិច/កម្មករចំណាកស្រុក/(ថ្មី)/កម្មករនៅជនបទនៅកន្លែងដែលមានការពាក់ព័ន្ធ និងអនុវត្តន៍នៅថ្នាក់ជាតិ | N/A |
| | N/A | A – កាលានុវត្តភាពការងារសម្រាប់ជនពិការ* | N/A |
| | N/A | A – កាលានុវត្តភាពការងារសម្រាប់ជនរងគ្រោះដោយសារការកេងប្រវ័ញ្ចផ្លូវភេទ* | N/A |
| សុវត្ថិភាពនៃបរិស្ថានការងារ | SAFE-1 | M – អត្រាគ្រោះថ្នាក់ការងារ , ស្លាប់ (ក្នុងនិយោជិត ១0000នាក់) តាមការកំណត់របស់ ISIC និង ISCO* | Administrative data |
| | SAFE-2 | A – អត្រាគ្រោះថ្នាក់ការងារ , មិនស្លាប់ (ក្នុងនិយោជិត ១0000នាក់) តាមការកំណត់របស់ ISIC និង ISCO* | Administrative data |
| | SAFE-3 | A – ពេលវេលាបាត់បង់ដោយសារគ្រោះថ្នាក់ការងារ | N/A |
| | SAFE-4 | A – អធិការកិច្ចការងារ (ចំនួនអធិការក្នុងនិយោជិត ១0000នាក់) | Administrative data |
| សន្តិសុខសង្គម | SECU-1 | M – ចំណែករបស់ប្រជាជនអាយុពី៦៥ឆ្នាំឡើងដែលបានទទួលអត្ថប្រយោជន៍ពីសោធន (S) | N/A |
| | SECU-2 | M – ការចំណាយនៃសន្តិសុខសង្គមសាធារណៈ (% នៃ GDP) | National accounts |
| | SECU-4 | A – ចំណែករបស់ប្រជាជនដែលបានទទួលការថែរក្សាសុខភាព (ជាមូលដ្ឋាន) (S) | N/A |
| | N/A | A – ការចំណាយរបស់រដ្ឋាភិបាលដើម្បីគាំទ្រអ្នកគ្មានការងារធ្វើ* | N/A |
| | N/A | A – ការចំណាយរបស់រដ្ឋាភិបាលសម្រាប់ការថែទាំកុមារអាយុក្រោម៣ឆ្នាំ* | N/A |
| | N/A | A – ការចំណាយរបស់រដ្ឋាភិបាលដើម្បីបង្កើត និងដំណើរការ | N/A |

| | | | |
|---|---|---|---|
| | | មណ្ឌលសម្រាប់មនុស្សចាស់ជរា និងកុមាររងាយរងគ្រោះ* | |
| សំវាទសង្គម តំណាងកម្មករ និងតំណាង និយោជក | DIAL-1 | M – អត្រាដង់ស៊ីតេសហជីព (S) | N/A |
| | DIAL-2 | M – សហគ្រាសជាកម្មសិទ្ធិរបស់អង្គការនិយោជក (អត្រា) | N/A |
| | DIAL-3 | M – អត្រាវិសាលភាពនៃអនុសញ្ញារួម (S) | N/A |
| | DIAL-4 | M – សូចនាករសម្រាប់គោលការណ៍ជាមូលដ្ឋាន និងសិទ្ធិនៅកន្លែងធ្វើការ (សេរីភាពក្នុងការបង្កើតសមាគម និងអនុសញ្ញារួម) ត្រូវបានអភិវឌ្ឍន៍ដោយការិយាល័យ | N/A |
| | DIAL-5 | A – កូដកម្ម និងឡុកអៅ/អត្រានៃថ្ងៃមិនបានធ្វើការ | Administrative data |
| បរិបទសេដ្ឋកិច្ច និងសង្គម សម្រាប់ការងារសមរម្យ | CONT-1 | C – កុមារមិនបានចូលរៀន (%តាមអាយុ) (S) | LFS/PC/CSES/ Administrative data |
| | CONT-2 | C – ការប៉ាន់ស្មាន%នៃប្រជាជនក្នុងអាយុធ្វើការដែលមានមេរោគហ៊ីវវិជ្ជមាន (S) | UNAIDS |
| | CONT-3 | C – ផលិតភាពការងារ (GDP ក្នុងនិយោជិតម្នាក់ , កម្រិត និងអត្រាកំណើន) | National accounts LFS/PC/CSES |
| | CONT-4 | C – ប្រាក់ចំណូលមិនស្មើភាព (percentile ratio P90/P10 ចំណូល ឬការប្រើប្រាស់) | CSES |
| | CONT-5 | C – អត្រាអតិផរណា (CPI) | National accounts |
| | CONT-6 | C – អ្នកមានការងារធ្វើតាមសកម្មភាពសេដ្ឋកិច្ច | LFS/PC/CSES |
| | CONT-7 | C – ការសិក្សានៃប្រជាជនពេញវ័យ (អត្រាអក្ខរកម្មប្រជាជនពេញវ័យ អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សារបស់ប្រជាជនពេញវ័យ) (S) | PC/CSES Administrative data |
| | CONT-8 | C – ការងាររួមចំណែកក្នុង GDP | N/A |
| | CONT-9 | C – (បន្ថែម) - GDP ពិតក្នុងមនុស្សម្នាក់ in PPP$ (កម្រិត និងអត្រាកំណើន) | National accounts |
| | CONT-10 | C – (បន្ថែម) -ស្ត្រីចូលរួមចំណែកក្នុងការងារតាមឧស្សាហកម្ម (ប្រភេទទិន្នន័យ ISIC) | LFS/PC/CSES |

| | | | |
|---|---|---|---|
| | CONT-11 | C – (បន្ថែម) - ប្រាក់ឈ្នួល/ប្រាក់ចំណូលមិនស្មើភាព (percentile ratio P90/P10) | CSES |
| | CONT-12 | C – (បន្ថែម) - សូចនាករនៃភាពក្រីក្រ (គម្លាត និងអត្រា) | CSES |

សម្គាល់: សូចនាករដែលលេខសូចនាករសម្គាល់ដកស្រង់ចេញពីក្របខណ្ឌកិច្ចប្រជុំត្រីភាគីនៃអ្នកជំនាញខាងវាស់វែងការងារសមរម្យ។ រីឯសូចនាករដែលមានសញ្ញា(*) មានលក្ខណៈជាក់លាក់ ឬត្រូវបានកែសម្រួលសម្រាប់កម្ពុជា។ “N/A” គឺមិនមានព័ត៌មាន។

ប្រភព: ការដកស្រង់ពីដំណើរការសិក្ខាសាលា។

## ILO/EC គម្រោង "ការតាមដាន និងវាយតម្លៃវឌ្ឍនភាពស្ដីពីការងារសមរម្យ" (MAP)

ការពិនិត្យតាមដាន និងវាយតំលៃអំពីវឌ្ឍនភាពសំដៅសំរេចបាននូវការងារសមរម្យ គឺជាកង្វល់ជាយូរមកហើយរបស់អង្គការពលកម្មអន្តរជាតិ និងសមាជិកជាតំណាងរបស់អង្គការនេះ។ គំរោង "ពិនិត្យតាមដាន និងវាយតំលៃអំពីវឌ្ឍនភាពនៃការងារសមរម្យ" (MAP) ដែលបានអនុវត្តដោយអង្គការពលកម្មអន្តរជាតិ ក្រោមជំនួយឧបត្ថម្ភរបស់សហគមន៍អឺរ៉ុប បានជួយដោះស្រាយនូវកង្វល់នេះ។ ក្នុងកំឡុងពេលបួនឆ្នាំនេះ (២០០៩-២០១៣) គំរោងនេះនឹងធ្វើការសហការជាមួយក្រសួងការងារ ការិយាល័យស្ថិតិជាតិ ទីភ្នាក់ងាររដ្ឋាភិបាល អង្គការនិយោជក និងកម្មករនិយោជិត និងស្ថាប័នស្រាវជ្រាវដទៃទៀត ដើម្បីជួយពង្រឹងសមត្ថភាពដល់ប្រទេសកំពុងអភិវឌ្ឍ និងប្រទេសនៅក្នុងដំណាក់កាលអន្តកាល ក្នុងការត្រួតពិនិត្យ និងវាយតម្លៃវឌ្ឍនភាព សំដៅការងារសមរម្យរបស់ខ្លួន។

គំរោងនេះជួយសម្របសម្រួលដល់អត្តសញ្ញាណរបស់សូចនាករការងារសមរម្យដែលផ្សារភ្ជាប់ទៅនឹង បញ្ហាអាទិភាពថ្នាក់ជាតិរបស់ប្រទេសគាំទ្រដល់ការប្រមូលទិន្នន័យ និងជួយក្នុងការវិភាគទិន្នន័យអំពីការងារ សមរម្យក្នុងគោលបំណងបង្កើតនូវភាពពាក់ព័ន្ធសម្រាប់អ្នកធ្វើគោលនយោបាយ។

ការបោះពុម្ពផ្សាយជាសេរីនៃគំរោង "ពិនិត្យតាមដាន និងវាយតំលៃអំពីវឌ្ឍនភាពនៃការងារសមរម្យ" (MAP) បានផ្សព្វផ្សាយអំពីទិន្នផលនៃគំរោងទៅកាន់អ្នកអានបានយ៉ាងទូលំទូលាយទៅដល់ប្រទេសដែលគំរោងនេះគ្របដណ្តប់ និងមិនគ្របដណ្តប់។ សម្រាប់ពត៌មានលម្អិតអំពីគំរោង "ពិនិត្យតាមដាន និងវាយតំលៃអំពីវឌ្ឍនភាពនៃការងារសមរម្យ"

សូមចូលមើលវ៉ិបសាយ **http://www.ilo.org/map**.

ISBN 978-92-2-825176-0

9 789228 251760